ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 9

# ឧបករណ៍ហិរញ្ញវត្ថុ

## Financial Instruments

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្ដើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្ដីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**វ៉ី តាយី**

## ជំពូកទី១ គោលបំណង

១.១ គោលបំណងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ នេះគឺដើម្បីកសាងគោលការណ៍ សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលនឹងបង្ហាញនូវព័ត៌មានពាក់ព័ន្ធ និងមានប្រយោជន៍ ទៅអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឲ្យពួកគេវាយតម្លៃលើបរិមាណ, ពេលវេលា, និងភាពមិនប្រាកដប្រជា នៃលំហូរចលនាសាច់ប្រាក់នាពេលអនាគតរបស់អង្គភាព។

## ជំពូកទី២ វិសាលភាព

២.១ អង្គភាពត្រូវអនុវត្តស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះចំពោះគ្រប់ធាតុទាំងអស់ ដែលស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដារគណនេយ្យអន្តរជាតិ ៣៩ *ឧបករណ៍ហិរញ្ញវត្ថុៈ ការទទួលស្គាល់និងការវាស់វែង*។

## ជំពូកទី៣ ការទទួលស្គាល់និងការមិនទទួលស្គាល់

## ៣.១ ការទទួលស្គាល់លើកដំបូង

៣.១.១ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែល, និងតែនៅពេលដែល, អង្គភាពក្លាយជាភាគីមួយនៃកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ (មើលកថាខណ្ឌ ខ៣.១.១ និងកថាខណ្ឌ ខ៣.១.២)។ នៅពេលអង្គភាពទទួលស្គាល់ជាលើកដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ, អង្គភាពត្រូវចាត់ថ្នាក់ទ្រព្យសកម្មនោះដោយអនុលោមតាមកថាខណ្ឌ ៤.១.១-៤.១.៥ និងវាស់វែងទ្រព្យសកម្មនោះ ដោយអនុលោមតាមកថាខណ្ឌ ៥.១.១ និង កថាខណ្ឌ ៥.១.២។ នៅពេលអង្គភាពទទួលស្គាល់ជាលើកដំបូងនូវបំណុលហិរញ្ញវត្ថុ, អង្គភាព ត្រូវចាត់ថ្នាក់បំណុលនោះ ដោយអនុលោមតាមកថាខណ្ឌ ៤.២.១-៤.២.២ និងវាស់វែងបំណុលនោះដោយអនុលោមតាមកថាខណ្ឌ ៥.១.១។

### ការទិញឬការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមវិធីធម្មតា

៣.១.២ ការទិញឬលក់នៃទ្រព្យសកម្មហិរញ្ញវត្ថុតាមវិធីធម្មតានឹងត្រូវទទួលស្គាល់និងមិនត្រូវទទួលស្គាល់, តាមតែអាចអនុវត្តបាន, ដោយប្រើគណនេយ្យនៃកាលបរិច្ឆេទជួញដូរ ឬគណនេយ្យ

**នៃកាលបរិច្ឆេទទូទាត់សង (មើលកថាខណ្ឌ ខ៣.១.៣-ខ៣.១.៦)។**

## ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ

៣.២.១ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម, កថាខណ្ឌ ៣.២.២-៣.២.៩ កថាខណ្ឌខ ៣.១.១- -ខ៣.១.២ និងកថាខណ្ឌ ខ៣.២.១៧ ត្រូវបានអនុវត្តនៅកម្រិតនៃការរួមបញ្ចូលរបាយការណ៍ហិរញ្ញ-វត្ថុ។ ដូច្នេះ ជាដំបូង អង្គភាពរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ទាំងអស់ ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ២៧ *របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក* និង SIC-12 *ការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពមានគោលបំណងពិសេស* និង បន្ទាប់មក អនុវត្តកថាខណ្ឌ ៣.២.២-៣.២.៩ កថាខណ្ឌ ខ៣.១.១ កថាខណ្ឌ ខ៣.១.២ និង កថាខណ្ឌខ៣.២.១៧ ចំពោះក្រុមហ៊ុនមេដែលបង្ហាញលទ្ធផល។

៣.២.២ **មុនពេលវាយតម្លៃថា ការមិនទទួលស្គាល់ និងកម្រិតនៃការមិនទទួលស្គាល់មានភាពសមរម្យតាមកថាខណ្ឌ ៣.២.៣-៣.២.៩, អង្គភាពត្រូវកំណត់ថា កថាខណ្ឌទាំងនោះអាចត្រូវបានអនុវត្តចំពោះផ្នែកមួយ នៃទ្រព្យសកម្មហិរញ្ញវត្ថុ (ឬផ្នែកមួយនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ឬទ្រព្យសកម្ម**

ហិរញ្ញវត្ថុមួយ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ) នៅក្នុងអង្គភាពទាំងមូលរបស់ខ្លួនដូចខាងក្រោម។

(ក) កថាខណ្ឌ ៣.២.៣-៣.២.៩ ត្រូវបានអនុវត្តចំពោះផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុមួយ (ឬផ្នែកមួយនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ក្នុងករណី, និងតែក្នុងករណី, ដែលផ្នែកនៃទ្រព្យសកម្មនោះត្រូវបានពិចារណាសម្រាប់ការមិនទទួលស្គាល់ ឆ្លើយតបលក្ខខណ្ឌមួយនៅក្នុងចំណោមលក្ខខណ្ឌបីខាងក្រោមៈ

(១) ផ្នែកនៃទ្រព្យសកម្មរួមមានតែចលនាសាច់ប្រាក់ដែលបានកំណត់យ៉ាងជាក់លាក់ ពីទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ស្រដៀងគ្នា)។ ជាឧទាហរណ៍ នៅពេលអង្គភាពចូលរួមនៅក្នុងកិច្ចសន្យាអត្រាការប្រាក់ដែលគូភាគីមានសិទ្ធិចំពោះចលនាសាច់ប្រាក់ជាការប្រាក់, ប៉ុន្តែ មិនមែនជាចលនាសាច់ប្រាក់ជាប្រាក់ដើម ពីឧបករណ៍ហិរញ្ញវត្ថុជាបំណុល, កថាខណ្ឌ ៣.២.៣-៣.២.៩ ត្រូវបានអនុវត្ត ចំពោះចលនាសាច់ប្រាក់ជាការប្រាក់។

(២) ផ្នែកនៃទ្រព្យសកម្ម រួមមានតែចំណែក តាម

សមាមាត្រពេញលេញនៃចលនាសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា)។ ជាឧទាហរណ៍ នៅពេលអង្គភាពចូលរួមនឹងកិច្ចព្រមព្រៀងមួយដែលគូភាគីទទួលបានសិទ្ធិរហូតដល់៩០ភាគរយនៃចលនាសាច់ប្រាក់ទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុជាបំណុល, កថាខណ្ឌ ៣.២.៣-៣.២.៩ ត្រូវបានអនុវត្តចំពោះ ៩០ ភាគរយ នៃចលនាសាច់ប្រាក់ទាំងនោះ។ ប្រសិនបើមានគូភាគីច្រើនជាងម្នាក់, គូភាគីនិមួយៗមិនតម្រូវឱ្យមានចំណែកតាមសមាមាត្រនៃចលនាសាច់ប្រាក់បានផ្តល់ដែលអង្គភាពផ្ទេរមានចំណែកសមាមាត្រពេញលេញ។

(៣) ផ្នែកនៃទ្រព្យសកម្មរួមមានតែចំណែកតាមសមាមាត្រពេញលេញ នៃចលនាសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា)។ ជាឧទាហរណ៍ នៅពេលអង្គភាពចូលរួមនឹងកិច្ចព្រមព្រៀងមួយដែលគូភាគីទទួលបានសិទ្ធិរហូតដល់ ៩០ភាគរយ នៃចលនាសាច់ប្រាក់ជាការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ, កថាខណ្ឌ៣.២.៣-៣.២.៩ ត្រូវបានអនុវត្តចំពោះ ៩០ភាគរយ នៃចលនាសាច់

ប្រាក់ជាការប្រាក់ទាំងនោះ។ ប្រសិនបើ មានគូភាគីច្រើនជាងម្នាក់, គូភាគីនិមួយៗមិនតម្រូវឲ្យមានចំណែកតាមសមាមាត្រនៃចលនាសាច់ប្រាក់បានផ្តល់ដែលអង្គភាពផ្ទេរមានចំណែកសមាមាត្រពេញលេញ។

(ខ) សម្រាប់ទ្រព្យសកម្មផ្សេងទៀត កថាខណ្ឌ ៣.២.៣-៣.២.៩ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលមាន (ឬចំពោះក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា)។ ជាឧទាហរណ៍ នៅពេលអង្គភាពផ្ទេរ (១) សិទ្ធិចំពោះ ៩០ភាគរយ ដំបូង ឬ៩០ភាគរយ ចុងក្រោយនៃការប្រមូលសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា), ឬ (២) សិទ្ធិរហូតដល់៩០ភាគរយនៃចលនាសាច់ប្រាក់ពីក្រុមនៃបរិមាណត្រូវទទួល, ប៉ុន្តែផ្តល់នូវការធានាសម្រាប់ការតបសងអ្នកទិញសម្រាប់ការខាតបង់ឥណទាន ដែលមានចំនួនដល់ទៅ៨ភាគរយនៃបរិមាណប្រាក់ដើមនៃបរិមាណត្រូវទទួល, កថាខណ្ឌ៣.២.៣--៣.២.៩ ត្រូវបានអនុវត្ត ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ទាំងអស់ដែលមាន។

កថាខណ្ឌ៣.២.៣-–៣.២.១២, ពាក្យថា "ទ្រព្យសកម្មហិរញ្ញវត្ថុ" សំដៅដល់ផ្នែកមួយនៃទ្រព្យសកម្ម (ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ដូចបានកំណត់ក្នុង(ក) ខាងលើ, បើមិនដូច្នេះទេ, ទ្រព្យសកម្មហិរញ្ញវត្ថុ (ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ទាំងអស់ដែលមាន។

៣.២.៣ អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែល, និងតែនៅពេលដែលៈ

(ក) សិទ្ធិតាមកិច្ចសន្យាលើចលនាសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដែលផុតកំណត់, ឬ

(ខ) វាផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ ដូចបានកំណត់ នៅក្នុងកថាខណ្ឌ៣.២.៤ និង កថាខណ្ឌ៣.២.៥ និងការផ្ទេរដែលមានលក្ខណៈសម្បត្តិសម្រាប់ការមិនទទួលស្គាល់ ដោយយោងតាម កថាខណ្ឌ៣.២.៦។

(មើលកថាខណ្ឌ៣.១.២ សម្រាប់ការលក់តាមវិធីធម្មតានៃទ្រព្យសកម្មហិរញ្ញវត្ថុ)

៣.២.៤ អង្គភាពផ្ទេរទ្រព្យសកម្ម ក្នុងករណី, និងតែក្នុងករណី, ដែលអង្គភាពៈ

(ក) ផ្ទេរសិទ្ធិតាមកិច្ចសន្យាដើម្បីទទួលនូវចនលនាសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ, ឬ

(ខ) រក្សាទុកសិទ្ធិតាមកិច្ចសន្យាដើម្បីទទួលនូវចលនាសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ, ប៉ុន្តែទទួលយកកាតព្វកិច្ចតាមកិច្ចសន្យា ដើម្បីសងចលនាសាច់ប្រាក់ទៅឲ្យអ្នកទទួលមួយ ឬច្រើននាក់នៅក្នុងកិច្ចព្រមព្រៀងដែលឆ្លើយតបទៅនឹងលក្ខខណ្ឌនានានៅក្នុង កថាខណ្ឌ ៣.២.៥។

៣.២.៥ នៅពេលអង្គភាពរក្សាទុកសិទ្ធិតាមកិច្ចសន្យាដើម្បីទទួលនូវចលនាសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ("ទ្រព្យសកម្មដើម") ប៉ុន្តែទទួលយកកាតព្វកិច្ចតាមកិច្ចសន្យាដើម្បីសងចលនាសាច់ប្រាក់ទៅឲ្យអង្គភាពមួយឬអង្គភាពច្រើន ("អ្នកទទួលចុងក្រោយ"), អង្គភាពចាត់ទុកប្រតិបត្តិការ នោះជាការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុក្នុងករណី និងតែក្នុងករណី ដែលលក្ខខណ្ឌទាំងបីខាងក្រោមត្រូវបានបំពេញ។

(ក) អង្គភាពមិនមានកាតព្វកិច្ចបង់ប្រាក់ទៅឲ្យអ្នកទទួលចុងក្រោយដរាបណា ខ្លួនប្រមូលប្រាក់បានពីទ្រព្យសកម្មដើមដំបូង។ ការបង់ប្រាក់មុនរយៈពេលខ្លីធ្វើឡើង ដោយអង្គភាពជាមួយនឹងសិទ្ធិនៃការទទួលបានគ្រប់ចំនួននៃបរិមាណបានខ្ចី បូកបន្ថែមនឹងការប្រាក់កើនថែមតាមអត្រាការប្រាក់ទីផ្សារ នឹងមិនប្រឆាំងលក្ខខណ្ឌនេះទេ។

(ខ) អង្គភាពត្រូវបានហាម តាមលក្ខខណ្ឌនៃកិច្ចសន្យាផ្ទេរនូវការលក់ឬដាក់បញ្ចាំទ្រព្យសកម្មដើមដំបូងដែលមិនមែនជាមូលបត្រទៅឱ្យអ្នកទទួលចុងក្រោយសម្រាប់កាតព្វកិច្ចបង់សាច់ប្រាក់ទៅឱ្យពួកគេ។

(គ) អង្គភាពមានកាតព្វកិច្ចផ្ទេរសាច់ប្រាក់ដែលខ្លួនប្រមូលបានក្នុងនាមអ្នកទទួលចុងក្រោយ ដោយមិនមានការពន្យាឡើយ។ បន្ថែមលើសនេះ អង្គភាពមិនមានសិទ្ធិវិនិយោគបន្តនូវសាច់ប្រាក់ទាំងនោះឡើយ លើកលែងតែ ការវិនិយោគក្នុងសាច់ប្រាក់និងសមមូលសាច់ប្រាក់ (ដូចបានកំណត់នៅក្នុងស្តង់ដាគណនេយ្យ អន្តរជាតិ៧ *របាយការណ៍លំហូរសាច់ប្រាក់*) ក្នុងអំឡុងពេលនៃកាទូទាត់រយៈពេលខ្លីគិតពីថ្ងៃប្រមូលប្រាក់ទៅ ដល់ថ្ងៃនៃការផ្ទេរដែលបានតម្រូវទៅឱ្យអ្នកទទួលចុងក្រោយ, ហើយការប្រាក់ដែលរកបានពីការវិនិយោគនោះត្រូវបញ្ជូនទៅឱ្យអ្នកទទួលចុងក្រោយនោះផងដែរ។

៣.២.៦ នៅពេលអង្គភាពផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ (មើល កថាខណ្ឌ ៣.២.៤) អង្គភាពត្រូវវាយតម្លៃវិសាលភាពដែលខ្លួនរក្សាបានហានិភ័យនិងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ក្នុងករណីនេះ÷

(ក) ប្រសិនបើអង្គភាពផ្ទេរយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យ និងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ, អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុនោះឡើយ និងត្រូវទទួលស្គាល់ដាច់ដោយឡែកថាជា ទ្រព្យសកម្ម ឬ បំណុល នូវសិទ្ធិនិងកាតព្វកិច្ចដែលបានបង្កើត ឬរក្សាទុកនៅក្នុងការផ្ទេរ។

(ខ) ប្រសិនបើអង្គភាពរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យ និងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ, អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។

(គ) ប្រសិនបើ អង្គភាពមិនផ្ទេរ ឬមិនរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យ និងផលចំណេញ នៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ, អង្គភាពត្រូវកំណត់ថាខ្លួនបានរក្សាទុកនូវការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុឬទេ។ក្នុងករណីនេះ

(១) ប្រសិនបើអង្គភាពមិនរក្សាទុកការគ្រប់គ្រង, អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងទទួលស្គាល់ដាច់ដោយឡែកថាជាទ្រព្យសកម្ម ឬបំណុល

**នូវសិទ្ធិ និង កាតព្វកិច្ចដែលបានបង្កើតឬរក្សាទុក នូវការផ្ទេរនោះ។**

**(២) ប្រសិនបើអង្គភាពរក្សាទុកការគ្រប់គ្រង, អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទៅតាមកម្រិតនៃការពាក់ព័ន្ធរបស់ខ្លួននៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុ។**

៣.២.៧ ការផ្ទេរហានិភ័យនិងផលចំណេញ (មើល កថាខណ្ឌ៣.២.៦) ត្រូវបានគេវាយតម្លៃ ដោយប្រៀបធៀបការប្រឈមហានិភ័យរបស់អង្គភាព មុននិងក្រោយការផ្ទេរ ជាមួយនឹងវិបវិឈាមភាពនៅក្នុងបរិមាណនៃចលនាសាច់ប្រាក់សុទ្ធនៃទ្រព្យសកម្ម ដែលបានផ្ទេរ។ អង្គភាពរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យនិងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើការប្រឈមហានិភ័យរបស់ខ្លួន ទៅនឹងវិបវិឈាមភាព ក្នុងតម្លៃបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ នាពេលអនាគត របស់ទ្រព្យសកម្មហិរញ្ញវត្ថុមិនប្រែប្រួលជាដុំកំភួន ដោយសារតែការផ្ទេរ (ឧ. ដោយសារក្រុមហ៊ុនបានលក់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវទិញយកមកវិញ តាមថ្លៃថេរ ឬតាមថ្លៃលក់បូកថែមកម្រិតចំណេញរបស់អ្នកឲ្យខ្ចី)។ អង្គភាពបានផ្ទេរយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យ និងផលចំណេញ នៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើការប្រឈមហានិភ័យរបស់ខ្លួនទៅនឹងវិបវិឈាមភាពមិនមានជាដុំកំភួនធៀបទៅនឹងវិបវិឈាម

ភាពសរុប នៃតម្លៃបច្ចុប្បន្នរបស់ចលនាសាច់ប្រាក់ នាពេលអនាគតដែលពាក់ពន្ធ័នឹងទ្រព្យសកម្មហិរញ្ញវត្ថុ (ឧ.ក្រុមហ៊ុនបានលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវជាសិទ្ធិពិសេស នៃការទិញមកវិញ នូវទ្រព្យសកម្មហិរញ្ញវត្ថុនោះ តាម *តម្លៃសមស្រប* នៅពេលទិញមកវិញឬបានផ្ទេរគ្រប់ចំនួននូវចំណែកនៃចលនាសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុយ៉ាងច្រើនតាមកិច្ចព្រមព្រៀង, ដូចជា ការចូលរួមថ្នាក់ក្រោមបំណុល, ដែលបំពេញបានតាមលក្ខខណ្ឌក្នុងកថាខណ្ឌ ៣.២.៥)។

៣.២.៨ វាជាការពិតណាស់ថា អង្គភាពបានផ្ទេរឬរក្សាទុកនូវរាល់ហានិភ័យ និងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ហើយមិនចាំបាច់ត្រូវធ្វើការគណនាណាមួយឡើយ។ ក្នុងករណីផ្សេងទៀត វាជាការចាំបាច់ ដើម្បីគណនា និងប្រៀបធៀបការប្រឈមនឹងហានិភ័យរបស់អង្គភាព ទៅនឹងវិបរិយាមក្នុងតម្លៃបច្ចុប្បន្ន នៃចលនាសាច់ប្រាក់សុទ្ធនាពេលអនាគត នៅមុនការផ្ទេរ និងក្រោយការផ្ទេរ។ ការគណនានិងការប្រៀបធៀបត្រូវបានធ្វើឡើង ដោយប្រើអត្រាការប្រាក់សមរម្យ ទៅនឹងអត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន។ រាល់វិបរិយាមភាពដែលអាចកើតមានដោយហេតុផលសមស្រប នៅក្នុងចលនាសាច់ប្រាក់សុទ្ធ ត្រូវបានពិចារណាដោយការថ្លឹងថ្លែងយ៉ាងម៉ត់ចត់ត្រូវបានផ្តល់ឲ្យ ចំពោះលទ្ធផលដែលអាចកើតឡើងទាំងនោះ។

៣.២.៩ អង្គភាព រក្សាទុកការគ្រប់គ្រង (មើល កថាខណ្ឌ៣.២.៦(គ)) លើទ្រព្យសកម្មបានផ្ទេរអាស្រ័យ លើលទ្ធភាពរបស់អ្នកទទួលការផ្ទេរ ដើម្បីលក់នូវទ្រព្យសកម្មនោះ។ ប្រសិនបើ អ្នកទទួលការផ្ទេរមានលទ្ធភាពជាក់ស្តែងដើម្បីលក់ទ្រព្យសកម្មទាំងស្រុង ដោយមិនឲ្យពាក់ពន្ធ័នឹងភាគីទីបី និងអាចប្រើលទ្ធភាពនោះ ដោយឯកតោភាគី និងដោយមិនចាំបាច់ដាក់ការបម្រាមបន្ថែមលើការផ្ទេរ, នោះអង្គភាពមិនមានការរក្សាទុកការគ្រប់គ្រងទេ។ក្នុងករណីផ្សេងទៀត, អង្គភាពរក្សាទុកការគ្រប់គ្រងលើទ្រព្យសកម្មហិរញ្ញវត្ថុនោះ។

## ការផ្ទេរដែលមានលក្ខណៈសម្បត្តិសម្រាប់ការមិនទទួលស្គាល់

៣.២.១០ ប្រសិនបើអង្គភាពផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងការ ផ្ទេរមួយដែលមានលក្ខណៈសម្បត្តិសម្រាប់ការមិនទទួលស្គាល់ទាំងស្រុង និងរក្សាទុកសិទ្ធិប្រើប្រាស់ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់បានកម្រៃ, អង្គភាពត្រូវទទួលស្គាល់ថាជាទ្រព្យសកម្មដែលផ្តល់សេវាកម្ម ឬបំណុលដែលផ្តល់សេវាកម្មសម្រាប់កិច្ចសន្យាផ្តល់សេវាកម្ម។ ប្រសិនបើប្រាក់កម្រៃដែលត្រូវបានទទួលមិនត្រូវបាន គេរំពឹងថាតបសងគ្រប់គ្រាន់ដល់អង្គភាពសម្រាប់ការធ្វើសេវាកម្ម, បំណុលដែលផ្តល់សេវាកម្មសម្រាប់ កាតព្វកិច្ចសេវាកម្មនឹងត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ប្រសិនបើ

ប្រាក់កម្រៃដែលត្រូវបានទទួលត្រូវបានគេរំពឹងថាបានតបស្នង លើសពីគ្រប់គ្រាន់ដល់អង្គភាពសម្រាប់ការធ្វើសេវាកម្ម, ទ្រព្យសកម្មដែលផ្តល់សេវាកម្មនឹងត្រូវបានទទួលស្គាល់សម្រាប់សិទ្ធិផ្តល់សេវាកម្មតាមបរិមាណមួយដែលបានកំណត់លើមូលដ្ឋាននៃការបែងចែកនៃតម្លៃលើបញ្ជីរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានតម្លៃច្រើនដោយយោងតាមកថាខណ្ឌ៣.២.១៣។

៣.២.១១ ប្រសិនបើ ដោយសារតែលទ្ធផលនៃការផ្ទេរ ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានគេទទួលស្គាល់ទាំងស្រុង ក៏ប៉ុន្តែ អង្គភាពទទួលបានទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ឬទទួលយកបំណុលហិរញ្ញវត្ថុ, ឬបំណុលដែលផ្តល់សេវាកម្ម,អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី បំណុលហិរញ្ញវត្ថុ ឬបំណុលដែលផ្តល់សេវាកម្មតាមតម្លៃសមស្រប។

៣.២.១២ ចំពោះការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងស្រុង, ភាពខុសគ្នារវាងៈ

(ក) បរិមាណទឹកប្រាក់លើបញ្ជី (វាស់វែងនៅថ្ងៃដែលមិនទទួលស្គាល់) និង

(ខ) ការតបសងដែលបានទទួល (រួមទាំងទ្រព្យសកម្មថ្មីនានាដែលបានទទួល ដកចេញ បំណុលថ្មីបានទទួលយក)នឹងត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

៣.២.១៣ ប្រសិនបើទ្រព្យសកម្មបានផ្ទេរគឺជាផ្នែកមួយនៃទ្រព្យសកម្មធំមួយ (ឧ. នៅពេលអង្គភាពផ្ទេរលំហូរសាច់ប្រាក់ជាការប្រាក់ ដែលជាផ្នែកនៃឧបករណ៍បំណុល, មើលកថាខណ្ឌ៣.២.២ (ក) ហើយផ្នែកដែលបានផ្ទេរមានលក្ខណៈសម្បត្តិ សម្រាប់ការមិនទទួលស្គាល់ទាំងស្រុង, បរិមាណទឹកប្រាក់លើបញ្ជីពីមុនរបស់ទ្រព្យសកម្មហិរញ្ញវត្ថុធំនឹងត្រូវបែងចែករវាងផ្នែកដែលត្រូវបន្តទទួលស្គាល់និងផ្នែកដែលមិនត្រូវបានទទួលស្គាល់ ដោយផ្អែកលើតម្លៃសមស្របរបស់ផ្នែកទាំងនោះនៅថ្ងៃដែលផ្ទេរ។ សម្រាប់គោលបំណងនេះ ទ្រព្យសកម្មផ្តល់សេវាកម្ម ដែលបានរក្សាទុកត្រូវបានចាត់ទុកថាជាផ្នែកមួយដែលត្រូវបន្តការទទួលស្គាល់។ ភាពខុសគ្នារវាង:

(ក) បរិមាណទឹកប្រាក់លើបញ្ជី (បានវាស់វែងនៅថ្ងៃ ដែលមិនទទួលស្គាល់) ដែលបានបែងចែកឲ្យផ្នែក ដែលមិនទទួលស្គាល់ និង

(ខ) ការតបសងដែលបានទទួលសម្រាប់ផ្នែកដែលមិនទទួលស្គាល់ (រួមទាំងទ្រព្យសកម្មថ្មីបានទទួលនិងបំណុលថ្មីបានទទួលយកផង) នឹងត្រូវទទួលស្គាល់ថាជាចំណេញ ឬខាត។

៣.២.១៤ នៅពេលអង្គភាពបែងចែកបរិមាណទឹកប្រាក់លើបញ្ជីពីមុនរបស់ទ្រព្យសកម្មហិរញ្ញវត្ថុធំរវាងផ្នែក ដែលត្រូវបន្តទទួលស្គាល់ និងផ្នែកមិនត្រូវបន្តទទួលស្គាល់, តម្លៃសមស្របនៃផ្នែកដែលត្រូវបន្តទទួលស្គាល់ត្រូវតែបានកំណត់ជាការចាំបាច់។ នៅពេលប្រវត្តិអង្គភាព នៃផ្នែកលក់ ដែលស្រដៀងគ្នាទៅនឹងផ្នែកដែលត្រូវបន្តទទួលស្គាល់ ឬប្រតិបត្តិការទីផ្សារផ្សេងទៀតបានកើតឡើងសម្រាប់ផ្នែកនោះ ថ្លៃថ្មីៗនៃប្រតិបត្តិការជាក់ស្តែងផ្តល់នូវការប៉ាន់ស្មានល្អបំផុតនៃតម្លៃសមស្របរបស់វា។

នៅពេលមិនមានសម្រង់ថ្លៃ ឬ ប្រតិបត្តិការទីផ្សារថ្មីៗដើម្បីគាំទ្រដល់តម្លៃសមស្រប នៃផ្នែកដែលត្រូវបន្តទទួលស្គាល់, ការប៉ាន់ស្គាល់,ការប៉ាន់ស្មានល្អបំផុតនៃតម្លៃសមស្រប គឺជាភាពខុសគ្នារវាងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុធំជាងទាំងស្រុងជាមួយនឹងការតបសងដែលបានទទួលពីអ្នកទទួលការ ផ្ទេរសម្រាប់ផ្នែកដែលមិនទទួលស្គាល់។

## ការផ្ទេរដែលមិនមានលក្ខណៈសម្បត្តិសម្រាប់ការទទួលស្គាល់

**៣.២.១៥ ប្រសិនបើការផ្ទេរមិនផ្តល់ជាលទ្ធផលនៃការមិនទទួលស្គាល់ដោយសារតែ អង្គភាពបានរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យនិងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរនោះទាំង**

ស្រុង និងត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុសម្រាប់ការតបសង ដែលបានទទួល។ នៅការិយបរិច្ឆេទជាបន្តបន្ទាប់ អង្គភាពត្រូវ ទទួលស្គាល់នូវចំណូលនានាដែលបានពីទ្រព្យសកម្មបានផ្ទេរនិង ចំណាយនានាដែលកើតឡើងដោយបំណុលហិរញ្ញវត្ថុ។

**ការពាក់ព័ន្ធជាបន្តនៅក្នុងទ្រព្យសកម្មបានផ្ទេរ**

៣.២.១៦ ប្រសិនបើអង្គភាពមិនផ្ទេរឬមិនរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យនិងផលចំណេញនៃការកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ហើយរក្សាទុកការគ្រប់គ្រងលើទ្រព្យសកម្មបានផ្ទេរ អង្គភាព ត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មបានផ្ទេរនោះទៅតាមកម្រិតនៃការពាក់ព័ន្ធជាបន្តរបស់ខ្លួន។ កម្រិតនៃការពាក់ព័ន្ធជាបន្តរបស់អង្គភាពនៅក្នុងទ្រព្យសកម្មបានផ្ទេរគឺជាកម្រិតដែលអង្គភាពត្រូវប្រឈមទៅនឹងបម្រែបម្រួលតម្លៃរបស់ទ្រព្យសកម្មបានផ្ទេរ។

ឧទាហរណ៍:

(ក) នៅពេលដែលការពាក់ព័ន្ធជាបន្តរបស់អង្គភាពមានទម្រង់ជាការធានាចំពោះទ្រព្យសកម្មបានផ្ទេរ, កម្រិតនៃការពាក់ព័ន្ធជាបន្តរបស់អង្គភាពគឺមានកម្រិតទាបជាង (១) បរិមាណទឹកប្រាក់របស់ទ្រព្យសកម្ម និង (២) បរិមាណទឹកប្រាក់អតិបរិមានៃការតបសងបានទទួល ដែលអង្គភាព អាចត្រូវបានតម្រូវឱ្យសងវិញ (“បរិមាណទឹកប្រាក់ធានា”)។

(ខ) នៅពេលដែលការពាក់ព័ន្ធជាបន្តរបស់អង្គភាពមានទម្រង់ជាសិទ្ធិពិសេសដែលបានទិញឬជាកិច្ចសន្យា (ឬទាំងពីរ) លើទ្រព្យសកម្មបានផ្ទេរ, កម្រិតនៃការពាក់ព័ន្ធជាបន្តរបស់អង្គភាពគឺ ជាបរិមាណទឹកប្រាក់របស់ទ្រព្យសកម្មបានផ្ទេរដែលអង្គភាពអាចទិញមកវិញ។ទោះជាយ៉ាងណា នៅក្នុងករណីជាសិទ្ធិពិសេសនៃការលក់តាមកិច្ចសន្យាលើទ្រព្យសកម្មមួយ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប, កម្រិតនៃការពាក់ពន្ធ័ជាបន្តរបស់អង្គភាពត្រូវបានកំណត់ត្រឹមតម្លៃទាបជាង នៃតម្លៃសមស្របរបស់ទ្រព្យសកម្មបានផ្ទេរនិងថ្លៃនៃការលក់សិទ្ធិពិសេស (មើល កថាខណ្ឌ ខ៣.២.១៣)។

(គ) នៅការពាក់ពន្ធ័ជាបន្តរបស់អង្គភាពមានទម្រង់ ជាសិទ្ធិពិសេសនៃការទូទាត់សាច់ប្រាក់ ឬលក្ខខណ្ឌស្រដៀងគ្នាលើទ្រព្យសកម្មបានផ្ទេរ, កម្រិតនៃការពាក់ពន្ធ័ជាបន្តរបស់អង្គភាពត្រូវបានវាស់វែងតាមរបៀបដូចគ្នាទៅនឹងការវាស់វែងដែលកើតចេញពីសិទ្ធិពិសេសនៃការទូទាត់មិនមែនសាច់ប្រាក់ ដូចបានកំណត់នៅក្នុង (ខ) ខាងលើ។

៣.២.១៧ នៅពេលអង្គភាពបន្តទទួលស្គាល់ទ្រព្យសកម្មមួយទៅតាមកម្រិតនៃការពាក់ពន្ធ័ជាបន្ត, អង្គភាពត្រូវទទួលស្គាល់ផងដែរនូវបំណុលដែលពាក់ពន្ធ័។ ទោះបីជាមានការតម្រូវលើការវាស់វែងផ្សេង

ទៀតនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះក៏ដោយ, ទ្រព្យសកម្មបានផ្ទេរ និងបំណុលពាក់ពន្ធ័ត្រូវបានវាស់វែងឈរលើមូលដ្ឋានដែលឆ្លុះបញ្ចាំងអំពីសិទ្ធិនិងកាតព្វកិច្ចដែលអង្គភាពត្រូវរក្សាទុក។ បំណុលពាក់ពន្ធ័ត្រូវវាស់វែងតាមរបៀបដែលថាតម្លៃលើបញ្ជីរបស់ទ្រព្យសកម្មបានផ្ទេរ និងបំណុលពាក់ព័ន្ធគឺជា:

(ក) ថ្លៃដើមដករំលស់របស់សិទ្ធិនិងកាតព្វកិច្ចដែលរក្សាទុកដោយអង្គភាព, ប្រសិនបើ ទ្រព្យសកម្មបានផ្ទេរត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់, ឬ

(ខ) ស្មើនឹងតម្លៃសមស្របរបស់សិទ្ធិនិងកាតព្វកិច្ច ដែលរក្សាទុកដោយអង្គភាពនៅពេលវាស់វែងតាមមូលដ្ឋានឯករាជ្យ, ប្រសិនបើទ្រព្យសកម្មបានផ្ទេរនោះត្រូវបានវាស់វែងតាមតម្លៃសមស្រប។

៣.២.១៨ អង្គភាព ត្រូវបន្តទទួលស្គាល់ចំណូលនានាដែលបានមកពីទ្រព្យសកម្មបានផ្ទេរទៅតាមកម្រិតនៃការពាក់ព័ន្ធជាបន្ត និងត្រូវទទួលស្គាល់ចំណាយដែលកើតឡើងដោយសារបំណុលពាក់ព័ន្ធ។

៣.២.១៩ សម្រាប់គោលបំណងនៃការវាស់វែងជាបន្តបន្ទាប់ទៀត, បម្រែបម្រួលដែលបានទទួលស្គាល់នៃតម្លៃសមស្របរបស់ទ្រព្យសកម្ម

បានផ្ទេរ និងបំណុលពាក់ព័ន្ធត្រូវបានកំណត់ដោយមានសង្គតិភាព ជាមួយគ្នាទៅវិញទៅមក ដោយអនុលោមតាមកថាខណ្ឌ៥.៧.១ និងមិនត្រូវទូទាត់រវាងគ្នាទៅវិញទៅមកឡើយ។

៣.២.២០ ប្រសិនបើ ការពាក់ពន្ធ័ជាបន្តរបស់អង្គភាពគឺគ្រាន់តែជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ឧ. នៅពេលអង្គភាពរក្សាទុកសិទ្ធិពិសេសសម្រាប់ការទិញមកវិញនូវផ្នែកមួយនៃទ្រព្យសកម្មបានផ្ទេរ, ឬរក្សាទុកភាគកម្មនៅសល់ដែលមិនឈានដល់ការរក្សាទុកយ៉ាងក្រាស់ក្រែលនូវរាល់ហានិភ័យ និងផលចំណេញនៃការកាន់កាប់ ហើយអង្គភាពរក្សាទុកការគ្រប់គ្រង), អង្គភាព ត្រូវបែងចែកតម្លៃលើបញ្ជីនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះជាផ្នែក ដែលខ្លួនត្រូវទទួលស្គាល់តាមកម្រិតនៃការពាក់ព័ន្ធ និងជាផ្នែកដែលខ្លួនលែងទទួលស្គាល់ដោយឈរលើមូលដ្ឋាននៃតម្លៃ សមស្របពាក់ព័ន្ធនាថ្ងៃដែលផ្ទេរ។ សម្រាប់គោលបំណងនេះការតម្រូវរបស់កថាខណ្ឌ ៣.២.១៤ ត្រូវតែអនុវត្ត។

ភាពខុសគ្នារវាងៈ

(ក) តម្លៃលើបញ្ជី (បានវាស់វែងនៅថ្ងៃដែលមិនទទួលស្គាល់) ដែលបានបែងចែកទៅផ្នែកដែលលែងទទួលស្គាល់ និង

(ខ) ការតបសងដែលបានទទួលសម្រាប់ផ្នែកដែលលែងទទួលស្គាល់ត្រូវទទួលស្គាល់ជាចំណេញឬខាត។

៣.២.១ ប្រសិនបើទ្រព្យសកម្មបានផ្ទេរត្រូវវាស់វែង តាមថ្លៃដើមដករំលស់, ជម្រើសនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ត្រូវចាត់ចែងកំណត់បំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត, មិនអាចអនុវត្តបានចំពោះបំណុលពាក់ព័ន្ធឡើយ។

ការផ្ទេរទាំងអស់

៣.២.២២ ប្រសិនបើទ្រព្យសកម្មបានផ្ទេរត្រូវបន្តទទួលស្គាល់, ទ្រព្យសកម្ម និងបំណុលពាក់ព័ន្ធមិនត្រូវទូទាត់គ្នាឡើយ។ ស្រដៀងគ្នានេះ, អង្គភាពមិនត្រូវទូទាត់ចំណូលណាមួយដែលបានមកពីទ្រព្យសកម្មបានផ្ទេរជាមួយចំណាយណាមួយដែលកើតចេញពីបំណុលពាក់ព័ន្ធឡើយ (មើលស្តង់ដាគណនេយ្យ ៣២ *ឧបករណ៍ហិរញ្ញវត្ថុ: ការដាក់បង្ហាញ* នៅកថាខណ្ឌ ៤២)។

៣.២.២៣ ប្រសិនបើអ្នកផ្ទេរផ្តល់ឱ្យនូវវត្ថុបញ្ចាំមិនមែនសាច់ប្រាក់ (ដូចជាឧបករណ៍បំណុល ឬទ្រព្យម្ចាស់) ទៅអ្នកទទួលការផ្ទេរ, ការកត់ត្រាគណនេយ្យសម្រាប់វត្ថុបញ្ចាំធ្វើឡើងដោយអ្នកផ្ទេរ និងអ្នកទទួលការផ្ទេរ អាស្រ័យលើថាតើ អ្នកទទួលការផ្ទេរមានសិទ្ធិលក់ ឬដាក់បញ្ចាំបន្តនូវវត្ថុបញ្ចាំនោះឬទេ និងថាតើ អ្នកផ្ទេរបានបោកប្រាស់ឬទេ។ អ្នកផ្ទេរ និងអ្នកទទួលការផ្ទេរត្រូវគណនាតម្លៃវត្ថុបញ្ចាំ ដូចខាងក្រោមៈ

(ក) ប្រសិនបើអ្នកទទួលការផ្ទេរមានសិទ្ធិតាមកិច្ចសន្យា ឬជាទំលាប់ដើម្បីលក់ឬដាក់បញ្ចាំបន្តនូវវត្ថុបញ្ចាំ, អ្នកផ្ទេរត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មនោះ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ឧ. ជាទ្រព្យសកម្មខ្ចី, ឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់បានដាក់បញ្ចាំ ឬបរិមាណត្រូវទទួលបានពីការទិញមកវិញ) ដាច់ដោយឡែកពីទ្រព្យសកម្មផ្សេងទៀត។

(ខ) ប្រសិនបើអ្នកទទួលការផ្ទេរលក់វត្ថុបញ្ចាំដែលបានដាក់បញ្ចាំទៅឲ្យខ្លួន, អ្នកផ្ទេរត្រូវទទួលស្គាល់ទឹកប្រាក់បានពីការលក់ នោះហើយបំណុលបានវាស់វែងតាមតម្លៃសមស្របសម្រាប់កាតព្វកិច្ចរបស់ខ្លួនដើម្បីបង្វិលឲ្យវិញនូវវត្ថុបញ្ចាំនោះ ។

(គ) ប្រសិនបើ អ្នកផ្ទេរបោកប្រាស់យោងតាមលក្ខខណ្ឌ នៃកិច្ចសន្យា ហើយលែងមានសិទ្ធិដើម្បីទទួលមកវិញនូវវត្ថុបញ្ចាំនោះ,អ្នកផ្ទេរមិនត្រូវទទួលស្គាល់នូវវត្ថុបញ្ចាំនោះទេ, ហើយអ្នកទទួលការផ្ទេរត្រូវទទួលស្គាល់វត្ថុបញ្ចាំនោះថាជាទ្រព្យសកម្មរបស់ខ្លួនដែលបានវាស់វែងពីដំបូងតាមតម្លៃសមស្រប ឬប្រសិនបើខ្លួនបានលក់រួចហើយនូវវត្ថុបញ្ចាំនោះ, មិនត្រូវទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួនដើម្បីបង្វិលវិញនូវវត្ថុបញ្ចាំនោះ។

(ឃ) លើកលែងករណីដូចមានចែងក្នុង (គ), អ្នកផ្ទេរត្រូវបន្តរក្សាទុកវត្ថុបញ្ចាំនោះថាជាទ្រព្យសកម្មរបស់ខ្លួន, ហើយអ្នកទទួលការផ្ទេរមិនត្រូវទទួលស្គាល់វត្ថុបញ្ចាំនោះថា ជាទ្រព្យសកម្មឡើយ។

## ៣.៣ ការមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ

៣.៣.១ អង្គភាពត្រូវដកចេញបំណុលហិរញ្ញវត្ថុ (ឬ ផ្នែកមួយនៃបំណុលហិរញ្ញវត្ថុ) ពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន នៅពេល និងតែនៅពេល បំណុលហិរញ្ញវត្ថុនោះលែងមានតទៅទៀត មានន័យថា កាតព្វកិច្ចបានចែងនៅក្នុងកិច្ចសន្យាត្រូវបានលុបចោល ឬត្រូវបានបោះបង់ចោល ឬផុតកាលកំណត់។

៣.៣.២ ការដោះដូររវាងអ្នកខ្ចីនិងអ្នកឲ្យខ្ចីបច្ចុប្បន្ន នៃឧបករណ៍បំណុលដែលមានលក្ខខណ្ឌខុសគ្នាខ្លាំងត្រូវចាត់ទុកថាជាការលុបចោលបំណុលហិរញ្ញវត្ថុដើមដំបូង និងជាការទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។ ស្រដៀងគ្នានេះ ការកែប្រែជាដុំកំភួននៃលក្ខខណ្ឌរបស់បំណុលហិរញ្ញវត្ថុបច្ចុប្បន្ន ឬផ្នែកមួយនៃបំណុលហិរញ្ញវត្ថុនោះ (ទោះបីជាវាអាចចាត់ទុកថាជាការលំបាកផ្នែកហិរញ្ញវត្ថុរបស់កូនបំណុល) ត្រូវចាត់ទុកថាជាការលុបចោលនូវបំណុលហិរញ្ញវត្ថុដើមដំបូង និងជាការទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។

**៣.៣.៣ ភាពខុសគ្នារវាងតម្លៃលើបញ្ជីនៃបំណុលហិរញ្ញវត្ថុ (ឬ ផ្នែកមួយនៃបំណុលហិរញ្ញវត្ថុ) ដែលបានរំលាយចោល ឬបានផ្ទេរទៅភាគីមួយទៀត និងការតបសងបានបង់, រួមមានទាំងទ្រព្យសកម្មមិនមែនសាច់ប្រាក់បានផ្ទេរ ឬបំណុលបានទទួលយក, ត្រូវទទួលស្គាល់ជាចំណេញ ឬការខាតបង់។**

៣.៣.៤ ប្រសិនបើ អង្គភាពទិញមកវិញផ្នែកមួយ នៃបំណុលហិរញ្ញវត្ថុ, អង្គភាព ត្រូវបែងចែកបរិមាណលើបញ្ជីរបស់បំណុលហិរញ្ញវត្ថុទៅជាផ្នែក ដែលត្រូវបន្តទទួលស្គាល់និងផ្នែកដែលលែងត្រូវទទួលស្គាល់ ដោយផ្អែកលើតម្លៃសមស្រប នៃផ្នែកបំណុលហិរញ្ញវត្ថុទាំងនោះនៅកាលបរិច្ឆេទនៃការទិញមកវិញ។ភាពខុសគ្នារវាង (ក) បរិមាណលើបញ្ជីបានបែងចែកទៅផ្នែកដែលលែងទទួលស្គាល់ និង (ខ) ការតបសងដែលបានបង់, រួមមានទាំងទ្រព្យសកម្ម មិនមែនសាច់ប្រាក់បានផ្ទេរ ឬបំណុលបានទទួលយក, សម្រាប់ផ្នែកដែលលែងទទួលស្គាល់ត្រូវទទួលស្គាល់ថាជាចំណេញ ឬ ការខាតបង់។

## ៤.១ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

៤.១.១ ដរាបណា កថាខណ្ឌ ៤.១.៥ អនុវត្តន៍, អង្គភាពត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ ដូចបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ឬតាមតម្លៃសមស្រប ដោយផ្អែកលើមូលដ្ឋានទាំងពីរខាងក្រោមៈ

(ក) ម៉ូឌែលអាជីវកម្មរបស់អង្គភាព សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និង

(ខ) ចរិតលក្ខណៈនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

៤.១.២ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវវាស់វែងតាមតម្លៃដករំលស់ ប្រសិនបើលក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបំពេញៈ

(ក) ទ្រព្យសកម្ម ដែលមាននៅក្នុងម៉ូឌែលអាជីវកម្មមានគោល-បំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា

(ខ) លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់ឱ្យនៅកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលត្រូវទូទាត់តែម្តងគត់ទាំងប្រាក់ដើម និងការប្រាក់តាមបរិមាណប្រាក់ដើមនៅជំពាក់។

កថាខណ្ឌ ១៨.១.១-កថាខណ្ឌ ១៨.១.២៦ ផ្តល់ការណែនាំអំពីរបៀបនៃការអនុវត្តលក្ខខណ្ឌទាំងនេះ។

៤.១.៣ ក្នុងគោលបំណងអនុវត្ត កថាខណ្ឌ ៤.១.២(ខ), ការប្រាក់គឺជាការតបសងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់សម្រាប់រយៈពេលមួយ និងសម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ។

៤.១.៤ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវវាស់វែងតាមតម្លៃសមស្រប ដរាបណាវាត្រូវវាស់វែងតាមតម្លៃដករំលស់ ដោយយោងតាម កថាខណ្ឌ ៤.១.២។

**ជម្រើសដើម្បីកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ តាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញឬខាត**

៤.១.៥ ទោះបីយ៉ាងណា កថាខណ្ឌ៤.១.១-កថាខណ្ឌ៤.១.៤, នៅពេលដែលទទួលស្គាល់លើកដំបូង អង្គភាពមួយអាចកំណត់ដោយមិនអាចដកយកមកវិញបាននូវទ្រព្យសកម្មហិរញ្ញវត្ថុ ដូចបានវាស់វែងតាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញ ឬខាត ក្នុងករណីធ្វើបែបនោះនឹងលុបបំបាត់ចោលឬបន្ថយជាដុំកំភួននូវការវាស់វែង ឬ ការទទួលស្គាល់ដោយមិនមានសង្គតិភាព (ពេលខ្លះសំដៅដល់ "ការផ្ទុយផ្គងមិនត្រូវគ្នាផ្នែកគណនេយ្យ") ដែលនឹង

**កើតចេញពីការវាស់វែងទ្រព្យសកម្មឬបំណុល ឬការទទួលស្គាល់ចំណេញឬខាតលើទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ ដោយឈរលើមូលដ្ឋានផ្សេងៗគ្នា (មើល កថាខណ្ឌ ខ៤.១.២៩--ខ៤.១.៣២)។**

៤.១.៦ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ *ឧបករណ៍ហិរញ្ញវត្ថុៈ ការលាតត្រដាងព័ត៌មាន* តម្រូវឱ្យអង្គភាព ផ្តល់នូវការលាតត្រដាងព័ត៌មាន អំពីទ្រព្យសកម្មហិរញ្ញវត្ថុដែលខ្លួនមានដែលបានកំណត់តាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញឬខាត។

## ៤.២ ការធ្វើចំណាត់ថ្នាក់បំណុលហិរញ្ញវត្ថុ

**៤.២.១ អង្គភាពត្រូវធ្វើចំណាត់ថ្នាក់រាល់បំណុលហិរញ្ញវត្ថុទាំងអស់ បន្ទាប់ពីត្រូវបានវាស់វែងតាមតម្លៃដករំលស់ ដោយប្រើអត្រាការប្រាក់ជាក់ស្តែង លើកលែងតែ:**

**(ក) *បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របដែលកើតឡើង ដោយប្រតិបត្តិការចំណេញឬខាត*។បំណុលទាំងនោះរួមមាននិស្សន្ទ ដែលជាបំណុល, នឹងត្រូវវាស់វែងជាបន្តបន្ទាប់ទៀតតាមតម្លៃសមស្រប។**

**(ខ) បំណុលហិរញ្ញវត្ថុដែលកើតឡើង នៅពេលដែលការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុមិនមានលក្ខណៈសម្បត្តិ សម្រាប់ការមិនទទួលស្គាល់ ឬនៅពេលអនុវត្តនូវវិធីសាស្ត្រ នៃ**

ការពាក់ព័ន្ធបន្ត។ កថាខណ្ឌ៣.២.១៥ និង កថាខណ្ឌ ៣.២.១៧ អនុវត្តចំពោះការវាស់វែងបំណុលហិរញ្ញវត្ថុបែបនោះ។

(គ) *កិច្ចសន្យាធានាហិរញ្ញវត្ថុ*ត្រូវបានកំណត់អត្ថន័យនៅក្នុងឧបសម្ព័ន្ធ (ក)។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង អ្នកចេញផ្សាយកិច្ចសន្យាធានាហិរញ្ញវត្ថុត្រូវ(ដរាបណាអនុវត្ត កថាខណ្ឌ៤.២.១(ក) ឬ (ខ)) វាស់វែងជាបន្តបន្ទាប់ទៀតនូវកិច្ចសន្យានោះតាមតម្លៃខ្ពស់ជាងនេះ:

(១) បរិមាណទឹកប្រាក់បានកំណត់ ដោយយោងតាមស្តង់ដា គណនេយ្យអន្តរជាតិ ៣៧ *សំវិធានធន, បំណុលយ ថាហេតុ និងទ្រព្យសកម្មយថាហេតុ* និង

(២) បរិមាណទឹកប្រាក់បានទទួលស្គាល់លើកដំបូង (មើល កថាខណ្ឌ ៥.១.១) ដក, នៅពេលសមស្រប, រំលស់បង្គរ ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ១៨ *ចំណូល*។

(ឃ) ការសន្យាផ្តល់ប្រាក់កម្ចីតាមអត្រាការប្រាក់ទាបជាងទីផ្សារ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង អ្នកផ្តល់នូវកិច្ចសន្យាផ្តល់ប្រាក់កម្ចីត្រូវ (ដរាបណា អនុវត្ត កថាខណ្ឌ ៤.២.១(ក)

ឬ (ខ)) វាស់វែងជាបន្តបន្ទាប់ទៀតនូវកិច្ចសន្យានោះតាមតម្លៃខ្ពស់ជាងនេះ:

(១) បរិមាណទឹកប្រាក់បានកំណត់ ដោយយោងតាមស្តង់ដា គណនេយ្យអន្តរជាតិ ៣៧ និង

(២) បរិមាណទឹកប្រាក់បានទទួលស្គាល់លើកដំបូង (មើលកថាខណ្ឌ ៥.១.១) ដក, នៅពេលសមស្រប, រំលស់បង្គរ ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ១៨។

**ជម្រើសដើម្បីកំណត់បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្រប តាមប្រតិបត្តិការចំណេញឬខាត**

៤.២.២ ខណៈពេលនៃការទទួលស្គាល់លើដំបូង អង្គភាពអាចកំណត់ជាស្ថាពរនូវបំណុលហិរញ្ញវត្ថុមួយដោយវាស់វែងតាមតម្លៃសមស្រប តាមរយៈប្រតិបត្តិការចំណេញ ឬខាត នៅពេលដែលត្រូវបានអនុញ្ញាតិដោយកថាខណ្ឌ៤.៣.៥, ឬនៅពេលធ្វើដូច្នោះ បង្កើតឲ្យមាននូវព័ត៌មានពាក់ពន្ធ័កាន់តែច្រើនឡើង ដោយសារតែ:

(ក) វាលុបបំបាត់ចោលឬបន្ថយជាដុំកំភួននូវការវាស់វែង ឬភាពមិនមានសង្គតិភាពនៃការទទួលស្គាល់ (ជួនកាលសំដៅដល់ "ការផ្ទុរផ្គងមិនត្រឹមត្រូវផ្នែកគណនេយ្យ") ដែលអាចកើតមានឡើងដោយការវាស់វែងទ្រព្យសកម្មឬ បំណុល

ឬ ការទទួលស្គាល់ចំណេញនិងខាត ដោយការវាស់វែង ដែលមានមូលដ្ឋានខុសគ្នា ឬ

(ខ) ក្រុមនៃបំណុលហិរញ្ញវត្ថុ ឬទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង ហើយលទ្ធផលរបស់វា ត្រូវបានវាយតម្លៃដោយផ្អែកលើតម្លៃសមស្រប, ដោយ យោងតាមការគ្រប់គ្រងហានិភ័យ ឬយុទ្ធសាស្ត្រវិនិយោគ ដែលបានរៀបចំ, និងព័ត៌មានស្តីពីក្រុមនោះត្រូវបានផ្តល់ ឲ្យពីខាងក្នុងដោយផ្អែកលើមូលដ្ឋាននោះទៅឲ្យអ្នកគ្រប់គ្រង សំខាន់របស់អង្គភាព (ដូចបានកំណត់នៅក្នុងស្តង់ដា គណនេយ្យអន្តរជាតិ ២៤ *ការលាតត្រដាងព័ត៌មានរបស់ ភាគីពាក់ព័ន្ធ )* ឧទាហរណ៍ ក្រុមប្រឹក្សាភិបាលរបស់អង្គភាព និងនាយកប្រតិបត្តិ។

៤.២.៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ តម្រូវឲ្យ អង្គភាព ផ្តល់ការលាតត្រដាងព័ត៌មានដែលខ្លួនបានកំណត់ថាជា តម្លៃសមស្រប តាមរយៈប្រតិបត្តិការចំណេញ ឬខាត។

## ៤.៣ និសន្ទវត្ថុបង្កប់

៤.៣.១ និសន្ទវត្ថុបង្កប់គឺជាសមាសធាតុនៃកិច្ចសន្យា ដែលមានលក្ខណៈ ទ្វេ ដែលរួមមានទាំងបាហានិកមិនមែនជានិសន្ទវត្ថុ ជាមួយនឹង ផលប៉ះពាល់ដែលលំហូរសាច់ប្រាក់ខ្លះនៃឧបករណ៍ផ្គួបប្រែប្រួល

តាមរបៀបមួយស្រដៀងទៅនឹង និសន្យន្ទដាច់ដោយឡែកមួយ។ និសន្យន្ទបង្កប់បណ្ដាលឲ្យលំហូរសាច់ប្រាក់ខ្លះឬទាំងអស់ដែលនឹងត្រូវតម្រូវដោយកិច្ចសន្យា នឹងត្រូវកែប្រែដោយយោងទៅតាមអត្រាការប្រាក់ជាក់លាក់មួយ, ថ្លៃឧបករណ៍ហិរញ្ញវត្ថុ, ថ្លៃកុំម៉ូឌីធី, អត្រាប្ដូរប្រាក់, សន្ទស្សន៍ថ្លៃឬអត្រា, ចំណាត់ថ្នាក់ឥណទាន ឬសន្ទស្សន៍ឥណទាន, ឬអថេរផ្សេងទៀត ដែលបានផ្ដល់ឲ្យនៅក្នុងករណីជានិស្សន្ទ មិនមែនហិរញ្ញវត្ថុ ដែលអថេរមិនបានកំណត់ជាក់លាក់ចំពោះភាគីមួយនៃកិច្ចសន្យា។ និសន្យន្ទដែលភ្ជាប់នឹងឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែវាអាចផ្ទេរបានតាមកិច្ចសន្យា ដោយមិនចំណុះឧបករណ៍ហិរញ្ញវត្ថុនោះ, ឬមានសមភាគីផ្សេងគ្នា, មិនមែនជានិសន្យន្ទបង្កប់ឡើយ, ប៉ុន្តែ គឺជាឧបករណ៍ហិរញ្ញវត្ថុដាច់ដោយឡែក។

**កិច្ចសន្យាមានលក្ខណៈទ្វេរដែលមានបាហានិកជាទ្រព្យសកម្មហិរញ្ញវត្ថុ**

**៤.៣.២ ប្រសិនបើ កិច្ចសន្យាមានលក្ខណៈទ្វេររួមមានបាហានិកមួយគឺជាទ្រព្យសកម្មដែលស្ថិតនៅក្នុងវិសាលភាពរបស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, អង្គភាពត្រូវអនុវត្តការតម្រូវនៅក្នុងកថាខណ្ឌ ៤.១.១-៤.១.៥ចំពោះកិច្ចសន្យា ដែលមានលក្ខណៈទ្វេរទាំងមូល។**

### កិច្ចសន្យាមានលក្ខណៈទ្វេរផ្សេងទៀត

៤.៣.៣ ប្រសិនបើកិច្ចសន្យាមានលក្ខណៈទ្វេររួមមានបាហនិក មួយមិនមែនជាទ្រព្យសកម្មដែលស្ថិតនៅក្នុងវិសាលភាពរបស់ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ, និស្សន្ទបង្កប់ត្រូវតែញែកចេញពីបាហនិកនោះ ហើយចាត់ទុកថាជានិស្សន្ទមួយតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ក្នុងករណីដែល និងតែក្នុងករណីដែលៈ

(ក) ចរិតលក្ខណៈសេដ្ឋកិច្ចនិងហានិភ័យរបស់និស្សន្ទបង្កប់មិនមានទំនាក់ទំនងជិតស្និទ្ធទៅនឹងចរិតលក្ខណៈសេដ្ឋកិច្ច និងហានិភ័យរបស់បាហនិក (មើល កថាខណ្ឌ ខ៤.៣.៥ និង ខ៤.៣.៨)

(ខ) ឧបករណ៍ហិរញ្ញវត្ថុ ដាច់ដោយឡែកមួយ ដែលមានលក្ខខណ្ឌដូចគ្នាជាមួយនឹងនិសន្យន្ទបង្កប់ត្រូវនឹងនិយមន័យនៃ និស្សន្ទ, និង

(គ) កិច្ចសន្យាមានលក្ខណៈទ្វេរ មិនត្រូវបានវាស់វែងតាមតម្លៃសមស្របជាមួយនឹងការដោះដូរនៅក្នុងតម្លៃសមស្របដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត (មានន័យថា ជានិស្សន្ទដែលបង្កប់នៅក្នុងបំណុលហិរញ្ញវត្ថុ

តាមតម្លៃលើបញ្ជីតាមរយៈប្រតិបត្តិការចំណេញ ឬខាត មិនត្រូវបានញែកចេញពីគ្នាឡើយ)។

៤.៣.៤ ប្រសិនបើនិសន្ទវត្ថុបង្កប់ដាច់ដោយឡែកពីគ្នា, កិច្ចសន្យាបាហនិក ត្រូវតែបានកំណត់ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសមស្រប។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះមិនសង្កត់ធ្ងន់ថាតើនិសន្ទវត្ថុបង្កប់ត្រូវដាក់បង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឬទេ។

៤.៣.៥ ទោះបីមានចែងក្នុងកថាខណ្ឌ៤.៣.៣ និង កថាខណ្ឌ៤.៣.៤, ប្រសិនបើកិច្ចសន្យាមួយរួមមាននិសន្ទវត្ថុបង្កប់មួយ ឬច្រើន ហើយបាហនិកមិនមែនជាទ្រព្យសកម្មស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ, អង្គភាពអាចកំណត់កិច្ចសន្យាដែលមានលក្ខណៈទ្វេរ នោះតាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញ ឬខាតនៅចុងការិយបរិច្ឆេទ ដរាបណា៖

(ក) និសន្ទវត្ថុបង្កប់មិនធ្វើឱ្យមានការកែប្រែជាដុំកំភួនលំហូរសាច់ប្រាក់ដែលបានតម្រូវដោយកិច្ចសន្យា ឬ

(ខ) វាមានភាពច្បាស់លាស់តិចតួច ឬមិនមានការវិភាគ នៅពេលដែលមានឧបករណ៍មានលក្ខណៈទ្វេរស្រដៀងគ្នានេះ

ត្រូវបានពិចារណាពីដំបូងថា ភាពដាច់ដោយឡែកពីគ្នានៃនិសន្ទវត្ថុបង្កប់ត្រូវបានហាមឃាត់, ឧទាហរណ៍ដូចជា ជម្រើសនៃការទូទាត់សងមុនដែលបានបង្កប់នៅក្នុងប្រាក់កម្ចីដែលអនុញ្ញាតិឱ្យអ្នកកាន់កាប់សងមុននូវប្រាក់កម្ចីសម្រាប់តម្លៃដកវិលស់សមរម្យរបស់ខ្លួន។

៤.៣.៦ ប្រសិនបើអង្គភាពមួយត្រូវបានតម្រូវដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ដើម្បីញែកបំបែកនិសន្ទវត្ថុបង្កប់ពីបាហនិករបស់វា ប៉ុន្តែមិនអាចវាស់វែងបានដាច់ដោយឡែកពីគ្នានូវនិសន្ទវត្ថុបង្កប់ទាំងនៅពេលទិញ ឬទាំងនៅចុងការិយបរិច្ឆេទនៃការរាយការណ៍ហិរញ្ញវត្ថុបន្ទាប់, អង្គភាពត្រូវកំណត់កិច្ចសន្យាដែលមានលក្ខណៈទ្វេរនេះតាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញឬខាតនៅចុងការិយបរិច្ឆេទ។

៤.៣.៧ ប្រសិនបើអង្គភាពមិនអាចមានលទ្ធភាពកំណត់បាន ដោយអាចទុកចិត្តបាននូវតម្លៃសមស្របរបស់និសន្ទវត្ថុបង្កប់ដោយឈរលើលក្ខខណ្ឌនានា របស់ខ្លួនបាន, តម្លៃសមស្របរបស់និសន្ទវត្ថុបង្កប់គឺជាភាពខុសគ្នារវាងតម្លៃសមស្របរបស់កិច្ចសន្យា ដែលមានលក្ខណៈទ្វេរ និងតម្លៃសមស្របរបស់បាហនិក, ប្រសិនបើកិច្ចសន្យា ដែលមានលក្ខណៈទ្វេរនិងបាហនិក អាចត្រូវបានកំណត់តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ។ ប្រសិនបើ អង្គភាពមិនអាចមានលទ្ធភាពកំណត់នូវតម្លៃ

របស់និសន្ទុ្យន្ទបង្កប់ ដោយប្រើវិធីសាស្ត្រនេះ, អង្គភាព ត្រូវអនុវត្តកថាខណ្ឌ ៤.៣.៦ ហើយ កិច្ចសន្យាដែលមានលក្ខណៈទ្វេរនេះ ត្រូវបានកំណត់តម្លៃសមស្រប តាមរយៈប្រតិបត្តិការចំណេញឬខាតនៅចុងការិយបរិច្ឆេទ។

## ៤.៤ ការធ្វើចំណាត់ថ្នាក់ឡើងវិញ

**៤.៤.១ នៅពេលដែល និងតែនៅពេលដែល អង្គភាពផ្លាស់ប្តូរម៉ូឌែលអាជីវកម្មរបស់ខ្លួនសម្រាប់ការគ្រប់គ្រងទ្រព្យសកម្ម ហិរញ្ញវត្ថុ អង្គភាពត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវរាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលទទួលផលប៉ះពាល់ ដោយអនុលោម តាមកថាខណ្ឌ ៤.១.១-កថាខណ្ឌ៤.១.៤។**

**៤.៤.២ អង្គភាពមិនត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវបំណុលហិរញ្ញវត្ថុណាមួយឡើយ។**

៤.៤.៣ ការផ្លាស់ប្តូរកាលៈទេសៈខាងក្រោម មិនមែនជាការចាត់ថ្នាក់ឡើងវិញសម្រាប់គោលបំណងនៃកថាខណ្ឌ ៤.៤.១ និង កថាខណ្ឌ ៤.៤.២ ឡើយ:

(ក) និសន្ទុ្យន្ទ ដែលពីមុនគឺជាឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលបានកំណត់ទុកនិងជាក់ស្តែងនៅក្នុងការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់ ឬការទប់ស្កាត់ហានិភ័យវិនិយោគសុទ្ធលែងមានលក្ខណៈសម្បត្តិបែបនោះទៀត។

(ខ) និសន្យន្ទបានក្លាយជាឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលបានកំណត់ទុកនិងជាក់ស្តែងនៅក្នុងការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់ឬការទប់ស្កាត់ហានិភ័យវិនិយោគសុទ្ធ។

## **ជំពូកទី៥ ការវាស់វែង**

## **៥.១ ការវាស់វែងលើកដំបូង**

---

៥.១.១ នៅខណៈពេលនៃការទទួលស្គាល់លើកដំបូង, អង្គភាពត្រូវវាស់វែង ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្រប (មើល កថាខណ្ឌ៥.៤.១ -កថាខណ្ឌ៥.៤.៣ និង កថាខណ្ឌ ខ៥.៤.១-កថាខណ្ឌ ខ៥.៤.១៧) បូក ឬដក, ក្នុងករណីទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុមិនវាស់វែងតាមតម្លៃសមស្រប តាមរយៈប្រតិបត្តិការចំណេញ ឬខាត, *ចំណាយប្រតិបត្តិការ* ដែលកំណត់ថាពាក់ពន្ធ័នឹងការទិញ ឬការចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ។

៥.១.២ នៅពេលដែលអង្គភាពប្រើគណនេយ្យនាកាលបរិច្ឆេទទូទាត់សម្រាប់ទ្រព្យសកម្មដែលពេលក្រោយមកត្រូវបានវាស់តាមតម្លៃដើមដករំលស់, ទ្រព្យសកម្មនោះ ត្រូវបានទទួលស្គាល់ជាលើកដំបូងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញដូរនោះ។

## ៥.២ ការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ

៥.២.១ នៅខណៈពេលនៃការទទួលស្គាល់លើកដំបូង, អង្គភាពត្រូវវាស់វែងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដោយយោងតាមកថាខណ្ឌ ៤.១.១-កថាខណ្ឌ៤.១.៥ តាមតម្លៃសមស្រប (មើលកថាខណ្ឌ ៥.៤.១ កថាខណ្ឌ ៥.៤.២ និង កថាខណ្ឌ ខ៥.៤.១-កថាខណ្ឌ ខ៥.៤.១៧) ឬតាមតម្លៃដើមដករំលស់ (មើលកថាខណ្ឌ ៩ និង កថាខណ្ឌ AG5-AG8 នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)។

៥.២.២ អង្គភាពត្រូវអនុវត្តតាមការតម្រូវសម្រាប់ការធ្លាក់ចុះតម្លៃនៅក្នុងកថាខណ្ឌ៨៩-កថាខណ្ឌ១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃដករំលស់។

៥.២.៣ អង្គភាព ត្រូវអនុវត្តការតម្រូវ សម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យនៅក្នុង កថាខណ្ឌ៨៩-កថាខណ្ឌ១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកំណត់ថាជាធាតុទប់ស្កាត់ហានិភ័យ (មើលកថាខណ្ឌ៧៨-កថាខណ្ឌ៨៤ និង កថាខណ្ឌ AG98-AG101 នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩)។

## ៥.៣ ការវាស់វែងជាបន្តបន្ទាប់នៃបំណុលហិរញ្ញវត្ថុ

៥.៣.១ បន្ទាប់ពីការទទួលស្គាល់លើកដំបូង, អង្គភាពត្រូវវាស់វែងតម្លៃបំណុលហិរញ្ញវត្ថុដោយយោងតាម កថាខណ្ឌ៤.២.១-កថាខណ្ឌ៤.២.២ (មើល កថាខណ្ឌ៥.៤.១-កថាខណ្ឌ៥.៤.៣ និង កថាខណ្ឌខ៥.៤.១-កថាខណ្ឌខ៥.៤.១៧ និង កថាខណ្ឌ AG5-AG8 នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)។

៥.៣.២ អង្គភាព ត្រូវអនុវត្តការតម្រូវសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យនៅក្នុង កថាខណ្ឌ៨៩-កថាខណ្ឌ១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ ចំពោះបំណុលហិរញ្ញវត្ថុដែលបានកំណត់ថាជាធាតុទប់ស្កាត់ហានិភ័យ (មើលកថាខណ្ឌ៧៨-កថាខណ្ឌ៨៤ និងកថាខណ្ឌ AG98-AG101 នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩)។

## ៥.៤ ការវាស់វែងតម្លៃសមស្រប

៥.៤.១ ក្នុងការកំណត់តម្លៃសមស្របរបស់ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ សម្រាប់គោលបំណង នៃការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, ស្តង់ដាគណនេយ្យ អន្តរជាតិ ៣២, ស្តង់ដាគណនេយ្យអន្តរជាតិ៣៩ ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៧, អង្គភាពត្រូវអនុវត្តកថាខណ្ឌ ខ៥.៤.១-កថាខណ្ឌខ៥.៤.១៧។

៥.៤.២ ភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្របគឺថ្លៃបានធ្វើសម្រង់នៅក្នុងទីផ្សារសកម្ម។ ប្រសិនបើ ទីផ្សារសម្រាប់ឧបករណ៍ហិរញ្ញវត្ថុមិនមែនជាទីផ្សារសកម្ម, អង្គភាពត្រូវបង្កើតតម្លៃសមស្រប ដោយប្រើបច្ចេកទេសនៃការវាយតម្លៃ។ គោលបំណងនៃការប្រើបច្ចេក-ទេសវាយតម្លៃ គឺដើម្បីបង្កើតនូវអ្វីដែលថ្លៃប្រតិបត្តិការនឹងកើតមាននាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងការដោះដូរធម្មតាដែលជម្រុញទឹកចិត្ត ដោយការតបសង នៃអាជីវកម្មធម្មតាមួយ។ បច្ចេទេស នៃការវាយតម្លៃរួមមាន ការប្រើប្រតិបត្តិការទីផ្សារធម្មតាថ្មីៗដែលកើតឡើងរវាងបណ្តាភាគីដែលមានឆន្ទះ និងមានការយល់ដឹង ប្រសិនបើមាន, ការយោងទៅតម្លៃសមស្របបច្ចុប្បន្នរបស់ឧបករណ៍ផ្សេងទៀតដែលមានភាពដូចគ្នា, ការវិភាគលំហូរសាច់ប្រាក់ដែលបានធ្វើអប្បហារ, និងម៉ូឌែលកំណត់ថ្លៃសិទ្ធិពិសេស។ ប្រសិនបើ មានបច្ចេកទេសនៃការវាយតម្លៃដែលត្រូវបានប្រើជាទូទៅដោយអ្នកចូលរួមនៅក្នុងទីផ្សារ ដើម្បីកំណត់ថ្លៃឧបករណ៍នោះ និងបច្ចេកទេសដែលបានបង្ហាញ ដើម្បីផ្តល់ឲ្យនូវ ការប៉ាន់ស្មានថ្លៃ ដែលអាចជឿទុកចិត្តបាន ដែលបានទទួលបានពីប្រតិបត្តិការទីផ្សារជាក់ស្តែង, អង្គភាពប្រើបច្ចេកទេសនោះ។

បច្ចេកទេសនៃការវាយតម្លៃដែលបានជ្រើសរើសធ្វើការប្រើប្រាស់ជាអតិបរមានូវធាតុចូលរបស់ទីផ្សារ និងពឹងផ្អែកលើធាតុចូលពី

អង្គភាពឲ្យបានតិចបំផុត។ វាត្រូវរួមបញ្ចូលនូវរាល់កត្តាទាំងអស់ ដែលអ្នកចូលរួមនៅក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ និងមានសង្គតិភាពជាមួយវិធីសាស្ត្រប្រែបបសេដ្ឋកិច្ច ដែលបានទទួលយកសម្រាប់ការកំណត់ថ្លៃឧបករណ៍ហិរញ្ញវត្ថុ។ ជួនពេលខ្លះ អង្គភាពធ្វើព្យាសកម្មបច្ចេកទេសនៃការវាយតម្លៃ និងតេស្តវាសម្រាប់រកសុពលភាពក្នុងការប្រើសម្រាប់កំណត់ថ្លៃពីប្រតិបត្តិការទីផ្សារបច្ចុប្បន្ន ដែលអាចអង្កេតបានសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលដូចគ្នា (មានន័យថា មិនមានការកែប្រែ ឬរៀបចំឡើងវិញអ្វីទាំងអស់) ឬផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន ដែលមានណាមួយ។

៥.៤.៣ តម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលមានលក្ខណៈនៃលក្ខខណ្ឌតម្រូវ (ដូចជា ប្រាក់បញ្ញើតាមកាលកំណត់) មានតម្លៃមិនតិចជាងបរិមាណត្រូវបង់តាមការតម្រូវ, ដែលបានអប្បហារតាំងពីកាលបរិច្ឆេទដំបូង ដែលបរិមាណនោះអាចត្រូវបានតម្រូវឲ្យបង់សង។

## ៥.៥ ការវាស់វែងតាមតម្លៃដករំលស់--មិនប្រើទៀតទេ

## ៥.៦ ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ

៥.៦.១ ប្រសិនបើអង្គភាពធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដោយយោងតាមកថាខណ្ឌ៤.៤.១, អង្គភាពត្រូវអនុវត្តតទៅថ្ងៃមុខនូវការធ្វើចំណាត់ថ្នាក់ឡើងវិញដោយគិតចាប់តាំងពីកាលបរិច្ឆេទនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ។ អង្គភាពមិនត្រូវចែងឡើងវិញនូវចំណេញ, ការខាតបង់ ឬការប្រាក់ ដែលបានទទួលស្គាល់ពីមុនឡើយ។

៥.៦.២ ប្រសិនបើ, ដោយយោងតាមកថាខណ្ឌ ៤.៤.១, អង្គភាពធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលខ្លួនបានវាស់វែងតាមតម្លៃសមស្រប, តម្លៃសមស្របរបស់វាត្រូវបានកំណត់នាកាលបរិច្ឆេទនៃការវាយតម្លៃឡើងវិញ។ ចំណេញ ឬខាតណាមួយដែលកើតឡើងពីភាពខុសគ្នារវាងតម្លៃលើបញ្ជីពីមុននិងតម្លៃសមស្របត្រូវទទួលស្គាល់ជាចំណេញឬខាតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៥.៦.៣ ប្រសិនបើ, ដោយយោងតាមកថាខណ្ឌ៤.៤.១, អង្គភាពធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុដែលខ្លួនបានវាស់វែងតាមតម្លៃដករំលស់, តម្លៃសមស្របរបស់វានាកាលបរិច្ឆេទនៃការវាយតម្លៃឡើងវិញក្លាយជាតម្លៃលើបញ្ជីថ្មី។

## ៥.៧ ចំណេញ និង ការខាតបង់

៥.៧.១ ចំណេញ ឬការខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របត្រូវទទួលស្គាល់ជាចំណេញ ឬការខាតបង់ ដរាបណា៖

(ក) វាជាផ្នែកមួយនៃទំនាក់ទំនងនៃការទប់ស្កាត់ហានិភ័យ (មើល កថាខណ្ឌ ៨៩-១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)

(ខ) វាគឺជាការវិនិយោគមួយនៅក្នុង *ឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់* ហើយអង្គភាពបានជ្រើសរើសបង្ហាញចំណេញ និងការខាតបង់លើការវិនិយោគនោះនៅក្នុងប្រាក់ចំណូលបន្ទាប់បន្សំផ្សេងៗ ដោយយោងតាមកថាខណ្ឌ ៥.៧.៥ ឬ

(គ) វាគឺជាបំណុលហិរញ្ញវត្ថុដែលបានកំណត់តាមតម្លៃសមស្រប តាមរយៈប្រតិបត្តិការចំណេញ ឬខាតនៅចុងការិយបរិច្ឆេទហើយអង្គភាពត្រូវបានតម្រូវឱ្យបង្ហាញផលប៉ះពាល់នៃការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់បំណុលនោះនៅក្នុងចំណូលបន្ទាប់បន្សំផ្សេងៗទៀត ដោយយោងតាមកថាខណ្ឌ ៥.៧.៧។

៥.៧.២ ចំណេញឬការខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃដករំលស់ ហើយដែលមិនមែនជាផ្នែកមួយនៃទំនាក់

ទំនងសម្រាប់ការទប់ស្កាត់ហានិភ័យ (មើល កថាខណ្ឌ៨៩-១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩) ត្រូវទទួលស្គាល់ជាចំណេញ ឬការខាតបង់ នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុនោះមិនត្រូវបានមិនទទួលស្គាល់, មានការធ្លាក់ចុះតម្លៃ, ឬត្រូវបានធ្វើចំណាត់ថ្នាក់ ឡើងវិញ ដោយយោងតាមកថាខណ្ឌ ៥.៦.២, និងតាមរយៈដំណើរការនៃការដករំលស់ ។ ចំណេញ ឬ ការខាតបង់លើបំណុល ហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃដករំលស់ ហើយដែលមិនមែនជាផ្នែកមួយនៃទំនាក់ទំនងសម្រាប់ការទប់ស្កាត់ហានិភ័យ (មើល កថាខណ្ឌ៨៩-១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩) ត្រូវទទួលស្គាល់ជាចំណេញឬការខាតបង់ នៅពេលដែលបំណុលហិរញ្ញវត្ថុនោះត្រូវបានមិនទទួលស្គាល់ និង តាមរយៈដំណើរការ នៃការដករំលស់ ។

៥.៧.៣ ចំណេញ ឬការខាតបង់ លើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលជាធាតុសម្រាប់ទប់ស្កាត់ហានិភ័យ (មើល កថាខណ្ឌ៧៨- កថាខណ្ឌ៨៤ និង AG៩៨ - AG101 នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩) ត្រូវទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ៨៩-១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩។

៥.៧.៤ ប្រសិនបើអង្គភាពទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដោយប្រើគណនេយ្យនាកាលបរិច្ឆេទនៃការទូទាត់ (មើល កថាខណ្ឌ៣.១.២ និងកថាខណ្ឌខ៣.១.៣ និងកថាខណ្ឌ៣.១.៦), បម្រែបម្រួល

ណាមួយនៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្មដែលត្រូវទទួលនៅក្នុងអំឡុងពេលរវាងកាលបរិច្ឆេទនៃការជួញដូរ និងកាលបរិច្ឆេទនៃការទូទាត់មិនត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មដែលវាស់វែងតាមតម្លៃដករំលស់ឡើយ (លើកលែងតែការខាតបង់ដោយការធ្លាក់ចុះតម្លៃ)។ ក៏ប៉ុន្តែ សម្រាប់ទ្រព្យសកម្មដែលវាស់វែងតាមតម្លៃសមស្រប,បម្រែបម្រួលណាមួយនៅក្នុងតម្លៃសមស្របត្រូវទទួលស្គាល់ថាជាចំណេញឬការខាតបង់ពីសកម្មភាពប្រតិបត្តិការ ឬទទួលស្គាល់នៅក្នុងចំណូលបន្ទាប់បន្សំផ្សេងៗ, តាមភាពសមស្រប, យោងតាម កថាខណ្ឌ៥.៧.១។

***ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់***

៥.៧.៥ នៅខណៈពេលនៃការទទួលស្គាល់លើកដំបូង, អង្គភាពអាចធ្វើការជ្រើសរើសជាស្ថាពរដើម្បីបង្ហាញនូវចំណូលបន្ទាប់បន្សំផ្សេងទៀតបន្ទាប់ពីការផ្លាស់ប្តូរតម្លៃសមស្របនៃការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ដែលមិនមែន*រក្សាទុកសម្រាប់ការជួញដូរ*។

៥.៧.៦ ប្រសិនបើ អង្គភាពធ្វើការជ្រើសរើសដូចក្នុង កថាខណ្ឌ ៥.៧.៥, អង្គភាពត្រូវទទួលស្គាល់ជាចំណេញ ឬខាតនូវភាគលាភ ដែលបានពីការវិនិយោគនោះនៅពេលដែលសិទ្ធិរបស់អង្គភាព ដើម្បី

ទទួលបាននូវការទូទាត់ភាគលាភត្រូវបានបង្កើតឡើងដោយយោង តាមស្តង់ដាគណនេយ្យអន្តរជាតិ ១៨។

**បំណុលដែលបានកំណត់ថាមានតម្លៃសមស្របនៅចុងការិយបរិច្ឆេទ**

៥.៧.៧ អង្គភាពត្រូវបង្ហាញចំណេញឬខាតពីបំណុលហិរញ្ញវត្ថុ ដែលបានកំណត់ថាមានតម្លៃសមស្របនៅចុងការិយបរិច្ឆេទ ដូចខាងក្រោមៈ

(ក) បរិមាណនៃការប្រែប្រួលនៃតម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលនាំទៅដល់ការប្រែប្រួល នៃហានិភ័យឥណទានរបស់បំណុលនោះ ត្រូវតែបង្ហាញនៅក្នុងផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ (មើល កថាខណ្ឌ ខ៥.៧.១៣ - កថាខណ្ឌ ខ៥.៧.២០) និង

(ខ) បរិមាណនៅសល់នៃការប្រែប្រួលនៃតម្លៃសមស្រប របស់បំណុលត្រូវតែបង្ហាញនៅក្នុងផ្នែកចំណេញ ឬខាត។

ដរាបណាប្រព្រឹត្តិកម្មនៃផលប៉ះពាល់របស់ការប្រែប្រួលនៅក្នុងហានិភ័យឥណទានរបស់បំណុលដែលមានបរិយាយនៅក្នុង (ក) នឹងបង្កើតឬធ្វើឲ្យរីកធំនូវភាពមិនស៊ីគ្នានៃគណនេយ្យនៅក្នុងផ្នែកចំណេញខាត (ដែលក្នុងករណីនេះ កថាខណ្ឌ៥.៧.៨ ត្រូវតែអនុវត្ត)។ កថាខណ្ឌខ៥.៧.៥--កថាខណ្ឌខ៥.៧.៧ និង កថាខណ្ឌខ៥.៧.១០--កថាខណ្ឌខ៥.៧.១២ ផ្តល់នូវការណែនាំអំពីរបៀប

**នៃកការកំណត់ភាពមិនស៊ីគ្នានៃគណនេយ្យ ដែលអាចត្រូវបាន បង្កើតឡើង ឬធ្វើឱ្យរីកធំ។**

**៥.៧.៨ ប្រសិនបើការតម្រូវនានានៅក្នុងកថាខណ្ឌ ៥.៧.៧ នឹងបង្កើតឱ្យ មាន ឬធ្វើឱ្យរីកធំនូវភាពមិនស៊ីគ្នានៃគណនេយ្យ នៅក្នុងផ្នែក ចំណេញឬខាត, អង្គភាពត្រូវបង្ហាញនូវរាល់ចំណេញ ឬការខាត បង់ទាំងអស់នៅបំណុលនោះ (រួមទាំង ផលប៉ះពាល់នៃការប្រែ ប្រួលនៅក្នុងហានិភ័យឥណទានរបស់បំណុលនោះផងដែរ) នៅ ក្នុងផ្នែកចំណេញឬខាត។**

៥.៧.៩ ទោះបីជាមានការតម្រូវនៅក្នុង កថាខណ្ឌ៥.៧.៧ និងកថាខណ្ឌ ៥.៧.៨, អង្គភាពត្រូវបង្ហាញនៅក្នុងផ្នែកចំណេញ ឬខាតនូវរាល់ ចំណេញ និងការខាតបង់នានាពីកាតព្វកិច្ចបំណុល និងកិច្ចសន្យា ធានាហិរញ្ញវត្ថុដែលត្រូវបានកំណត់ថាមានតម្លៃសមស្របនៅចុង ការិយបរិច្ឆេទ។

## ជំពូកទី៦ គណនេយ្យទប់ស្កាត់ហានិភ័យ– *មិនប្រើទៀតទេ*

## ជំពូកទី៧ កាលបរិច្ឆេទចូលជាធរមាននិងអន្តរកាល

### ៧.១ កាលបរិច្ឆេទចូលជាធរមាន

៧.១.១ អង្គភាពត្រូវអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ការអនុវត្តន៍មុនត្រូវបានអនុញ្ញាតិ។ ក៏ប៉ុន្តែ ប្រសិនបើអង្គភាពជ្រើសរើសអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះមុន ហើយមិនទាន់បានអនុវត្ត ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩ ដែលបានចេញផ្សាយនៅឆ្នាំ២០០៩, អង្គភាព ត្រូវអនុវត្តនូវរាល់ការតម្រូវនានានៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ នៅក្នុងពេលតែមួយ (ប៉ុន្តែមើលកថាខណ្ឌ ៧.៣.២ផង)។ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅមុនថ្ងៃទី១ ខែមករា ឆ្នាំ២០១៣, អង្គភាពត្រូវលាតត្រដាងនូវព័ត៌មាននោះ ហើយនៅពេលជាមួយគ្នានេះ អនុវត្តការកែប្រែនានានៅក្នុងឧបសម្ពន្ធ គ។

## ៧.២ អន្តរកាល

៧.២.១ អង្គភាពត្រូវអនុវត្តស្តង់ដា របាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះដោយប្រតិសកម្ម, ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៨ *គោលនយោបាយគណនេយ្យបម្រែបម្រួលនៅក្នុងការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង,* លើកលែងតែបានបញ្ជាក់នៅក្នុង កថាខណ្ឌ ៧.២.៤ - កថាខណ្ឌ ៧.២.១៥។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ មិនត្រូវអនុវត្តចំពោះធាតុទាំងឡាយណា ដែលលែងត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង។

៧.២.២ សម្រាប់គោលបំណងអន្តរកាលនៅក្នុង កថាខណ្ឌ៧.២.១ និង កថាខណ្ឌ ៧.២.៣ - កថាខណ្ឌ ៧.២.១៦, កាលបរិច្ឆេទនៃការអនុវត្តលើកដំបូង គឺជាកាលបរិច្ឆេទដែលអង្គភាពអនុវត្តជាលើកដំបូងនូវបណ្តាការតម្រូវនានារបស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។ កាលបរិច្ឆេទនៃការអនុវត្តលើកដំបូងអាចជាៈ

(ក) កាលបរិច្ឆេទណាមួយ រវាងការចេញផ្សាយស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ និងកាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០, សម្រាប់អង្គភាព អនុវត្តជាលើកដំបូងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះនៅមុនថ្ងៃទី១ ខែមករា ឆ្នាំ២០១១ឬ

(ខ) ពេលដើមគ្រា នៃការិយបរិច្ឆេទរាយការណ៍ លើកដំបូង ដែលអង្គភាពចាប់ផ្ដើមប្រើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, សម្រាប់អង្គភាពអនុវត្តជាលើកដំបូងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះនៅថ្ងៃទី ឬ ក្រោយថ្ងៃទី១ខែមករា ឆ្នាំ២០១១

៧.២.៣ ប្រសិនបើ កាលបរិច្ឆេទនៃការអនុវត្តលើកដំបូង មិនមែនជាពេលដើមគ្រានៃការិយបរិច្ឆេទរាយការណ៍, អង្គភាពត្រូវលាតត្រដាងព័ត៌មាននោះ និងហេតុផលនៃការប្រើកាលបរិច្ឆេទអនុវត្តលើកដំបូងនេះ។

៧.២.៤ នៅកាលបរិច្ឆេទ នៃការអនុវត្តលើកដំបូង អង្គភាពត្រូវវាយតម្លៃមើលថា តើទ្រព្យសកម្មហិរញ្ញវត្ថុឆ្លើយតបទៅនឹងលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ៤.១.២(ក)ដោយផ្អែកលើព័ត៌មាន និងកាលៈទេសៈដែលកើតឡើងនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង។ ការធ្វើចំណាត់ថ្នាក់ដែលមានលទ្ធផលត្រូវតែអនុវត្តជាប្រតិសកម្មដោយមិនគិតដល់ម៉ូឌែលអាជីវកម្មរបស់អង្គភាព នៅមុនការិយបរិច្ឆេទរាយការណ៍ឡើយ។

៧.២.៥ ប្រសិនបើ អង្គភាពវាស់វែងតម្លៃកិច្ចសន្យាដែលមានលក្ខណៈទ្វេរតាមតម្លៃសមស្របដោយអនុលោមតាមកថាខណ្ឌ ៤.១.៤ ឬ កថាខណ្ឌ៤.១.៥ ប៉ុន្តែតម្លៃសមស្របនៃកិច្ចសន្យា ដែលមាន

លក្ខណៈទ្វេរនេះមិនទាន់ត្រូវបានកំណត់នៅក្នុងការិយបរិច្ឆេទ - រាយការណ៍ប្រៀបធៀបនៅឡើយ, តម្លៃសមស្របនៃកិច្ចសន្យាដែលមានលក្ខណៈទ្វេរនៅក្នុងការិយបរិច្ឆេទរាយការណ៍ ត្រូវតែជាចំនួនសរុបនៃតម្លៃសមស្របរបស់សមាសធាតុនោះ (មានន័យថាជា បាហនិកមិនមែននិសន្សន្ទនិងនិសន្សន្ទបង្កប់) នៅចុងការិយបរិច្ឆេទរាយការណ៍ប្រៀបធៀបនីមួយៗ។

៧.២.៦ នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូងអង្គភាពត្រូវទទួលស្គាល់នូវភាពខុសគ្នារវាងតម្លៃសមស្របនៃកិច្ចសន្យា ដែលមានលក្ខណៈទ្វេរទាំងមូលនាកាលបរិច្ឆេទនៃការអនុវត្តលើកដំបូងនិងបរិមាណសរុប នៃតម្លៃសមស្របរបស់សមាសធាតុនៃកិច្ចសន្យា ដែលមានលក្ខណៈទ្វេរ នាកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង:

(ក) នៅក្នុងប្រាក់ចំណេញរក្សាទុកដើមគ្រានៃការិយបរិច្ឆេទរាយការណ៍នៃការអនុវត្តលើកដំបូង ប្រសិនបើអង្គភាពអនុវត្តជាលើកដំបូងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះនៅពេលចាប់ផ្តើមនៃការិយបរិច្ឆេទរាយការណ៍ ឬ

(ខ) នៅក្នុងផ្នែកចំណេញឬខាត ប្រសិនបើអង្គភាពអនុវត្តជាលើកដំបូងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះនៅក្នុងអំឡុងពេលនៃការិយបរិច្ឆេទរាយការណ៍។

៧.២.៧ នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង អង្គភាពអាចកំណត់:

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុ ថាបានវាស់វែង តាមតម្លៃសមស្រប នាកាលបរិច្ឆេទចុងគ្រា ដោយអនុលោមតាម កថាខណ្ឌ ៤.១.៥ ឬ

(ខ) ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ តាមតម្លៃសមស្របនៅក្នុងប្រាក់ចំណេញបន្ទាប់បន្សំ ដោយយោងតាមកថាខណ្ឌ៥.៧.៥។

ការកំណត់បែបនេះនឹងត្រូវធ្វើឡើងដោយផ្អែកលើព័ត៌មាន និងកាលៈទេសៈដែលកើតឡើងនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង។ ការធ្វើចំណាត់ថ្នាក់នោះត្រូវអនុវត្តជាប្រតិសកម្ម។

៧.២.៨ នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង អង្គភាព:

(ក) ត្រូវលុបចោលនូវការកំណត់ពីមុនរបស់ខ្លួននូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃសមស្របនាចុងការិយបរិច្ឆេទ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុនោះមិនឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុង កថាខណ្ឌ៤.១.៥

(ខ) អាចលុបចោលនូវការកំណត់ពីមុនរបស់ខ្លួននូវទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របនាចុងការិយបរិច្ឆេទ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុនោះឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុងកថាខណ្ឌ៤.១.៥ ។

ការលុបចោលបែបនេះត្រូវតែធ្វើឡើងដោយផ្អែកលើព័ត៌មាននិង កាលៈទេសៈដែលកើតឡើងនៅកាលបរិច្ឆេទ នៃការអនុវត្តលើក ដំបូង។ ការធ្វើចំណាត់ថ្នាក់នោះត្រូវអនុវត្តជាប្រតិសកម្ម។

៧.២.៩ នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង អង្គភាពៈ

(ក) អាចកំណត់បំណុលហិរញ្ញវត្ថុថាបានវាស់វែងតាមតម្លៃសម ស្របនាកាលបរិច្ឆេទចុងគ្រាដោយអនុលោមតាមកថាខណ្ឌ ៤.១.២(ក)

(ខ) ត្រូវលុបចោលនូវការកំណត់ពីមុនរបស់ខ្លួន នូវបំណុល ហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃសមស្របនាចុង ការិយបរិច្ឆេទ ប្រសិនបើការកំណត់នោះបានធ្វើឡើង នៅ ខណៈពេលនៃការទទួលស្គាល់លើកដំបូងដោយយោងតាម លក្ខខណ្ឌដែលឥឡូវនេះមាននៅក្នុងកថាខណ្ឌ៤.២.២ (ក) និងការកំណត់នោះមិនឆ្លើយតបទៅនឹងលក្ខខណ្ឌនៅកាល បរិច្ឆេទនៃការអនុវត្តលើកដំបូង។

(គ) អាចលុបចោល នូវការកំណត់ពីមុនរបស់ខ្លួននូវបំណុល ហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃសមស្របនាចុង ការិយបរិច្ឆេទ ប្រសិនបើការកំណត់នោះបានធ្វើឡើង នៅ ខណៈណាពេលនៃការទទួលស្គាល់លើកដំបូងដោយយោង តាមលក្ខខណ្ឌដែលឥឡូវនេះមាននៅក្នុងកថាខណ្ឌ៤.២.២

(ក)និងការកំណត់នោះឆ្លើយតបទៅនឹងលក្ខខណ្ឌនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង។

ការកំណត់និងការលុបចោលបែបនេះត្រូវតែធ្វើឡើងដោយផ្អែកលើព័ត៌មាននិងកាលៈទេសៈដែលកើតឡើងនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង ។ ការធ្វើចំណាត់ថ្នាក់នោះត្រូវអនុវត្តជាប្រតិសកម្ម។

៧.២.១០ ប្រសិនបើវាមិនអាចអនុវត្តបាន (ដូចបានកំណត់នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ៨) សម្រាប់អង្គភាពអនុវត្តជាប្រតិសកម្មនូវវិធីសាស្ត្រអត្រាការប្រាក់ជាក់ស្តែង ឬការតម្រូវសម្រាប់ការធ្លាក់ចុះតម្លៃ នៅក្នុងកថាខណ្ឌ៥៨-កថាខណ្ឌ៦៥ និង AG៨៤-AG៩៣នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩, អង្គភាពត្រូវចាត់ទុកតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅចុងការិយបរិច្ឆេទប្រៀបធៀបនីមួយៗថាជាថ្លៃដើមដករំលស់។នៅក្នុងកាលៈទេ - សៈនោះតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុនៅកាលបរិ - ច្ឆេទ នៃការអនុវត្តលើកដំបូងត្រូវតែចាត់ទុកថាជាថ្លៃដើមដករំលស់ថ្មី របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះនៅកាលបរិច្ឆេទ នៃការអនុវត្តលើកដំបូងនៃស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះ។

៧.២.១១ ប្រសិនបើ អង្គភាពកំណត់តម្លៃការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ ដែលមិនមានសម្រង់ថ្លៃ (ឬទ្រព្យសកម្មនិសន្ទ្ធទុលបានភ្ជាប់ទៅនឹងហើយដែលត្រូវតែទូទាត់ ដោយឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ ដែលមិនមានសម្រង់ថ្លៃ) តាមថ្លៃដើម ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៣៩, អង្គភាពត្រូវវាស់វែងឧបករណ៍ហិរញ្ញវត្ថុនោះ តាមតម្លៃសមស្របនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង។ភាពខុសគ្នាណាមួយរវាងតម្លៃលើបញ្ជីពីមុននិងតម្លៃសមស្របត្រូវទទួលស្គាល់ នៅក្នុងផ្នែកប្រាក់ចំណេញរក្សាទុកដើមគ្រានៃការិយបរិច្ឆេទរាយការណ៍ដែលរួមមានកាលបរិច្ឆទនៃការអនុវត្តលើកដំបូង។

៧.២.១២ ប្រសិនបើ អង្គភាពកំណត់តម្លៃបំណុលនិសន្ទ្ធ ដែលបានភ្ជាប់ទៅនឹង ហើយដែលត្រូវតែទូទាត់ ដោយឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់តាមថ្លៃដើម ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៣៩, អង្គភាពត្រូវវាស់វែងបំណុលនិសន្ទ្ធនោះ តាមតម្លៃសមស្របនៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង ។ ភាពខុសគ្នាណាមួយរវាងតម្លៃលើបញ្ជីពីមុននឹងតម្លៃសមស្រប ដែលត្រូវទទួលស្គាល់នៅក្នុងផ្នែកប្រាក់ចំណេញរក្សាទុកដើមគ្រា នៃការិយបរិច្ឆេទរាយការណ៍ដែលរួមមានកាលបរិច្ឆទនៃការអនុវត្តលើកដំបូង។

៧.២.១៣ នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង អង្គភាពត្រូវកំណត់ថា តើប្រព្រឹត្តិកម្មនៅក្នុង កថាខណ្ឌ ៥.៧.៧ នឹងបង្កើត ឬធ្វើឲ្យរីកធំនូវភាពមិនស៊ីគ្នានៃគណនេយ្យនៅក្នុងផ្នែកចំណេញឬខាត ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មាន និងកាលៈទេសៈដែលកើតមាន នៅកាលបរិច្ឆេទនៃការអនុវត្តលើកដំបូង ។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ត្រូវអនុវត្តជាប្រតិសកម្មនៅលើមូលដ្ឋាននៃការកំណត់នោះ។

៧.២.១៤ ទោះបីជាមានការតម្រូវនៅក្នុងកថាខណ្ឌ ៧.២.១, អង្គភាពដែលប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះសម្រាប់បណ្តាការិយបរិច្ឆេទរាយការណ៍ មុនថ្ងៃទី១ ខែមករា ឆ្នាំ២០១២ មិនចាំបាច់ចែងឡើងវិញ នូវរបាយការណ៍សម្រាប់ការិយបរិច្ឆេទមុនៗឡើយ។ ប្រសិនបើ អង្គភាពមិនចែងឡើងវិញនូវរបាយការណ៍សម្រាប់ការិយបរិច្ឆេទមុនៗ អង្គភាពត្រូវទទួលស្គាល់ភាពខុសគ្នារវាងតម្លៃលើបញ្ជីពីមុន និងតម្លៃលើបញ្ជីនៅដើមការិយបរិច្ឆេទរាយការណ៍ដែលរួមបញ្ចូលទាំងកាលបរិច្ឆេទនៃការអនុវត្តលើកដំបូងនៅក្នុងផ្នែកប្រាក់ចំណេញរក្សាទុកដើមគ្រា ( ឬសមាសធាតុផ្សេងទៀតនៃទ្រព្យម្ចាស់, តាមតែការសមស្រប ) នៃការិយបរិច្ឆេទរាយការណ៍ដែលបញ្ចូលទាំងកាលបរិច្ឆេទនៃការអនុវត្តលើកដំបូងផងដែរ ។ ប៉ុន្តែ ប្រសិនបើ អង្គភាពចែងឡើងវិញរបាយការណ៍ហិរញ្ញវត្ថុគ្រាមុនៗ,របាយការ-

ណ៍ហិរញ្ញវត្ថុដែលបានចែងឡើងវិញនោះ ត្រូវតែឆ្លុះបញ្ចាំងរាល់ការតម្រូវនានា នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ។

៧.២.១៥ ប្រសិនបើអង្គភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្នុងចន្លោះពេលដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣៤ *ការរាយការណ៍ហិរញ្ញវត្ថុក្នុងចន្លោះពេល* អង្គភាពមិនចាំបាច់អនុវត្តតាមការតម្រូវនានានៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ចំពោះការិយបរិច្ឆេទក្នុងចន្លោះពេល មុនកាលបរិច្ឆេទនៃការអនុវត្តលើកដំបូងឡើយ ប្រសិនបើមិនអាចអនុវត្តបាន ( ដូចបានកំណត់នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៨)។

**អង្គភាពដែលអនុវត្តមុននូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩ ដែលបានចេញផ្សាយនៅ ឆ្នាំ២០០៩**

៧.២.១៦ អង្គភាពត្រូវអនុវត្តតាមការតម្រូវអន្តរកាលនៅក្នុងកថាខណ្ឌ ៧.២.១-កថាខណ្ឌ៧.២.១៥ តាមកាលបរិច្ឆេទពាក់ព័ន្ធនៃការអនុវត្តលើកដំបូង ។ ម៉្យាងទៀត អង្គភាពត្រូវអនុវត្ត កថាខណ្ឌ ៧.២.៤-កថាខណ្ឌ ៧.២.១១ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៩ (បានចេញផ្សាយនៅឆ្នាំ២០០៩) ឬដោយមិនបានធ្វើដូច្នេះ នៅពេលអង្គភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៩( បាន

ចេញផ្សាយនៅឆ្នាំ២០១០) ទាំងស្រុង។ អង្គភាព មិនត្រូវបាន អនុញ្ញាតិឲ្យអនុវត្តកថាខណ្ឌទាំងនោះច្រើនជាមួយឡើយ។

## ៧.៣ ការដកចេញ IFRIC 9 និងIFRS 9 (2009)

៧.៣.១ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះជំនួស IFRIC9 *ការវាយតម្លៃឡើងវិញនិសន្ទវត្ថុបង្កប់* ។ ការតម្រូវនានា បានបន្ថែមទៅលើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៩ នៅខែតុលា ឆ្នាំ២០១០ ដោយរួមបញ្ចូលជាមួយគ្នានូវការតម្រូវនានាដែលបានកំណត់ពីមុននៅក្នុងកថាខណ្ឌ៥ និងកថា-ខណ្ឌ៧ នៃIFRI 9។ តាមការកែប្រែជាបន្តបន្ទាប់ទៀត ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១ *ការប្រើលើកដំបូងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* បានរួមបញ្ចូលការតម្រូវនានា ដែលបានកំណត់ពីមុននៅក្នុងកថាខណ្ឌ៨ នៃ IFRIC 9 ។

៧.៣.២ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះជំនួសស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៩ ដែលបានចេញផ្សាយនៅឆ្នាំ២០០៩ ។ ប៉ុន្តែ សម្រាប់ការចាប់ផ្តើមការិយ-បរិច្ឆេទប្រចាំឆ្នាំ មុនថ្ងៃទី១ ខែមករា ឆ្នាំ២០១៣, អង្គភាពអាចជ្រើសរើសអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ

ជាតិ៩ ដែលបានចេញផ្សាយនៅឆ្នាំ២០០៩ ជំនួសឲ្យការ អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។

## ឧបសម្ព័ន្ធ
## អត្ថន័យនៃពាក្យ

*ឧបសម្ពន្ធ័នេះ គឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិ*

**ការមិនទទួលស្គាល់** ការដកចេញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលបានទទួលស្គាល់ពីមុនចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

និសន្ទវត្ថុ ឧបករណ៍ហិរញ្ញវត្ថុឬកិច្ចសន្យាផ្សេងៗដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ (មើល កថាខណ្ឌ២.១) ដោយភ្ជាប់មកជាមួយនូវចរិតលក្ខណៈបីដូចខាងក្រោមៈ

- តម្លៃរបស់វាប្រែប្រួលដោយឆ្លើយតបទៅនឹងការប្រែប្រួល នៃអត្រាការប្រាក់ជាក់លាក់មួយ, ថ្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ, ថ្លៃរបស់កុំម៉ូឌីធី, អត្រាប្តូរប្រាក់បរទេស, សន្ទស្សន៍ថ្លៃឬអត្រាថ្លៃ, ចំណាត់ថ្នាក់ឥណទាន ឬសន្ទស្សន៍ឥណទាន, ឬ

[1] កថាខណ្ឌ៥.៤.២-កថាខណ្ឌ៥.៤.៣ និងកថាខណ្ឌ ខ៥.៤.១ –កថាខណ្ឌ ខ៥.៤.១៧ រួមមានការតម្រូវនានាសម្រាប់កំណត់តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ។

អថេរផ្សេងទៀត ដែលផ្តល់ឲ្យក្នុងករណីជាអថេរមិនមែនហិរញ្ញវត្ថុដែលអថេរនោះមិនបានបញ្ជាក់ចំពោះភាគីនៃកិច្ចសន្យា (ជួនកាលហៅថា "ជាមូលដ្ឋាន")។

- វាមិនតម្រូវឲ្យមានការវិនិយោគដំបូង ឬការវិនិយោគដំបូង ដែលមានបរិមាណតិចជាងបរិមាណដែលនឹងត្រូវតម្រូវសម្រាប់ប្រភេទនៃកិច្ចសន្យាផ្សេងទៀត ដែលត្រូវបានរំពឹងថាមានការឆ្លើយតបស្រដៀងគ្នា ចំពោះបម្រែបម្រួលនៅក្នុងកត្តាទីផ្សារ។
- វាត្រូវទូទាត់នាពេលអនាគត។

**តម្លៃសមស្រប** តម្លៃដែលទ្រព្យសកម្មមួយអាចត្រូវបានដោះដូរ, ឬបំណុលមួយ ត្រូវបានទូទាត់រវាងភា គីដែលមានឆន្ទៈនិងការយល់ដឹងនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា*។

កិច្ចសន្យាធានាហិរញ្ញវត្ថុកិច្ចសន្យាដែលតម្រូវឲ្យអ្នកចេញផ្សាយឧបករណ៍ហិរញ្ញវត្ថុធ្វើការទូទាត់សងណាមួយទៅឲ្យអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ការខាតបង់ ដែលកើតឡើងដោយសារតែកូនបំណុលណាមួយមិនបានធ្វើ

ការទូទាត់សងនៅពេលដល់កំណត់សងយោងតាមលក្ខខណ្ឌដើម ឬលក្ខខណ្ឌបានកែប្រែនៃឧបករណ៍ហិរញ្ញវត្ថុបំណុល។

**បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របនៅចុងកាលបរិច្ឆេទ**

បំណុលហិរញ្ញវត្ថុដែលបំពេញបានតាមលក្ខខណ្ឌមួយដូចខាងក្រោមៈ

(ក) វាបំពេញបាននិយមន័យនៃ**ការរក្សាទុកសម្រាប់ការជួញដូរ**។

(ខ) នៅខណៈពេល នៃការទទួលស្គាល់លើកដំបូង វាត្រូវបានកំណត់ទុក ដោយអង្គភាពថា មានតម្លៃសមស្របនៅចុងកាលបរិច្ឆេទដោយអនុលោមតាមកថាខណ្ឌ៤.២.២ ឬ ៤.៣.៥។

**ការរក្សាទុកសម្រាប់ការជួញដូរ**

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ ដែលៈ

(ក) ត្រូវបានទិញឬកើតឡើងមានគោលការណ៍ចំបងសម្រាប់ការលក់ឬការទិញមកវិញ នៅក្នុងរយៈពេលដ៏ខ្លី

(ខ) ការទទួលស្គាល់លើកដំបូងគឺជាផ្នែកមួយនៃក្រុមឧបករណ៍ហិរញ្ញវត្ថុស្រដៀងគ្នា ដែលត្រូវបានគ្រប់គ្រងរួមគ្នា និងដែលមានភស្តុតាងអំពីបែបផែនជាក់

ស្តែងនៃការទាញយកប្រាក់ចំណេញរយៈពេលខ្លី ឬ (គ)ជានិស្សន្ទ (លើកលែងតែនិស្សន្ទដែលជាកិច្ចសន្យាធានាហិរញ្ញវត្ថុឬជាឧបករណ៍សម្រាប់ទប់ស្កាត់ហានិភ័យដែលបានកំណត់ទុក ឬជាក់ស្តែង)។

**កាលបរិច្ឆេទនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ**

ថ្ងៃទីមួយ នៃការិយបរិច្ឆេទរាយការណ៍លើកដំបូងបន្ទាប់ពីការផ្លាស់ប្តូរ ម៉ូឌែលអាជីវកម្ម ដែលធ្វើឱ្យអង្គភាព ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ។

**ការទិញឬលក់តាមរបៀបធម្មតា**

ការទិញឬការលក់ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុតាមកិច្ចសន្យាមួយ ដែលលក្ខខណ្ឌតម្រូវឱ្យប្រគល់ទ្រព្យសកម្ម នៅក្នុងអំឡុងពេល ដែលបានកំណត់ជាទូទៅដោយនិយតកម្ម ឬដោយអនុសញ្ញានៅក្នុងទីផ្សារដែលពាក់ពន្ធ័។

ពាក្យខាងក្រោមត្រូវបានឱ្យអត្ថន័យនៅក្នុងកថាខណ្ឌ១១នៃស្តង់ដាគណនេយ្យអន្តរជាតិ៣២,កថាខណ្ឌ៩នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩ ឬឧបសម្ពន្ធ័ ក នៃស្តង់ដារបាយការណ៍ ទាក់ទង

នឹងហិរញ្ញវត្ថុអន្តរជាតិ ៧ និងត្រូវបានប្រើ នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះ ជាមួយនឹងអត្ថន័យបានកំណត់ នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣២, ស្តង់ដាគណនេយ្យអន្តរជាតិ ៣៩, ឬស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៧។

(ក) ថ្លៃដើមដករំលស់ របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ

(ខ) ហានិភ័យឥណទាន

(គ) វិធីសាស្ត្រអត្រាការប្រាក់ជាក់ស្តែង

(ឃ) ឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ

(ច) ឧបករណ៍ហិរញ្ញវត្ថុ

(ឆ) បំណុលហិរញ្ញវត្ថុ

(ជ) ធាតុទប់ស្កាត់ហានិភ័យ

(ឈ) ឧបករណ៍សម្រាប់ទប់ស្កាត់ហានិភ័យ

(ញ) ចំណាយប្រតិបត្តិការ

## ឧបសម្ព័ន្ធខ
## ការណែនាំអំពីការអនុវត្តន៍

*ឧបសម្ពន្ធ័នេះ គឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិ*

## ការទទួលស្គាល់និងការមិនទទួលស្គាល់(ជំពូកទី៣)

### ការទទួលស្គាល់លើកដំបូង(ផ្នែក ៣.១)

ខ៣.១.១ ផលវិបាកនៃគោលការណ៍នៅក្នុងកថាខណ្ឌ ៣.១.១, អង្គភាពទទួលស្គាល់រាល់សិទ្ធិតាមកិច្ចសន្យា និងរាល់កាតព្វកិច្ច តាមប្រភេទនិស្សន្ទនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនថាជាទ្រព្យសកម្ម និងបំណុលរៀងៗគ្នា លើកលែងតែសម្រាប់និស្សន្ទនានាដែលរារាំងការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថា សម្រាប់ការលក់ (មើល កថាខណ្ឌ ខ៣.២.១៤)។ ប្រសិនបើ ការផ្ទេរមិនមានគុណវុឌ្ឍ សម្រាប់ការទទួលស្គាល់, អ្នកទទួលការផ្ទេរមិន ត្រូវទទួលស្គាល់ទ្រព្យសកម្មបានផ្ទេរថាជាទ្រព្យសកម្មរបស់ខ្លួនឡើយ (មើល កថាខណ្ឌ ខ៣.២.១៥)។

ខ៣.១.២ ខាងក្រោមគឺជាឧទាហរណ៍សម្រាប់អនុវត្ត កថាខណ្ឌ៣.១.១ :

(ក) បរិមាណដែលត្រូវទទួល និងបរិមាណត្រូវសង ដែលគ្មានលក្ខខណ្ឌត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មនិងបំណុល

នៅពេលដែលអង្គភាពក្លាយជាភាគីមួយនៃកិច្ចសន្យាហើយជាផលវិបាក អង្គភាពមានសិទ្ធិស្របច្បាប់ដើម្បីទទួលសាច់ប្រាក់ ឬ មានកាតព្វកិច្ចតាមផ្លូវច្បាប់ដើម្បីសងប្រាក់។

(ខ) ទ្រព្យសកម្មត្រូវទទួល ឬបំណុលត្រូវកើតឡើង ដែលបណ្តាលមកពីការសន្យាច្បាស់លាស់មួយ ដើម្បីទិញឬលក់ទំនិញ ឬសេវាកម្ម ជាទូទៅមិនត្រូវបានទទួលស្គាល់ឡើយរហូតដល់មានភាគីមួយយ៉ាងតិច ក្នុងកិច្ចសន្យាបានអនុវត្តតាមកិច្ចព្រមព្រៀង។ ឧទាហរណ៍ អង្គភាព ដែលទទួលបានការបញ្ជាទិញច្បាស់លាស់មួយជាទូទៅមិនទទួលស្គាល់ទ្រព្យសកម្ម ( និងអង្គភាពដែលដាក់ការបញ្ជាទិញ មិនទទួលស្គាល់បំណុល ) នៅខណៈពេលនៃកិច្ចសន្យាឡើយប៉ុន្តែពន្យាពេលនៃការទទួលស្គាល់រហូតទំនិញ ឬ សេវាកម្មដែលបានបញ្ជាទិញត្រូវបានដឹកដល់ទីកន្លែង, ត្រូវបានប្រគល់ឲ្យ, ឬត្រូវបានផ្តល់ឲ្យ ។ ប្រសិនបើការសន្យាច្បាស់លាស់ ដើម្បីទិញឬលក់ធាតុមិនមែនហិរញ្ញវត្ថុស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ដោយយោងតាម កថាខណ្ឌ៥-កថាខណ្ឌ៧ នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩, តម្លៃសមស្របរបស់វាត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលនៅថ្ងៃនៃកិច្ចសន្យា (មើល(គ)) ខាងក្រោម។

បន្ថែមលើនេះ ប្រសិនបើកិច្ចសន្យាច្បាស់លាស់ដែលមិនទទួលស្គាល់ត្រូវបានកំណត់ថាជាធាតុទប់ស្កាត់ហានិភ័យនៅក្នុងការទប់ស្កាត់ហានិភ័យតម្លៃសមស្រប, ការប្រែប្រួលណាមួយនៅក្នុងតម្លៃសមស្របសុទ្ធ នាំទៅដល់ហានិភ័យដែលបានទប់ស្កាត់ត្រូវទទួលស្គាល់ថាជាទ្រព្យសកម្ម ឬបំណុលបន្ទាប់ពីការទទួលយកនូវការទប់ស្កាត់ហានិភ័យនោះ (មើលកថាខណ្ឌ ៩៣ និង កថាខណ្ឌ ៩៤ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)។

(គ) កិច្ចសន្យាអនាគតដែលស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ (មើលកថាខណ្ឌ ២.១) ត្រូវទទួលស្គាល់ថាជាទ្រព្យសកម្ម ឬបំណុលនៅថ្ងៃនៃការធ្វើកិច្ចសន្យា ជាជាងនៅថ្ងៃនៃការទូទាត់បានកើតឡើង។ នៅពេលអង្គភាពក្លាយជាភាគីមួយនៃកិច្ចសន្យាអនាគត, តម្លៃសមស្របនៃសិទ្ធិ និងកាតព្វកិច្ច តែងតែស្មើគ្នា, ដូច្នេះហើយតម្លៃសមស្របសុទ្ធរបស់កិច្ចសន្យាអនាគតគឺស្មើសូន្យ។ ប្រសិនបើ តម្លៃសមស្របរបស់សិទ្ធិ និងកាតព្វកិច្ចមិនស្មើសូន្យទេ, កិច្ចសន្យានោះនឹងត្រូវទទួលស្គាល់ថាជាទ្រព្យសកម្ម ឬបំណុល។

(ឃ) កិច្ចសន្យាមានជម្រើស ដែលស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ

(មើល កថាខណ្ឌ២.១)ត្រូវទទួលស្គាល់ថាជាទ្រព្យសកម្ម ឬបំណុលនៅពេលដែលអ្នកកាន់កាប់ ឬអ្នកចេញផ្សាយ ក្លាយជាភាគីមួយនៃកិច្ចសន្យានោះ។

(ង) ប្រតិបត្តិការអនាគតបានគ្រោងទុក, ទោះបីជាក្នុងលក្ខណៈយ៉ាងណាក៏ដោយ,មិនមែនជាទ្រព្យសកម្មនិងបំណុលទេ ពីព្រោះអង្គភាពមិនបានក្លាយជាភាគីមួយនៃកិច្ចសន្យានៅឡើយ។

## ការទិញឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបធម្មតា

ខ៣.១.៣ ការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបធម្មតា ដោយប្រើគណនេយ្យនៅកាលបរិច្ឆេទជួញដូរ ឬគណនេយ្យនាកាលបរិច្ឆេទទូទាត់ ដូចបានបរិយាយក្នុងកថាខណ្ឌ ខ៣.១.៥ និង កថាខណ្ឌ ខ៣.១.៦។ អង្គភាពត្រូវអនុវត្តវិធីសាស្រ្តដូចគ្នាជាប្រចាំសម្រាប់ការទិញនិងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានចាត់ថ្នាក់តាមរបៀបដូចគ្នា ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ។ សម្រាប់គោលបំណងនេះ ទ្រព្យសកម្ម ដែលត្រូវវាស់វែងជាចាំបាច់តាមតម្លៃសមស្រប នៅចុងកាលបរិច្ឆេទបង្កើតបានជាការបែងចែកដាច់ដោយឡែកមួយពីទ្រព្យសកម្មដែលបានកំណត់ថាបានវាស់វែងតាមតម្លៃសមស្រប នៅចុងកាលបរិច្ឆេទ។បន្ថែមលើសនេះ ការវិនិយោគក្នុងឧប-

ករណីហិរញ្ញវត្ថុជាទ្រព្យម្ចាស់ដែលបានផ្សំផ្គុំឡើងដោយការប្រើជម្រើស ដែលបានផ្តល់ឱ្យនៅក្នុងកថាខណ្ឌ៥.៧.៥ បង្កើតបានជាការបែងចែកដាច់ដោយឡែកមួយ។

ខ៣.១.៤ កិច្ចសន្យាដែលតម្រូវ ឬអនុញ្ញាតិឱ្យមានការទូទាត់សុទ្ធ នៃការផ្លាស់ប្តូរតម្លៃសមស្រប មិនមែនជាកិច្ចសន្យាតាមរបៀបធម្មតានោះទេ។ ផ្ទុយទៅវិញកិច្ចសន្យានោះ ត្រូវបានគេកំណត់ថាជានិសន្ទវត្ថុមួយនៅក្នុងរយៈពេលចន្លោះពីកាលបរិច្ឆេទជួញដូរ និងកាលបរិច្ឆេទទូទាត់។

ខ៣.១.៥ កាលបរិច្ឆេទជួញដូរគឺជាកាលបរិច្ឆេទ ដែលអង្គភាពប្តេជ្ញា ដោយខ្លួនឯងដើម្បីទិញឬលក់ទ្រព្យសកម្ម ។ គណនេយ្យនៅកាល-បរិច្ឆេទជួញដូរសំដៅដល់ (ក) ការទទួលស្គាល់ទ្រព្យសកម្មដែលត្រូវទទួលនិងបំណុលដែលត្រូវសងនៅកាលបរិច្ឆេទជួញដូរ, និង (ខ) ការមិនទទួលស្គាល់ទ្រព្យសកម្មដែលបានលក់, ការទទួលស្គាល់ចំណេញ ឬខាត ពីការលក់ទ្រព្យសកម្មនិងការទទួលស្គាល់បរិមាណត្រូវទារពីអ្នកទិញសម្រាប់ការទូទាត់នៅកាលបរិច្ឆេទជួញដូរ។ ជាទូទៅ ការប្រាក់មិនចាប់ផ្តើមកើនបន្ថែមលើទ្រព្យសកម្មនិងបំណុលពាក់ពន្ធ័ទេ រហូតដល់កាលបរិច្ឆេទទូទាត់ នៅពេលដែលកម្មសិទ្ធិភាពត្រូវផ្ទេរ។

១៣.១.៦ កាលបរិច្ឆេទទូទាត់គឺជាកាលបរិច្ឆេទ ដែលទ្រព្យសកម្ម ត្រូវបាន ប្រគល់ឱ្យឬបានទទួលដោយអង្គភាព។ គណនេយ្យ នៃកាល-បរិច្ឆេទទូទាត់សំដៅដល់ (ក) ការទទួលស្គាល់ទ្រព្យសកម្ម នៅថ្ងៃ ដែលវាត្រូវបានទទួលដោយអង្គភាព, និង (ខ) ការមិនទទួល ស្គាល់ទ្រព្យសកម្ម និងការទទួលស្គាល់ចំណេញ ឬខាត ដោយ ការបោះបង់ចោលនៅថ្ងៃដែលទ្រព្យ សកម្មនោះត្រូវបានទទួល ដោយអង្គភាព។ នៅពេលអនុវត្តគណនេយ្យ នៃកាលបរិច្ឆេទ ទូទាត់ អង្គភាព ត្រូវកំណត់អំពីបម្រែបម្រួលនៅក្នុងតម្លៃសមស្រប របស់ទ្រព្យសកម្ម ដែលត្រូវទទួល នៅក្នុងអំឡុងការិយបរិច្ឆេទ រវាងកាលបរិច្ឆេទជួញដូរនិងកាលបរិច្ឆេទទូទាត់តាមរបៀបដូចគ្នា ដែលអង្គភាពកំណត់តម្លៃ សម្រាប់ទ្រព្យសកម្មបានទិញ។ ម៉្យាង វិញទៀត បម្រែបម្រួលនៃតម្លៃមិនត្រូវបានទទួលស្គាល់សម្រាប់ ទ្រព្យសកម្មដែលវាស់វែងតាមតម្លៃដករំលស់ឡើយ, វាត្រូវទទួល ស្គាល់ក្នុងចំណេញឬខាតសម្រាប់ទ្រព្យសកម្មដែលបានចាត់ថ្នាក់ ថាជាទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាម តម្លៃសមស្រប នៅចុងការិយបរិច្ឆេទ; ហើយវាត្រូវទទួលស្គាល់ នៅក្នុងផ្នែក ចំណូលបន្ទាប់បន្សំផ្សេងៗសម្រាប់ការវិនិយោគនៅក្នុងទ្រព្យម្ចាស់ ដោយអនុលោមតាមកថាខណ្ឌ៥.៧.៥។

## ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ(ផ្នែក៣.២)

### ខ៣.២.១ គំនូសតាងខាងក្រោមពន្យល់បង្ហាញនូវការវាយតម្លៃការ មិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ។






*ការរៀបចំដែលអង្គភាពរក្សាទុសិទ្ធិតាមកិច្ចសន្យាដើម្បីទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ, ប៉ុន្តែទទួលខុសត្រូវលើកាព្វកិច្ចតាមកិច្ចសន្យា ដើម្បីសងនូវលំហូរសាច់ប្រាក់ទៅអ្នកទទួលមួយ ឬច្រើននាក់ (កថាខណ្ឌ ៣.២.៤(ខ))*

ខ៣.២.២ ស្ថានភាពដូចបានបរិយាយក្នុងកថាខណ្ឌ ៣.២.៤(ខ) (នៅពេលដែលអង្គភាពរក្សាទុសិទ្ធិ តាមកិច្ចសន្យា ដើម្បីទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ, ប៉ុន្តែទទួលខុសត្រូវលើកាព្វកិច្ចតាមកិច្ចសន្យាដើម្បីសងនូវលំហូរសាច់ប្រាក់ទៅអ្នកទទួលមួយ ឬច្រើននាក់) កើតឡើង, ឧទាហរណ៍ ប្រសិនបើអង្គភាពគឺជាអង្គភាព

មានគោលបំណងពិសេសឬជាបរធនបាលកិច្ច,និងការបោះផ្សាយទៅឲ្យអ្នកវិនិយោគនូវភាគកម្មអត្ថប្រយោជន៍នៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតនៅក្រោមការគ្រប់គ្រង និងផ្តល់នូវសេវាកម្មសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ។ ក្នុងករណីនោះ ទ្រព្យសកម្ម ហិរញ្ញវត្ថុមានលក្ខណៈសម្បត្តិសម្រាប់ការមិនទទួលស្គាល់ ប្រសិនបើ លក្ខខណ្ឌនៅក្នុង កថាខណ្ឌ ៣.២.៥ និង កថាខណ្ឌ ៣.២.៦ ត្រូវបានបំពេញ។

ខ៣.២.៣ ក្នុងការអនុវត្តកថាខណ្ឌ ៣.២.៥, អង្គភាពអាចជាអ្នកបង្កបង្កើតទ្រព្យសកម្មហិរញ្ញវត្ថុ, ឬវាអាចជាក្រុមមួយដែលរួមមានអង្គភាពមានគោលបំណងពិសេសដែលបានរួមបញ្ចូល ដែលបានទទួលទ្រព្យសកម្មហិរញ្ញវត្ថុ និងផ្ទេរលំហូរសាច់ប្រាក់ទៅអ្នកវិនិយោគដែលជាភាគីទីបីដែលមិនមានការពាក់ពន្ធ័។

## ការវាយតម្លៃនូវការផ្ទេរហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព (កថាខណ្ឌ ៣.២.៦)

ខ៣.២.៤ ឧទាហរណ៍ អំពីពេលដែល អង្គភាព ផ្ទេរជាដុំកំភួន នូវរាល់ហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព គឺៈ

(ក) ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុដោយមិនមានលក្ខខណ្ឌ

(ខ) ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុរួមជាមួយនឹងជម្រើសពិសេស ដើម្បីទិញមកវិញទ្រព្យសកម្មហិរញ្ញវត្ថុ តាមតម្លៃសមស្រប នៅពេលទិញមកវិញ, និង

(គ) ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុរួមជាមួយនឹងជម្រើសពិសេស ដើម្បីទិញមកវិញឬលក់ទៅវិញទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមែនជាទឹកប្រាក់យ៉ាងខ្ពស់(មានន័យថាជម្រើសពិសេស ដែលមិនមែនទឹកប្រាក់ ដែលវាមានលទ្ធភាពមិនកើតមានខ្ពស់ដើម្បីឈានទៅទឹកប្រាក់មុនពេលវាដល់កំណត់) ។

១៣.២.៥ ឧទាហរណ៍អំពីពេលដែលអង្គភាពរក្សាទុកជាដុំកំភួន នូវរាល់ហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព គឺៈ

(ក) ប្រតិបត្តិការនៃការលក់ ឬការទិញមកវិញដែលថ្លៃ នៃការទិញមកវិញគឺជាថ្លៃថេរ ឬជាថ្លៃលក់បូកថែមប្រាក់ចំណេញរបស់អ្នកឱ្យខ្ចី

(ខ) កិច្ចព្រមព្រៀងនៃការឱ្យខ្ចីមូលបត្រ

(គ) ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុរួម ជាមួយនឹង ការដោះដូរយកផលចំណេញសរុបដែលបានផ្ទេរការប្រឈមហានិភ័យទីផ្សារត្រលប់ទៅឱ្យអង្គភាពវិញ

(ឃ) ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុរួមជាមួយនឹងជម្រើសពិសេស ដើម្បីទិញមកវិញ ឬលក់ទៅវិញទ្រព្យសកម្មហិរញ្ញវត្ថុដែល

មានទីកប្រាក់យ៉ាងខ្ពស់ (មានន័យថាជម្រើសពិសេសដែលមិនមែនជាទីកប្រាក់ដែលវាមានលទ្ធភាពមិនកើតមានខ្ពស់ដើម្បីឈានទៅទីកប្រាក់មុនពេលវាដល់កំណត់)។

(ង) ការលក់គណនី ត្រូវទាររយៈពេលខ្លី ដែលអង្គភាពធានាធ្វើការតបសងវិញដល់អ្នកទទួលការផ្ទេរស ម្រាប់ការខាតបង់ឥណទានដែលអាចនឹងកើតឡើង។

១៣.២.៦ ប្រសិនប់អង្គភាពកំណត់ថាជាលទ្ធផលនៃការផ្ទេរ, អង្គភាព បានផ្ទេរជាដុំកំភួននូវរាល់ហានិភ័យនិហផលចំណេញ នៃកម្មសិទ្ធិភាពលើទ្រព្យសកម្មបានផ្ទេរ, អង្គភាព មិនទទួលស្គាល់ទ្រព្យសកម្មបាន ផ្ទេរនោះម្តងទៀតទេនាពេលអនាគត ដរាបណា អង្គភាពបានទទួលមកវិញនូវទ្រព្យសកម្មបានផ្ទេរនៅក្នុងប្រតិបត្តិការថ្មី។

*ការវាយតម្លៃលើការផ្ទេរសិទ្ធិនៃការគ្រប់គ្រង*

១៣.២.៧ អង្គភាព មិនរក្សាទុកការគ្រប់គ្រងទ្រព្យសកម្ម ដែលបានផ្ទេរប្រសិនបើ អ្នកទទួលការផ្ទេរមានលទ្ធភាពជាក់ស្តែង ដើម្បីលក់ទ្រព្យសកម្មបានផ្ទេរនោះ។ អង្គភាពរក្សាទុកការគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរប្រសិនបើអ្នកទទួលការផ្ទេរមិនមានលទ្ធភាពជាក់ស្តែង ដើម្បីលក់ទ្រព្យសកម្មបានផ្ទេរនោះ។ អ្នកទទួលការផ្ទេរមានលទ្ធភាពជាក់ស្តែង ដើម្បីលក់ទ្រព្យសកម្មបានផ្ទេរនោះប្រសិនបើ វាត្រូវបានជួញដូរនៅក្នុងទីផ្សារសកម្ម ពីព្រោះអ្នក

ទទួលការផ្ទេរ អាចទិញមកវិញនូវទ្រព្យសកម្មបានផ្ទេរ នៅក្នុងទីផ្សារនោះ ប្រសិនបើ វាចាំបាច់ត្រូវបង្វែរទ្រព្យសកម្មនោះ ទៅអង្គភាពវិញ។ ឧទាហរណ៍ អ្នកផ្ទេរអាចមានលទ្ធភាពជាក់ស្តែងដើម្បីលក់ទ្រព្យសកម្មបានផ្ទេរនោះ ប្រសិនបើ ទ្រព្យសកម្មបានផ្ទេរនឹងអាចជាជម្រើសពិសេសមួយដែលអនុញ្ញាតិឲ្យអង្គភាពទិញមកវិញនូវទ្រព្យសកម្មនោះ ប៉ុន្តែអ្នកទទួលការផ្ទេរអាចទទួលបានរួចជាស្រេចនូវទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងទីផ្សារប្រសិនបើជម្រើសពិសេសត្រូវបានអនុវត្ត។ អ្នកទទួលការផ្ទេរមិនមានលទ្ធភាពជាក់ស្តែងដើម្បីលក់ទ្រព្យសកម្មបានផ្ទេរ ប្រសិនបើអង្គភាពរក្សាទុកនូវជម្រើសពិសេស ហើយអ្នកទទួលការផ្ទេរ មិនអាចទទួលបានស្រាប់ៗ នូវទ្រព្យសកម្មបានផ្ទេរ នៅក្នុងទីផ្សារ ប្រសិនបើអង្គភាពអនុវត្តជម្រើសពិសេសរបស់ខ្លួន។

១៣.២.៨ អ្នកទទួលការផ្ទេរមានលទ្ធភាពជាក់ស្តែង ដើម្បីលក់ទ្រព្យសកម្មបានផ្ទេរនោះ តែក្នុងករណីដែល អ្នកទទួលការផ្ទេរ អាចលក់ទ្រព្យសកម្មបានផ្ទេរនៅក្នុងអង្គភាពរបស់ខ្លួនទៅឲ្យភាគីទីបីដែលមិនមានការពាក់ពន្ធ័ និងអាចមានលទ្ធភាពអនុវត្តលទ្ធភាពនោះដោយឯកតោភាគី និងមិនដាក់កម្រិតកំណត់ផ្សេងទៀតនៅលើការផ្ទេរ។ បញ្ហាចំបងនៅត្រង់ថា អ្វីដែលអ្នកទទួលការផ្ទេរអាចធ្វើបានដោយជាក់ស្តែង, មិនមែនអ្វីដែលជាសិទ្ធិតាមកិច្ចសន្យាដែលអ្នក ទទួលការផ្ទេរមានការបារម្ភពីអ្វីដែលខ្លួនអាចធ្វើបានជាមួយ

នឹងទ្រព្យសកម្មបានផ្ទេរ ឬជាអ្វីដែលជាការហាមឃាត់ តាមកិច្ចសន្យាបានកើតឡើង។ ជាពិសេសៈ

(ក) សិទ្ធិតាមកិច្ចសន្យា ដើម្បីលក់ចោលទ្រព្យសកម្មបានផ្ទេរមាន ផលប៉ះពាល់ជាក់ស្តែងតិចតួច ប្រសិនបើ មិនមានទីផ្សារសម្រាប់ទ្រព្យសកម្មបានផ្ទេរ និង

(ខ) លទ្ធភាពលក់ចោលទ្រព្យសកម្មបានផ្ទេរមាន ផលប៉ះពាល់ជាក់ស្តែងតិចតួច ប្រសិនបើ វាមិនអាចអនុវត្តបានដោយសេរី។ សម្រាប់ហេតុផលនេះ÷

(១)លទ្ធភាពរបស់អ្នកផ្ទេរ ដើម្បីលក់ចោល ទ្រព្យសកម្មបានផ្ទេរត្រូវតែមិនចំណុះដោយសារសកម្មភាពរបស់អ្នកដទៃ (មានន័យថា វាត្រូវតែជាលទ្ធភាពឯកតោភាគី)

(២)អ្នកទទួលការផ្ទេរត្រូវតែអាចលលក់ចោលទ្រព្យសកម្មបានផ្ទេរ ដោយមិនចាំបាច់ភ្ជាប់មកជាមួយ នូវលក្ខខណ្ឌកំហិត ឬ “កម្រិតកំណត់” លើការផ្ទេរ (ឧ. លក្ខខណ្ឌស្តីពីរបៀបសងទ្រព្យសកម្មជាកម្ចី ឬជម្រើសពិសេសបានផ្តល់ឲ្យអ្នកទទួលការផ្ទេរនូវសិទ្ធិ ដើម្បីទិញមកវិញ នូវទ្រព្យសកម្ម)។

១៣.២.៩ អ្នកទទួលការផ្ទេរ មិនអាចលក់ទ្រព្យសកម្មបានផ្ទេរ សម្រាប់ខ្លួនឯងមានន័យថាអ្នកផ្ទេររក្សាទុកការគ្រប់គ្រងទ្រព្យសកម្មបានផ្ទេរ។

ទោះជាយ៉ាងណា, ជម្រើសពិសេសសម្រាប់លក់ ឬការធានារារាំងអ្នកទទួលការផ្ទេរមិនឱ្យលក់ ទ្រព្យសកម្មបានផ្ទេរ ដូចនេះ អ្នកផ្ទេរបានរក្សាទុកការគ្រប់គ្រងលើទ្រព្យសកម្មបានផ្ទេរ។ឧទាហរណ៍ ប្រសិនបើជម្រើសពិសេសសម្រាប់លក់ ឬការធានាមានតម្លៃ គ្រប់គ្រាន់ ដែលវាកម្រិតទៅលើអ្នកទទួលការផ្ទេរ មិនឱ្យលក់ទ្រព្យសកម្មបានផ្ទេរ ពីព្រោះ ដោយជាក់ស្តែងអ្នកទទួលការផ្ទេរនឹងមិនលក់ទ្រព្យសកម្មបានផ្ទេរទៅភាគីទីបីដោយមិនបានភ្ជាប់ជម្រើសពិសេសដែលស្រដៀងគ្នា ឬលក្ខខណ្ឌកំហិតផ្សេងទៀត។ ផ្ទុយទៅវិញ អ្នកទទួលការផ្ទេរនឹងរក្សាទុក ទ្រព្យសកម្មបានផ្ទេរដើម្បីទទួលបាននូវការទូទាត់តាមជម្រើសពិសេសសម្រាប់លក់ ឬការធានា។ តាមកាលៈទេសៈទាំងនេះ អ្នកផ្ទេរបានរក្សាទុកការគ្រប់គ្រងទ្រព្យសកម្មបានផ្ទេរ។

## ការផ្ទេរដែលមានគុណវុឌ្ឍសម្រាប់ការមិនទទួលស្គាល់

ខ៣.២.១០ អង្គភាពអាចរក្សាសិទ្ធិទៅលើផ្នែកមួយ នៃការបង់ការប្រាក់ពីទ្រព្យសកម្មបានផ្ទេរថាជា កម្រៃតបសង សម្រាប់សេវាកម្មទ្រព្យសកម្មទាំងនោះ។ ផ្នែកមួយនៃការបង់ការប្រាក់ ដែលអង្គភាពនឹងលះបង់ដោយសារតែការបំបាត់ចោល ឬការផ្ទេរកិច្ចសន្យាផ្តល់សេវាកម្មត្រូវបានបែងចែកសម្រាប់ទ្រព្យសកម្មផ្តល់សេវាកម្មឬបំណុលផ្តល់សេវាកម្ម។ ផ្នែកមួយនៃការបង់

ការប្រាក់ ដែលអង្គភាពមិនលះបង់ចោលគឺជាការចំរៀកការប្រាក់សុទ្ធដែលត្រូវទទួល។ ឧទាហរណ៍ ប្រសិនបើ អង្គភាពមិនបោះបង់ចោល ការប្រាក់ណាមួយទេ នៅពេលមានការបំបាត់ចោល ឬការផ្ទេរកិច្ចសន្យាផ្តល់សេវាកម្ម, លំអៀងនៃការប្រាក់ទាំងអស់ គឺជាចំរៀកការប្រាក់សុទ្ធដែលត្រូវទទួល។ សម្រាប់គោលបំណងនៃការអនុវត្តន៍ កថាខណ្ឌ ៣.២.១៣ តម្លៃសមស្របរបស់ ទ្រព្យសកម្មផ្តល់សេវាកម្ម និងចំរៀកការប្រាក់សុទ្ធដែលត្រូវទទួល ត្រូវបានប្រើដើម្បីបែងចែកតម្លៃលើបញ្ជីនៃបរិមាណត្រូវទទួល រវាងផ្នែកមួយនៃទ្រព្យសកម្មដែលមិនត្រូវបានទទួលស្គាល់និងផ្នែកមួយទៀតត្រូវបន្តទទួលស្គាល់។ ប្រសិនប់មិនមានកម្រៃសេវាកម្មបានបញ្ជាក់ ឬប្រាក់កម្រៃត្រូវទទួល មិនត្រូវបានរំពឹងទុក សម្រាប់តបសងទៅអង្គភាព ដែលផ្តល់សេវាកម្មយ៉ាងគ្រប់គ្រាន់ បំណុលសម្រាប់ការតព្វកិច្ចផ្តល់សេវាកម្មត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។

ខ៣.២.១១ ក្នុងការប៉ាន់ស្មានតម្លៃសមស្រប នៃផ្នែក ដែលត្រូវបន្តទទួលស្គាល់ និងផ្នែក ដែលមិនត្រូវបន្តទទួលស្គាល់ សម្រាប់គោល-បំណងនៃការអនុវត្តកថាខណ្ឌ ៣.២.១៣, អង្គភាពអនុវត្តការវាស់វែងតាមតម្លៃសមស្របនៅក្នុងកថាខណ្ឌ ៥.៤.១ -៥.៤.៣

និង កថាខណ្ឌ ខ៥.៤.១ -កថាខណ្ឌ ខ៥.៤.១៣ បន្ថែមទៅលើកថាខណ្ឌ៣.២.១៤។

## ការផ្ទេរដែលមិនមានគុណវុឌ្ឍិសម្រាប់ការមិនទទួលស្គាល់

ខ៣.២.១២ ខាងក្រោម គឺជាការអនុវត្តន៍គោលការណ៍ដែលបាន បង្ហាញនៅក្នុង កថាខណ្ឌ៣.២.១៥។ ប្រសិនបើការធានាដែលបានផ្តល់ឱ្យដោយអង្គភាពសម្រាប់ការខាតបង់ដោយការបោកប្រាស់លើទ្រព្យសកម្មបានផ្ទេរ រារាំងទ្រព្យសកម្មបានផ្ទេរមិនឱ្យមានការមិនទទួលស្គាល់ ដោយសារតែ អង្គភាព បានរក្សាទុកជាដុំកំភួននូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិលើទ្រព្យសកម្មបានផ្ទេរ, ទ្រព្យសកម្មបានផ្ទេរ ត្រូវបន្តទទួលស្គាល់ទាំងស្រុងនិងការតបសងបានទទួលត្រូវទទួលស្គាល់ជាបំណុល។

ខ៣.២.១៣ ឧទាហរណ៍ខាងក្រោម បង្ហាញពីរបៀប ដែលអង្គភាពធ្វើការវាស់វែងទ្រព្យសកម្មបានផ្ទេរនិងបំណុលពាក់ពន្ធ័តាមកថាខណ្ឌ៣.២.១៦។

*ទ្រព្យសកម្មទាំងអស់*

(ក) ប្រសិនបើការធានាដែលបានផ្តល់ឱ្យដោយអង្គភាពសម្រាប់ការខាតបង់ ដោយការបោកប្រាស់លើទ្រព្យសកម្មបានផ្ទេររារាំងទ្រព្យសកម្មបានផ្ទេរមិនឱ្យមានការមិនទទួលស្គាល់ ទៅតាមកម្រិតនៃការពាក់ពន្ធ័, ទ្រព្យសកម្មបានផ្ទេរ នៅកាលបរិច្ឆេទ នៃ

ការផ្ទេរ ត្រូវបានវាស់វែងតាមតម្លៃទាបជាងនៃ(១)តម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និង(២) បរិមាណជាអតិបរិមា របស់កម្រៃតបសងដែលបានទទួលនៅក្នុងការផ្ទេរ ដែលអង្គភាពអាចទាមទារឱ្យបង់ ("បរិមាណធានា")។ បំណុលពាក់ពន្ធ័ត្រូវបានវាស់វែងជាដំបូង ដោយបរិមាណធានាបូកនឹងតម្លៃសមស្របរបស់ការធានា (ដែលជាធម្មតា គឺជាកម្រៃតបសងបានទទួល សម្រាប់ការធានា)។ ជាផលវិបាក តម្លៃសមស្របដំបូងរបស់ការធានាត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ផ្អែកតាមកម្រិត នៃពេលវាលា (មើល ស្តង់ដាគណនេយ្យអន្តរជាតិ ១៨) និងតម្លៃលើបញ្ជីនៃទ្រព្យសកម្មត្រូវបានបន្ថយដោយការខាតបង់ ដោយការថយចុះតម្លៃ។

*ទ្រព្យសកម្មវាស់វែងតាមតម្លៃដករំលស់*

(ខ)ប្រសិនបើកាតព្វកិច្ច នៃជម្រើសពិសេសសម្រាប់ការលក់បានសរសេរ ដោយអង្គភាពមួយ ឬសិទ្ធិ នៃជម្រើសពិសេសសម្រាប់ ទិញយកដែលស្ថិត នៅក្នុងដៃរបស់អង្គភាពរារាំងទ្រព្យសកម្មបានផ្ទេរ ពីការមិនទទួលស្គាល់ ហើយអង្គភាពវាស់វែងទ្រព្យសកម្មបានផ្ទេរតាមតម្លៃដករំលស់, បំណុលដែលពាក់ពន្ធ័ត្រូវបានវាស់វែងតាមតម្លៃដើមរបស់វា (នោះគឺ តម្លៃតបសងបានទទួល) ដោយមានការកែសម្រួល សម្រាប់ការដករំលស់

នៃភាពខុសគ្នារវាងតម្លៃដើម និងតម្លៃដើមបានដករំលស់របស់ទ្រព្យសកម្ម បានផ្ទេរនាកាលបរិច្ឆេទផុតកំណត់របស់ជម្រើសពិសេស។ ឧទាហរណ៍ សន្មតថាតម្លៃដើមបានដករំលស់ និងតម្លៃលើបញ្ជីរបសើទ្រព្យសកម្មនៅកាលបរិច្ឆេទនៃការផ្ទេរគឺ ៩៨ ឯកតារូបិយវត្ថុ ហើយតម្លៃតបសងបានទទួលគឺ ៩៥ ឯកតារូបិយវត្ថុ។ តម្លៃដើមបានដករំលស់របស់ទ្រព្យសកម្មនៅកាល-បរិច្ឆេទនៃការអនុវត្តជម្រើសពិសេសគឺ ១០០ឯកតារូបិយវត្ថុ។ តម្លៃលើបញ្ជីដំបូងរបស់បំណុលដែលពាក់ពន្ធ័គឺ ៩៥ឯកតារូបិយវត្ថុ ហើយភាពខុសគ្នា រវាង៩៥ឯកតារូបិយវត្ថុ និង ១០០ឯកតារូបិយវត្ថុ ត្រូវបានទទួលស្គាល់ជាចំណេះ ឬខាត ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ជាក់ស្តែង។ ប្រសិនបើជម្រើសពិសេសត្រូវបានអនុវត្ត ភាពខុសគ្នារវាងតម្លៃ លើបញ្ជីរបស់បំណុលពាក់ពន្ធ័និងថ្លៃអនុវត្តជម្រើសពិសេសនោះត្រូវបានទទួលស្គាល់ជាចំណេញឬខាត។

*ទ្រព្យសកម្មវាស់វែងតាមតម្លៃសមស្រប*

(គ) ប្រសិនបើសិទ្ធិនៃជម្រើសពិសេសទិញយកត្រូវបានរក្សាទុកដោយអង្គភាពរារាំងទ្រព្យសកម្មបានពីការមិនទទួលស្គាល់ ហើយអង្គភាពវាស់វែងទ្រព្យសកម្មបានផ្ទេរ តាមតម្លៃសមស្រប,ទ្រព្យសកម្មត្រូវបន្តវាស់វែងតាមតម្លៃសមស្របរបស់វា។ បំណុលដែលពាក់ពន្ធ័ត្រូវវាស់វែងតាម (១) ថ្លៃនៃការ

អនុវត្តជម្រើសពិសេសដកចេញតម្លៃបច្ចុប្បន្នរបស់ជម្រើសប្រសិនបើជម្រើសពិសេសនោះមានតម្លៃខ្ពស់ (is in the money), (២) តម្លៃសមស្របរបស់ទ្រព្យសកម្មបានផ្ទេរដកចេញតម្លៃបច្ចុប្បន្ន របស់ជម្រើសពិសេស ប្រសិនបើជម្រើសពិសេសនោះលែងមានតម្លៃ (out of the money)។ ការកែសម្រួលចំពោះការវាស់វែងបំណុលពាក់ពន្ធ័ ដើម្បីធានាថា តម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និងបំណុលពាក់ពន្ធ័គឺជាតម្លៃសមស្របរបស់សិទ្ធិរបស់ជម្រើសពិសេសទិញយក។ ឧទាហរណ៍ ប្រសិនបើតម្លៃសមស្របរបស់ទ្រព្យសកម្មគឺ ៨០ឯកតារូបិយវត្ថុ, ថ្លៃនៃការអនុវត្តជម្រើសពិសេសគឺ ៩៥ឯកតារូបិយវត្ថុ ហើយតម្លៃបច្ចុប្បន្នរបស់ជម្រើសពិសេសគឺ ៥ឯកតារូបិយវត្ថុ, តម្លៃលើបញ្ជីរបស់បំណុលពាក់ពន្ធ័គឺ ៧៥ឯកតារូបិយវត្ថុ (៨០ឯកតារូបិយវត្ថុ-៥ឯកតារូបិយវត្ថុ) ហើយតម្លៃលើបញ្ជីរបស់ទ្រព្យសកម្មបានផ្ទេរគឺ ៨០ឯកតារូបិយវត្ថុ (នោះគឺជាតម្លៃសមស្របរបស់វា)។

(ឃ) ប្រសិនបើ ជម្រើសពិសេសសម្រាប់ដាក់លក់ ដែលបានសរសេរ ដោយអង្គភាពរារាំងទ្រព្យសកម្មបានផ្ទេរពីការមិនទទួលស្គាល់ ហើយអង្គភាពវាស់វែងទ្រព្យសកម្ម បានផ្ទេរតាមតម្លៃសមស្រប, បំណុលពាក់ពន្ធ័ត្រូវបានវាស់វែង តាម

ថ្លៃអនុវត្តសិទ្ធិពិសេស បូកថែមតម្លៃបច្ចុប្បន្នរបស់ជម្រើសពិសេសនោះ។ ការវាស់វែងទ្រព្យសកម្មតាមតម្លៃសមស្រប ត្រូវបានកម្រិតទៅតាមកម្រិតទាបជាងរវាងតម្លៃសមស្រប និងថ្លៃអនុវត្តជម្រើសពីសេស ពីព្រោះអង្គភាព មិនមានសិទ្ធិបង្កើនតម្លៃសមស្របរបស់ទ្រព្យសកម្មបានផ្ទេរឲ្យលើសពីថ្លៃអនុវត្តជម្រើសពិសេសឡើយ។ ការធ្វើបែបនេះនឹងធានាថាតម្លៃលើបញ្ជីសុទ្ធរបស់ទ្រព្យសកម្មនិងបំណុលពាក់ពន្ធ័គឺជាតម្លៃសមស្របរបស់កាតព្វកិច្ចនៃជម្រើសសម្រាប់ការដាក់លក់។ ឧទាហរណ៍ ប្រសិនបើតម្លៃសមស្រប នៃទ្រព្យសកម្មគឺ ១២០ ឯកតារូបិយវត្ថុ, ថ្លៃអនុវត្តជម្រើសពិសេសគឺ ១០០ឯកតារូបិយវត្ថុ ហើយតម្លៃបច្ចុប្បន្នរបស់ជម្រើសពិសេសគឺ ៥ ឯកតារូបិយវត្ថុ, តម្លៃលើបញ្ជីរបស់បំណុលពាក់ពន្ធ័គឺ ១០៥ ឯកតារូបិយវត្ថុ (១០០ ឯកតារូបិយវត្ថុ+៥ ឯកតារូបិយវត្ថុ) ហើយបរិមាណលើបញ្ជីរបស់ទ្រព្យសកម្មគឺ១០០ឯកតារូបិយវត្ថុ (ក្នុងករណីនេះ វាគឺជាថ្លៃអនុវត្តសិទ្ធិពិសេស)។

(ង) ប្រសិនបើយុទ្ធសាស្ត្រជម្រើសពិសេស, ជាទម្រង់ នៃកិច្ចសន្យាទិញនិងលក់, រារាំងទ្រព្យសកម្មបានផ្ទេរពីការ មិនទទួលស្គាល់ ហើយអង្គភាពវាស់វែងទ្រព្យសកម្ម តាមតម្លៃសមស្រប, អង្គភាព ត្រូវបន្តវាស់វែងទ្រព្យសកម្មតាមតម្លៃ

សមស្រប។ បំណុលពាក់ពន្ធ័ត្រូវបានវាស់វែងតាម (១) ផលបូកនៃថ្លៃអនុវត្ត ជម្រើសពិសេសទិញយក ជាមួយនឹងតម្លៃសមស្របនៃជម្រើសសម្រាប់ដាក់លក់ដកចេញតម្លៃបច្ចុប្បន្នរបស់ជម្រើសពិសេសទិញយក, ប្រសិនបើ ជម្រើសពិសេសទិញយកមានតម្លៃខ្ពស់ ឬ (២) ផលបូកនៃតម្លៃសមស្របរបស់ទ្រព្យសកម្ម ជាមួយនឹងតម្លៃសមស្រប របស់ជម្រើសពិសេស សម្រាប់ដាក់លក់ ដកចេញ តម្លៃបច្ចុប្បន្នរបស់ជម្រើសពិសេសទិញយក ប្រសិនបើជម្រើស ពិសេសនោះលែងមានតម្លៃ។។ការ

កែសម្រួលចំពោះការវាស់វែងបំណុលពាក់ពន្ធ័ដើម្បីធានាថាតម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និងបំណុលពាក់ពន្ធ័ គឺជាតម្លៃសមស្របរបស់សិទ្ធិរបស់ជម្រើសពិសេសដែលរក្សាទុកនិងបានសន្យាដោយអង្គភាព។ឧទាហរណ៍សន្មតថា អង្គភាពផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ខណៈដែលមានការទិញជាបន្តបន្ទាប់ នូវជម្រើសពិសេសទិញយកដោយមានថ្លៃអនុវត្ត ១២០ ឯកតារូបិយវត្ថុ និងមានជម្រើសពិសេស នៃការដាក់លក់ដែលមាថ្លៃអនុវត្ត ៨០ ឯកតារូបិយវត្ថុ។ សន្មតផងដែរថា តម្លៃសមស្របរបស់ទ្រព្យសកម្មគឺ១០០ ឯកតារូបិយវត្ថុ នៅកាលបរិច្ឆេទនៃការផ្ទេរ។ តម្លៃបច្ចុប្បន្នរបស់ជម្រើសនៃការដាក់លក់គឺ ១ ឯកតា

រូបិយវត្ថុនិងតម្លៃបច្ចុប្បន្នរបស់ជម្រើសទិញយកគឺ ៥ ឯកតារូបិយវត្ថុ។ នៅក្នុងករណីនេះ, អង្គភាព ទទួលស្គាល់ទ្រព្យសកម្មតម្លៃ ១០០ ឯកតារូបិយវត្ថុ (តម្លៃសមស្របរបស់ទ្រព្យសកម្ម) និងបំណុលមានតម្លៃ ៩៦ ឯកតារូបិយវត្ថុ [(១០០ ឯកតារូបិយវត្ថុ + ១ ឯកតារូបិយវត្ថុ) - ៥ ឯកតារូបិយវត្ថុ]។ ប្រការនេះផ្តល់នូវ តម្លៃសុទ្ធរបស់ទ្រព្យសកម្មមានចំនួន ៤ ឯកតារូបិយវត្ថុ ដែលជាតម្លៃសមស្របរបស់ជម្រើសពិសេសរក្សាទុកនិងសន្យាដោយអង្គភាព។

## ការផ្ទេរទាំងស្រុង

ខ៣.២.១៤ នៅក្នុងកម្រិត នៃការផ្ទេរទ្រព្យសកម្មដែលមិនមានគុណវុឌ្ឍិសម្រាប់ការមិនទទួលស្គាល់, សិទ្ធិតាមកិច្ចសន្យារបស់អ្នកផ្ទេរ ឬកាតព្វកិច្ចដែលពាក់ពន្ធ័ទៅនឹងការផ្ទេរមិនត្រូវបានគិតដាច់ដោយឡែកពីគ្នាដូចជានិស្សន្ទឡើយ ប្រសិនបើ ទទួលស្គាល់ទាំងនិស្សន្ទនិងទាំងទ្រព្យសកម្មបានផ្ទេរ ឬបំណុលដែលកើតចេញពីការផ្ទេរនឹងធ្វើឱ្យមានការទទួលស្គាល់សិទ្ធិឬកាតព្វកិច្ចទាំងពីរដូចគ្នា។ ឧទាហរណ៍ សិទ្ធិទិញ (call option) មួយដែលបានរក្សាទុក ដោយអ្នកផ្ទេរ អាចរារាំងនូវការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ ពីការចាត់ទុកសម្រាប់ការលក់ចេញ។ ក្នុង

ករណីនោះ សិទ្ធិទិញមិនត្រូវបានទទួលស្គាល់ដាច់ដោយឡែក ថាជាទ្រព្យសកម្មនិស្សន្ទនោះឡើយ។

ខ៣.២.១៥ នៅក្នុងកម្រិតនៃការផ្ទេរទ្រព្យសកម្ម ដែលមិនមានគុណវុឌ្ឍិសម្រាប់ការ មិនទទួលស្គាល់, អ្នកទទួលការផ្ទេរ មិនទទួលស្គាល់ទ្រព្យសកម្មបានផ្ទេរថាជា ទ្រព្យសកម្មរបស់ខ្លួនឡើយ។ អ្នកទទួលការផ្ទេរមិនទទួលស្គាល់សាច់ប្រាក់ ឬតម្លៃតបសងផ្សេងៗ ដែលបានបង់ ហើយទទួលស្គាល់បរិមាណត្រូវទារពីអ្នកផ្ទេរ។ ប្រសិនបើអ្នកផ្ទេរមានទាំងសិទ្ធិនិងកាតព្វកិច្ចដើម្បីទទួលបានមកវិញនូវការគ្រប់គ្រងលើទ្រព្យសកម្មបានផ្ទេរទាំងស្រុងសម្រាប់បរិមាណទឹកប្រាក់ថេរមួយ (ដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនៃការទិញមកវិញ) អ្នកទទួលការផ្ទេរអាចវាស់វែងបរិមាណ ត្រូវទាររបស់ខ្លួន តាមតម្លៃបានដករំលស់ប្រសិនប់វាបំពេញបាន តាមលក្ខណៈវិនិច្ឆ័យក្នុង កថាខណ្ឌ ៤.១.២។

## ឧទាហរណ៍

ខ៣.២.១៦ ឧទាហរណ៍ខាងក្រោមពន្យល់ អំពីការអនុវត្តន៍គោលការណ៍នៃការមិនទទួលស្គាល់ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ។

(ក) *កិច្ចព្រមព្រៀងទិញមកវិញនិងការឲ្យខ្ចីមូលបត្រ។* ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលក់តាមកិច្ចព្រមព្រៀងដើម្បីទិញវាមិវិញតាមថ្លៃថេរមួយ ឬតាមថ្លៃលក់បូកថែមផលចំណេញរបស់អ្នកឲ្យខ្ចី ឬប្រសិនបើវាត្រូវបានខ្ចីតាមកិច្ចព្រមព្រៀងបង្វិលទ្រព្យសកម្មហិរញ្ញវត្ថុទៅឲ្យអ្នកផ្ទេរវិញ, ទ្រព្យសកម្មហិរញ្ញវត្ថុនោះមិនត្រូវបានទទួលស្គាល់ឡើយ ពីព្រោះអ្នកផ្ទេររក្សាទុកជាដុំកំភួននូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាពនោះ។ប្រសិនបើអ្នកទទួលការផ្ទេរមានសិទ្ធិលក់ ឬដាក់បញ្ចាំ ទ្រព្យសកម្មនោះ អ្នកផ្ទេរត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មនោះ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន, ឧទាហរណ៍, ជាទ្រព្យសកម្មបានឲ្យខ្ចី ឬបរិមាណត្រូវទទួលដោយការ ទិញមកវិញ។

(ខ) *កិច្ចព្រមព្រៀងទិញមកវិញនិងការឲ្យខ្ចីមូលបត្រទ្រព្យសកម្មដែលដូចគ្នាខ្លាំង។* ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានលក់តាមកិច្ចព្រមព្រៀង ដើម្បីទិញមកវិញ នូវទ្រព្យសកម្មដែលដូចគ្នាឬដែលស្ទើរតែដូចគ្នាតាមថ្លៃថេរមួយ ឬតាមថ្លៃលក់បូកថែម ផលចំណេញរបស់អ្នកឲ្យខ្ចី ឬទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានខ្ចី ឬបានឲ្យខ្ចី តាមកិច្ចព្រមព្រៀង ដើម្បីទិញមកវិញនូវទ្រព្យសកម្មដែលដូចគ្នាឬដែលស្ទើរតែដូចគ្នាចំពោះអ្នកផ្ទេរ,ទ្រព្យសកម្មនោះមិនត្រូវបានមិនទទួលស្គាល់

ឡើយពីព្រោះ អ្នកផ្ទេររក្សាទុកជាដុំកំភួននូវហានិភ័យ និង ផលចំណេញនៃកម្មសិទ្ធិភាពនោះ។

(គ) *កិច្ចព្រមព្រៀងទិញមកវិញនិងការឲ្យខ្ចីមូលបត្រសិទ្ធិនៃការជំនួស។* ប្រសិនបើកិច្ចព្រមព្រៀងនៃការទិញមកវិញ តាមថ្ងៃទិញមកវិញថេរមួយ ឬថ្ងៃដែលស្មើនឹង ថ្ងៃលក់បូកថែមផលចំណេញរបស់អ្នកឲ្យខ្ចី, ឬប្រតិបត្តិការឲ្យខ្ចី មូលបត្រដែលមានលក្ខណៈស្រដៀងគ្នា, ផ្តល់ឲ្យអ្នកទទួលការផ្ទេរនូវសិទ្ធិដើម្បីជំនួសទ្រព្យសកម្មដែលស្រដៀងគ្នា និងមានតម្លៃសមស្របស្មើគ្នា ចំពោះទ្រព្យសកម្មបានផ្ទេរនៅកាលបរិច្ឆេទទិញមកវិញ, ទ្រព្យសកម្មបានលក់ឬឲ្យ ខ្ចីតាមកិច្ចព្រមព្រៀងទិញមកវិញ ឬប្រតិបត្តិការឲ្យខ្ចីមូលបត្រមិនត្រូវបានមិនទទួលស្គាល់ឡើយពីព្រោះអ្នកផ្ទេររក្សាទុកជាដុំកំភួននូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាពនោះ។

(ឃ) *សិទ្ធិទិញមកវិញ តាមតម្លៃសមស្រប នៃការបដិសេធលើកដំបូង។* ប្រសិនបើ អង្គភាពលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងរក្សាទុកតែសិទ្ធិនៃការបដិសេធដំបូង ដើម្បីទិញមកវិញនូវទ្រព្យសកម្មបានផ្ទេរតាមតម្លៃសមស្រប ប្រសិនបើអ្នកទទួលការផ្ទេរលក់វានៅពេលក្រោយមក, អង្គភាពមិនទទួលស្គាល់

ទ្រព្យសកម្មនោះទេ ពីព្រោះ អង្គភាពបានផ្ទេរជាដុំកំភួន នូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាពនោះហើយ។

(ង) *ប្រតិបត្តិការលក់លាងសំអាត។* ការទិញមកវិញភ្លាមៗ នូវទ្រព្យសកម្មហិរញ្ញវត្ថុដែលអង្គភាពបានលក់ចេញ ពេលខ្លះត្រូវបានហៅថា ការលក់លាងសំអាត។ ការទិញមកវិញបែបនេះមិនច្រានចោលការមិនទទួលស្គាល់ ដែលបានផ្តល់ថាប្រតិបត្តិការដំបូងបានឆ្លើយតបទៅនឹងការតម្រូវនៃការមិនទទួលស្គាល់។ ទោះជាយ៉ាងណា ប្រសិនបើ កិច្ចព្រមព្រៀងលក់ទ្រព្យសកម្មហិរញ្ញវត្ថុបានធ្វើឡើងដោយដំណាលគ្នាជាមួយនឹងកិច្ចព្រមព្រៀងទិញមកវិញនូវទ្រព្យសកម្ម ដូចគ្នា តាមថ្លៃថេរ ឬថ្លៃលក់បូកថែមនឹង ផលចំណេញរបស់អ្នកឱ្យខ្ចី ដូច្នេះ ទ្រព្យសកម្មមិនត្រូវបានមិនទទួលស្គាល់នោះឡើយ។

(ច) *សិទ្ធិលក់និងសិទ្ធិទិញដែលមានតម្លៃទឹកប្រាក់ច្រើន។* ប្រសិនបើ ទ្រព្យសកម្មហិរញ្ញវត្ថុ អាចត្រូវបានទិញមកវិញដោយអ្នកផ្ទេរ ហើយសិទ្ធិទិញមានតម្លៃជាទឹកប្រាក់ច្រើន, ការផ្ទេរមិនមានគុណវិឡ្លសម្រាប់ការមិនទទួលស្គាល់ឡើយ ពីព្រោះអ្នកផ្ទេររក្សាទុកជាដុំកំភួននូវហានិភ័យនិងផលចំណេញ នៃកម្មសិទ្ធិភាពនោះ។ស្រដៀងគ្នានេះ ប្រសិនបើ ទ្រព្យសកម្មហិរញ្ញវត្ថុអាចត្រូវបានដាក់លក់ទៅវិញដោយអ្នកទទួលការ

ផ្ទេរ ហើយសិទ្ធិលក់មានតម្លៃជាទឹកប្រាក់ច្រើន, ការផ្ទេរមិនមានគុណវិឌ្ឍ សម្រាប់ការមិនទទួលស្គាល់ឡើយ ពីព្រោះអ្នកផ្ទេររក្សាទុកជាដុំកំភួននូវហានិភ័យ និងផលចំណេញ នៃកម្មសិទ្ធិភាពនោះ។

(ជ) *សិទ្ធិលក់ និងសិទ្ធិទិញ ដែលមិនមានតម្លៃទឹកប្រាក់ច្រើន។* ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានផ្ទេរសម្រាប់តែសិទ្ធិលក់ដែលមិនមានតម្លៃទឹកប្រាក់ច្រើនដែលរក្សាទុក ដោយអ្នកទទួលការផ្ទេរ ឬសិទ្ធិទិញដែលមិនមានទឹកប្រាក់ច្រើនដែលរក្សាទុកដោយអ្នកផ្ទេរនឹងមិនត្រូវទទួលស្គាល់ឡើយ។ នេះគឺដោយសារតែអ្នកផ្ទេរបានផ្ទេរទាំងស្រុង ជាដុំកំភួនហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាពនោះ។

(ឈ) *ទ្រព្យសកម្ម អាចទទួលបានជាស្រេចដែលកជាម្មវត្ថុនៃសិទ្ធិទិញដែលមិនមែនជាសិទ្ធិ ដែលមានតម្លៃទឹកប្រាក់ច្រើន ឬសិទ្ធិដែលមិនមានតម្លៃទឹកប្រាក់។* ប្រសិនបើ អង្គភាពកាន់កាប់សិទ្ធិទិញលើទ្រព្យសកម្ម ដែលអាចទទួលបានជាស្រេចនៅក្នុងទីផ្សារ ហើយសិទ្ធិនោះមិនមែនជាសិទ្ធិ ដែលមានតម្លៃទឹកប្រាក់ច្រើនឬសិទ្ធិដែលមិនមានតម្លៃទឹកប្រាក់, ទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់ឡើយ។ នេះគឺដោយសារតែអង្គភាព (១) មិនរក្សាទុកជាដុំកំភួននូវហានិភ័យ និងផល

ចំណេញនៃកម្មសិទ្ធិភាព, និង (២) មិនរក្សាទុកការគ្រប់គ្រងលើទ្រព្យសកម្មនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើទ្រព្យសកម្ម មិនអាចទទួលបានរួចជាស្រេច នៅក្នុងទីផ្សារ, ការមិនទទួលស្គាល់ ត្រូវច្រានចោល ជាមុនទៅតាមកម្រិតបរិមាណទឹកប្រាក់របស់ទ្រព្យសកម្ម ដែលជាកម្មវត្ថុ នៃសិទ្ធិទិញពីព្រោះអង្គភាពរក្សាទុក ការគ្រប់គ្រង លើទ្រព្យសកម្មនោះ។

(ញ) *ទ្រព្យសកម្ម មិនអាចទទួលបានជាស្រេចដែលជាកម្មវត្ថុ នៃសិទ្ធិលក់ដែលមិនមែនជាសិទ្ធិដែលមានតម្លៃទឹកប្រាក់ច្រើន ឬសិទ្ធិដែលមិនមានតម្លៃទឹកប្រាក់។* ប្រសិនបើ អង្គភាពផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនអាចទទួលបានជាស្រេច នៅក្នុងទីផ្សារ និងសរសេរសិទ្ធិលក់ដែលមិនមែនជាសិទ្ធិ ដែលមានតម្លៃទឹកប្រាក់ច្រើន ឬសិទ្ធិ ដែលមិនមានតម្លៃទឹកប្រាក់, អង្គភាពមិនរក្សាទុកឬក៏ផ្ទេរទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាព។ អង្គភាពរក្សាទុកការគ្រប់គ្រងទ្រព្យសកម្មប្រសិនបើសិទ្ធិលក់អាចមានតម្លៃគ្រប់គ្រាន់ដើម្បីរារាំងអ្នកទទួលការផ្ទេរ មិនឲ្យលក់ទ្រព្យសកម្មនោះ, ដែលក្នុងករណីនេះ ទ្រព្យសកម្មត្រូវបន្តទទួលស្គាល់ទៅតាមកម្រិតនៃការពាក់ពន្ធ័ជាបន្តរបស់អ្នកផ្ទេរ (មើល កថាខណ្ឌ ខ៣.២.៩)។ អង្គភាពផ្ទេរការគ្រប់គ្រងទ្រព្យសកម្មប្រសិនបើ

សិទ្ធិលក់មិនមានតម្លៃគ្រប់គ្រាន់ ដើម្បីរារាំងអ្នកផ្ទេរមិនឱ្យលក់ទ្រព្យសកម្មនោះ ដែលក្នុងករណីនេះ ទ្រព្យសកម្មមិនត្រូវបានគេទទួលស្គាល់ឡើយ។

(j) *ទ្រព្យសកម្ម ជាកម្មវត្ថុនៃសិទ្ធិទិញ ឬសិទ្ធិលក់តាមតម្លៃសមស្រប ឬនៃកិច្ចព្រមព្រៀងទិញមកវិញ តាមតម្លៃអនាគត។* ការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិទិញឬសិទ្ធិលក់តាមតម្លៃសមស្រប ឬនៃកិច្ចព្រមព្រៀង ទិញមកវិញតាមតម្លៃអនាគតដោយមានថ្លៃអនុវត្ត ឬថ្លៃទិញមកវិញស្មើនឹងតម្លៃសមស្របរបស់ទ្រព្យសកម្មនៅខណៈពេល នៃការទិញមកវិញដែលកើតចេញពីការមិនទទួលស្គាល់ដោយសារតែការផ្ទេរទាំងស្រុងជាដុំកំភួននូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព។

(k) សិទ្ធិទិញឬសិទ្ធលក់ដែលទូទាត់ជាសាច់ប្រាក់។ អង្គភាពវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិទិញ ឬសិទ្ធិលក់ ឬកិច្ចព្រមព្រៀងទិញមកវិញតាមតម្លៃអនាគត ដែលនឹងត្រូវទូទាត់ជាសាច់ប្រាក់សុទ្ធ ដើម្បីកំណត់ថា តើអង្គភាពបានរក្សាទុក ឬផ្ទេរទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាពនោះ។ ប្រសិនបើ អង្គភាពមិនរក្សាទុកទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញ

នៃកម្មសិទ្ធិភាពរបស់ទ្រព្យសកម្មបានផ្ទេរ, អង្គភាពកំណត់ថា តើខ្លួនបានរក្សាទុក ការគ្រប់គ្រងលើទ្រព្យសកម្ម បានផ្ទេរ ឬទេ។ ដូចច្នេះ សិទ្ធិលក់ឬសិទ្ធិទិញ ឬកិច្ចព្រមព្រៀងទិញមកវិញតាមតម្លៃអនាគត ដែលត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធមិនមានន័យជាស្វ័យប្រវត្តិថា អង្គភាពបានផ្ទេរការគ្រប់គ្រងឡើយ (មើល កថាខណ្ឌ ខ៣.២.៩ និងចំណុច (g), (h), និង (i) ខាងលើ។

(l) *ការដកចេញបរិមាណសំវិធានធន*។ ការដកចេញបរិមាណសំវិធានធនគឺជាសិទ្ធិ (ទិញ) នៃការទិញមកវិញដោយមិនមានលក្ខខណ្ឌដែលផ្តល់ឱ្យអង្គភាពនូវសិទ្ធិដើម្បីធ្វើបដិរូបករទ្រព្យសកម្មដែលបានផ្ទេរដែលជាកម្មវត្ថុទៅនឹង ការដាក់កំហិតមួយចំនួន។ ដោយបានផ្តល់ឱ្យ នូវសិទ្ធិជម្រើសមួយបែបនេះ ដែលបានធ្វើឱ្យអង្គភាពមិនរក្សាទុក ឬក៏ផ្ទេរទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាព, អង្គភាពច្រានចោលជាមុននូវការមិនទទួលតែទៅតាមកម្រិតនៃបរិមាណ ដែលជាកម្មវត្ថុនៃការទិញមកវិញ (សន្មតថាអ្នកទទួលការផ្ទេរ មិនអាចលក់ ទ្រព្យសកម្មនោះបាន)។ ឧទាហរណ៍ប្រសិនបើបរិមាណទឹកប្រាក់លើបញ្ជីនិងទឹកប្រាក់បានទទួលពីការផ្ទេរនៃទ្រព្យសកម្មកម្ចីគឺ ១០០,០០០ ឯកតារូបិយវត្ថុ ហើយប្រាក់កម្ចីនិមួយៗ អាចទិញមកវិញបាន ប៉ុន្តែ

បរិមាណបង្គរ នៃប្រាក់កម្ចី ដែលអាចត្រូវបានទិញមកវិញបាន មិនអាចមានបរិមាណលើសពី ១០,០០០ ឯកតារូបិយវត្ថុ, ដូចនេះបរិមាណ ៩០,០០០ឯកតារូបិយវត្ថុ នឹងមានគុណវុឌ្ឍសម្រាប់ការមិនទទួលស្គាល់។

(ញ) *ការលក់ផ្តាច់ (clean up call)*។ អង្គភាព ដែលអាចជាអ្នកផ្ទេរ, ដែលជាអ្នកធ្វើសេវាកម្ម លើទ្រព្យសកម្មបានផ្ទេរ អាចរក្សាទុកការលក់ផ្តាច់ដើម្បីទិញមកយកទ្រព្យសកម្មបានផ្ទេរដែលនៅសល់ នៅពេលដែលបរិមាណនៃទ្រព្យសកម្មដែលនៅសល់បានធ្លាក់ដល់ កម្រិតជាក់លាក់មួយ ដែលថ្លៃដើមនៃការធ្វើសេវាកម្មទ្រព្យសកម្ម ទាំងនោះក្លាយជាបន្ទុកក្នុងការពាក់ពន្ធ័ទៅនឹងអត្ថប្រយោជន៍ នៃការធ្វើសេវាកម្ម។ ដោយផ្តល់នូវការលក់ផ្តាច់បែបនេះ អង្គភាពមិនរក្សាទុក ឬក៏មិនផ្ទេរទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាព ហើយអ្នកទទួលការផ្ទេរមិនអាចលក់ទ្រព្យសកម្មនោះបាន, វារារាំងជាមុននូវការមិនទទួលស្គាល់ត្រឹមកម្រិតនៃបរិមាណទ្រព្យសកម្មដែលជាកម្មវត្ថុ នៃសិទ្ធិទិញ។

(ដ) *ការប្រាក់បន្ទាប់បន្សំនិងការធានាឥណទាន*។ អង្គភាព អាចផ្តល់ឲ្យអ្នកទទួលការផ្ទេរនូវភាពល្អប្រសើរ នៃឥណទានជាមួយនឹងការប្រាក់ខ្លះ ឬទាំងអស់ ដែលមាននៅក្នុងទ្រព្យ

សកម្មបានផ្ទេរ។ ម៉្យាងវិញទៀត អង្គភាពអាចផ្តល់ឲ្យអ្នកទទួលការផ្ទេរនូវការធ្វើឲ្យប្រសើរឡើងនៃឥណទាន នៅក្នុងទម្រង់ជាការធានាឥណទាន ដែលអាចមានបរិមាណកំណត់ ឬបរិមាណមិនកំណត់។ ប្រសិនបើអង្គភាពរក្សាទុកទាំងស្រុងជាដុំកំភួននូវហានិភ័យ និងផលចំណេញ នៃកម្មសិទ្ធិភាពរបស់ទ្រព្យសកម្មបានផ្ទេរ, ទ្រព្យសកម្មត្រូវបន្តទទួលស្គាល់ទាំងស្រុង។ ប្រសិនបើអង្គភាពរក្សាទុកខ្លះ ប៉ុន្តែមិនទាំងអស់នូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព និងរក្សាទុកការគ្រប់គ្រងលើទ្រព្យសកម្មនោះ ការមិនទទួលស្គាល់ត្រូវបានរារាំងតាមកម្រិត នៃបរិមាណសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងៗដែលអង្គភាពអាចតម្រូវឲ្យបង់ទូទាត់។

(០) *ការដោះដូរផលចំណេញសរុប។* អង្គភាព អាចកើនទ្រព្យសកម្មហិរញ្ញវត្ថុ និងឈានចូលកិច្ចព្រមព្រៀងដោះដូរផលចំណេញសរុបមួយ ជាមួយអ្នកទទួលការផ្ទេរ ដែលនៅក្នុងនោះរាល់លំហូរសាច់ប្រាក់ ដែលបានពីការទូទាត់ការប្រាក់ទាំងអស់នទ្រព្យសកម្មនោះ ត្រូវបានបង្វែរទៅឲ្យ អង្គភាពសម្រាប់ជាការដោះដូរជាមួយនឹងការទូទាត់តាមអត្រាថេរ ឬការទូទាត់តាមអត្រាប្រែប្រួល និងជាមួយការកើនថែម ឬការធ្លាក់ចុះ នៃតម្លៃសមស្របរបស់ទ្រព្យសកម្មនោះ ដែលត្រូវបានទទួលយកដោយអង្គភាព។ នៅក្នុងករណីនេះ ការ

មិនទទួលស្គាល់របស់ ទ្រព្យសកម្មទាំងអស់ ត្រូវបានហាមឃាត់។

(p) *ការដោះដូរអត្រាការប្រាក់។*អង្គភាពអាចផ្ទេរទៅឱ្យអ្នកទទួលការផ្ទេរនូវទ្រព្យសកម្មហិរញ្ញវត្ថុតាមអត្រាថេរមួយ និងឈានចូលកិច្ចព្រមព្រៀងនៃការដោះដូរអត្រាការប្រាក់មួយ ដែលអ្នកទទួលការផ្ទេរទទួលបាន នូវអត្រាការប្រាក់ថេរមួយ និងត្រូវបង់អត្រាការប្រាក់ប្រែប្រួលមួយដោយផ្អែកលើបរិមាណទឹកប្រាក់ជានាមមួយ ដែលស្មើនឹងបរិមាណប្រាក់ដើមរបស់ទ្រព្យសកម្មបានផ្ទេរ។

ការដោះដូរអត្រាការប្រាក់មិនត្រូវបានរារាំងនូវការមិនទទួលស្គាល់របស់ទ្រព្យសកម្មបានផ្ទេរដែលបានផ្ដលើនូវការទូទាត់នៅលើការដោះដូរដែលមិនមានដាក់លក្ខណខណ្ឌ លើការទូទាត់ ដែលត្រូវធ្វើសម្រាប់ទ្រព្យសកម្មបានផ្ទេរ។

(q) *ការដោះដូរអត្រាការប្រាក់ដោយរំលស់។* អង្គភាពអាចផ្ទេរទៅឱ្យអ្នកទទួលការផ្ទេរនូវទ្រព្យសកម្មហិរញ្ញវត្ថុ តាមអត្រាថេរដែលត្រូវបង់ជាបន្តបន្ទាប់, និងឈានចូលកិច្ចព្រមព្រៀងនៃការដោះដូរអត្រាការប្រាក់ដោយរំលស់មួយ ជាមួយនឹងអ្នកទទួលការផ្ទេរដើម្បីទទួលនូវអត្រាការប្រាក់ថេរ និងបង់អត្រាការប្រាក់ប្រែប្រួលមួយដោយផ្អែកលើ បរិមាណទឹកប្រាក់ជានាមមួយ។ ប្រសិនបើបរិមាណទឹកប្រាក់ជានាមនៃ

ការដោះដូរនោះត្រូវរំលស់ ដែលនឹងត្រូវស្មើ នឹងបរិមាណប្រាក់ដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរដែលនៅជាប់ជំពាក់នៅពេលណាមួយ, ជាទូទៅការដោះដូរនឹងធ្វើឲ្យអង្គភាពរក្សាទុកជាដុំកំភួននូវហានិភ័យនៃការបង់ប្រាក់មុន ដែលក្នុងករណីនេះ អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មបានផ្ទេរទាំងអស់ ឬត្រូវបន្តទទួកស្គាល់ទ្រព្យសកម្មបានផ្ទេរទៅតាមកម្រិតនៃភាពពាក់ពន្ធ័ជាបន្តរបស់វា។ផ្ទុយទៅវិញ ប្រសិនបើការរដករំលស់នៃបរិមាណទឹកប្រាក់ជានាមរបស់ការដោះដូរនោះមិនមានភ្ជាប់ទៅ នឹងប្រាក់ដើម ដែលនៅជាប់ជំពាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ, ការដោះដូរនោះនឹងមិនធ្វើឲ្យអង្គភាពរក្សាទុក នូវហានិភ័យ នៃការបង់មុនសម្រាប់ទ្រព្យសកម្មឡើយ។ ដូច្នេះ វានឹងមិនរារាំងដល់ការមិនទទួលស្គាល់របស់ទ្រព្យសកម្មបានផ្ទេរ ដែលបានផ្តល់នូវការទូទាត់លើការដោះដូរ ដែលមិនមានលក្ខខណ្ឌ លើការទូទាត់ការប្រាក់ដែលត្រូវធ្វើលើទ្រព្យសកម្មបានផ្ទេរ ហើយការដោះដូរនឹងមិនធ្វើឲ្យអង្គភាពរក្សាទុកនូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាពលើទ្រព្យសកម្មបានផ្ទេរនោះឡើយ។

ខ៣.២.១៧ កថាខណ្ឌ័នេះពន្យល់ពីការអនុវត្តវិធីសាស្រ្តនៃភាពជាប់ពាក់ពន្ធ័ជាបន្ត នៅពេលភាពជាប់ពាក់ពន្ធ័ជាបន្តរបស់អង្គភាពគឺជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

សន្មតថា អង្គភាពមានក្រុមនៃកម្ចីត្រូវបង់មុន ដែលការប្រាក់ និងអត្រាការប្រាក់ជាក់ស្តែងគឺ ១០% និងដែលមានប្រាក់ដើម និងថ្លៃដើម រំលស់ ១០០០០ ឯកតារូបិយវត្ថុ។ អង្គភាពមានប្រតិបត្តិការមួយដែលនៅក្នុងនោះចំណូលនៃកាទូទាត់មួយមាន ៩១១៥ ឯកតារូបិយវត្ថុ, អ្នកទទួលការផ្ទេរទទួលបានសិទ្ធិដែលមានតម្លៃ ៩០០០ ឯកតារូបិយវត្ថុ សម្រាប់ការប្រមូលប្រាក់ដើម បូកថែមការប្រាក់ ៩.៥%។ អង្គភាពរក្សាទុកសិទ្ធិ ចំពោះ ១០០០ ឯកតារូបិយវត្ថុ លើការប្រមូលប្រាក់ដើមបូកថែមការប្រាក់ ១០% បូកថែមកម្រិតចំណេញថែម០.៥%លើបរិមាណប្រាក់ដើមនៅសល់៩០០០ ឯកតារូបិយវត្ថុ។ ការប្រមូលពីការបង់មុនត្រូវបានបងចែករវាងអង្គភាព និងអ្នកទទួលការផ្ទេរតងាមអត្រា ១:៩, ប៉ុន្តែ រាល់ការមិនសងណាមួយត្រូវដកចេញពីការប្រាក់នៃ ១០០០ ឯកតា របស់អង្គភាពរហូតដល់អស់ការប្រាក់។ តម្លៃសមស្របរបស់ប្រាក់កម្ចីនៅថ្ងៃប្រតិបត្តិការគឺ ១០១០០ ឯកតារូបិយវត្ថុ ហើយតម្លៃសមស្របប៉ាន់ស្មាន នៃកម្រិតចំណេញថែម ០.៥% មាន ៤០ ឯកតារូបិយវត្ថុ។

អង្គភាពកំណត់ថាខ្លួនបានផ្ទេរនូវហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព (ឧទាហរណ៍ ហានិភ័យ នៃការបង់មុន) ប៉ុន្តែបានរក្សាទុកខ្លះនូវហានិភ័យ និងផលចំណេញនៃកម្មសិទ្ធិភាព (ដោយសារតែ ការប្រាក់បន្ទាប់បន្សំបាន រក្សាទុក) និងបានរក្សាទុកការគ្រប់គ្រង។ ដូច្នេះ អង្គភាពអនុវត្តវិធីសាស្ត្រ

នៃភាពជាប់ពាក់ពន្ធ័ជាបន្ត។

ដើម្បីអនុវត្តស្តង់ដានេះ អង្គភាពវិភាគប្រតិបត្តិការ (ក) ការរក្សាទុកភាគកម្មតាមចំណែកទាំងស្រុង ១០០០ ឯកតារូបិយវត្ថុ បូកថែម (ខ) ភាពបន្ទាប់បន្សំ នៃភាគកម្មបានរក្សាទុក ដើម្បីផ្តល់ឱ្យនូវភាព ល្អប្រសើរ នៃឥណទានចំពោះអ្នកទទួលការផ្ទេរសម្រាប់ការខាតបង់ឥណទាន។

អង្គភាពគណនាឃើញ ៩០៩០ ឯកតារូបិយវត្ថុ (៩០% Ů១០១០០) នៃតម្លៃតបសងដែលបានទទួលចំនួន ៩១១៥ ឯកតារូបិយវត្ថុ តំណាង ឱ្យតម្លៃតបសងស្មើនឹង ៩០%។ បរិមាណនៅសល់នៃតម្លៃតបសង ដែលបានទទួល (២៥ ឯកតារូបិយវត្ថុ) តំណាងឱ្យតម្លៃតបសងដែលបានទទួលសម្រាប់ភាពបន្ទាប់បន្សំនៃភាគកម្មបានរក្សាទុករបស់ខ្លួនដើម្បីផ្តល់នូវភាពល្អប្រសើខាងឥណទានចំពោះអ្នកទទួលការផ្ទេរ សម្រាប់ការខាតបង់ឥណ-ទាន។ បន្ថែមលើនោះ, កម្រិតចំណេញថែម០.៥% តំណាងឱ្យតម្លៃតបសងបានទទួលសម្រាប់ការធ្វើឱ្យប្រសើរឡើងនៃឥណទាន។ ជាមួយគ្នានេះតម្លៃតបសងសរុបដែលបានទទួលសម្រាប់ការធ្វើឱ្យប្រសើរឡើងនៃឥណទានគឺ ៦៥ឯកតារូបិយវត្ថុ (២៥ឯកតារូបិយវត្ថុ + ៤០ឯកតារូបិយវត្ថុ)។

អង្គភាពគណនាចំណេញឬខាតពីការលក់ចំណែកលំហូរសាច់ប្រាក់ដែលមាន ៩០%។ សន្មតថា តម្លៃសមស្របដាច់ដោយឡែកនៃចំណែក ៩០% បានផ្ទេរ និងចំណែក ១០% បានរក្សាទុកមិនមានទេនៅថ្ងៃនៃការផ្ទេរ,

អង្គភាព បែងចែកបរិមាណលើបញ្ជី នៃទ្រព្យសកម្មយោងតាម កថាខណ្ឌ ៣.២.១៤ ដូចខាង ក្រោមៈ

| | *តម្លៃសមស្រប ប៉ាន់ស្មាន* | *ភាគរយ* | *បរិមាណលើបញ្ជីបានបែងចែក* |
|---|---|---|---|
| ចំណែកបានផ្ទេរ | 9,090 | 90% | 9,000 |
| ចំណែកបានរក្សាទុក | 1,010 | 10% | 1,000 |
| **សរុប** | **10,100** | | **10,000** |

អង្គភាពគណនាចំណេញ ឬខាតលើការលក់ចំណែក ៩០% នៃលំហូរសាច់ប្រាក់ ដោយដកចេញបរិមាណលើបញ្ជីបានបែងចែក នៃចំណែកបានផ្ទេរពីតម្លៃតបសងដែលបានទទួល គឺថា (៩០៩០ឯកតារូបិយវត្ថុ - ៩០០០ ឯកតារូបិយវត្ថុ)។ បរិមាណលើបញ្ជីនៃចំណែកបានរក្សាទុក ដោយអង្គភាព គឺ ១០០០ ឯកតារូបិយវត្ថុ។

បន្ថែមលើនេះ អង្គភាពទទួលស្គាល់ភាពពាក់ពន្ធ័ជាបន្ត ដែលកើតចេញពីភាពបន្ទាប់បន្សំនៃភាគកម្ម បានរក្សាទុកសម្រាប់ការខាតបង់ឥណទាន។ ទន្ទឹមនឹងនេះ អង្គភាពទទួលស្គាល់ទ្រព្យសកម្ម ១០០០ ឯកតារូបិយវត្ថុ (បរិមាណអតិបរមានៃលំហូរសាច់ប្រាក់ដែលអង្គភាពនឹងមិនបានទទួលតាមការព្រមព្រៀងបន្ទាប់បន្សំ), ហើយបំណុលពាក់ពន្ធ័មានបរិមាណ ១០៥៦

ឯកតារូបិយវត្ថុ (ដែលជាបរិមាណអតិបរិមានៃនៃលំហូរសាច់ប្រាក់ ដែលអង្គភាពនឹងមិនបានទទួលតាមការព្រមព្រៀងបន្ទាប់បន្សំ នោះគឺ ១០០០ ឯកតារូបិយវត្ថុ បូកថែម តម្លៃសមស្របនៃកិច្ចព្រមព្រៀងបន្ទាប់បន្សំ ៦៥ ឯកតា រូបិយវត្ថុ)។

អង្គភាព ប្រើព័ត៌មានទាំងអស់ខាងលើ ដើម្បីកត់ត្រាប្រតិបត្តិការដូចខាងក្រោម:

| | *ឥណពន្ធ* | *ឥណទាន* |
|---|---|---|
| ទ្រព្យសកម្ម ដើម | – | 9,000 |
| ទ្រព្យសកម្មបានទទួលស្គាល់សម្រាប់ភាពបន្ទាប់បន្សំឬ ភាគកម្មសំណល់ | 1,000 | – |
| ទ្រព្យសកម្មសម្រាប់ការតបសងដែលបានទទួលជាទម្រង់កម្រិតចំណេញថែម | 40 | – |
| ចំណេញឬខាត (ចំណេញពីការផ្ទេរ) | – | 90 |
| បំណុល | – | 1,065 |
| សាច់ប្រាក់បានទទួល | 9,115 | – |
| **សរុប** | **10,155** | **10,155** |

ភ្លាមៗបន្ទាប់ពីប្រតិបត្តិការ តម្លៃលើបញ្ជីរបស់ទ្រព្យសកម្មគឺ ២០៤០

ឯកតារូបិយវត្ថុ ដែលរួមមាន១០០០ ឯកតារូបិយវត្ថុ តំណាងឲ្យថ្លៃដើម ដែលបានបែងចែក នៃចំណែកបានរក្សាទុក និង១០៤០ ឯកតារូបិយវត្ថុ តំណាងឲ្យភាពពាក់ពន្ធ័ជាបន្តបន្ថែមទៀតរបស់អង្គភាព ដែលបានពីភាព បន្ទាប់បន្សំនៃ ភាគកម្មបានរក្សាទុកសម្រាប់ការខាតបង់ឥណទាន (ដែលរួមមានកម្រិតចំណេញថែម ៤០ ឯកតារូបិយវត្ថុ)។

នៅក្នុងគ្រាជាបន្តបន្ទាប់អង្គភាពទទួលស្គាល់តម្លៃតបសងដែលបានទទួលសម្រាប់ការធ្វើឲ្យប្រសើរឡើងនៃឥណទាន (៦៥ ឯកតារូបិយវត្ថុ) ដោយផ្អែកលើចំណែក នៃពេលវេលា, បង្គរការប្រាក់លើទ្រព្យសកម្មដែលបានទទួលស្គាល់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ជាក់ស្តែង និងទទួលស្គាល់ការខូចខាតខាងឥណទានលើទ្រព្យសកម្មបានទទួលស្គាល់។ជាឧទាហរណ៍ សន្មតថា នៅឆ្នាំបន្ទាប់ មានការខារបង់ដោយការខូចខាតនៃឥណទាន លើប្រាក់កម្ចី ៣០០ ឯកតារូបិយវត្ថុ។ អង្គភាបកាត់បន្ថយទ្រព្យសកម្មបានទទួលស្គាល់របស់ខ្លួនចំនួន ៦០០ ឯកតារូបិយវត្ថុ (៣០០ ឯកតារូបិយវត្ថុពាក់ពន្ធ័ទៅនឹងការប្រាក់រក្សាទុក និង៣០០ ឯកតារូបិយវត្ថុ ពាក់ពន្ធ័នឹងការពាក់ពន្ធ័ជាបន្ត ដែលកើតចេញពីភាព បន្ទាប់បន្សំនៃការប្រាក់រក្សាទុករបស់ខ្លួនសម្រាប់ការខាតបង់ខាងឥណទាន), និងកាត់បន្ថយបំណុល បានទទួលស្គាល់របស់ខ្លួនចំនួន ៣០០ ឯកតារូបិយវត្ថុ។ លទ្ធផលសុទ្ធត្រូវបានដាក់បញ្ចូលទៅក្នុងចំណេញ ឬខាតសម្រាប់ការខូចខាត ខាងឥណទានចំនួន ៣០០ ឯកតារូបិយវត្ថុ។

## ការមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ (ផ្នែក ៣.៣)

១៣.៣.១ បំណុលហិរញ្ញវត្ថុ (ឬផ្នែកមួយនៃបំណុលហិរញ្ញវត្ថុ)ត្រូវបានរំលត់នៅពេលដែលកូនបំណុលៈ

(ក) បន្ទុបន្ថយបំណុល (ឬផ្នែកមួយនៃបំណុល) ដោយការសងម្ចាស់បំណុល ដែលជាធម្មតា គឺការសងជាសាច់ប្រាក់ ជាទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ជាទំនិញ ឬជាសេវាកម្ម ឬ

(ខ) ដកចេញ តាមផ្លូវច្បាប់ នូវការទទួលខុសត្រូវ ជាចំបងលើបំណុល (ឬផ្នែកមួយនៃបំណុល)តាមរយៈដំណើរការច្បាប់ ឬដោយម្ចាស់បំណុល។ (ប្រសិនបើ កូនបំណុលត្រូវបានផ្តល់ឲ្យនូវការធានាមួយ លក្ខខណ្ឌនេះនៅតែឆ្លើយតប)។

១៣.១.២ ប្រសិនបើ អ្នកបោះផ្សាយឧបករណ៍ បំណុលទិញ មកវិញនូវឧបករណ៍, បំណុលនោះត្រូវបានរំលត់ បើទោះបីជា អ្នកបោះផ្សាយបំណុល គឺជាអ្នកបង្កើតទីផ្សារ នៅក្នុងឧបករណ៍បំណុលនោះក្តី ឬមានបំណងលក់ទៅវិញនូវឧបករណ៍បំណុល នាពេលអនាគតដ៏ខ្លីខាងមុខ។

១៣.៣.៣ ការទូទាត់សងទៅភាគីទីបី, ដែលរួមមានទាំងត្រាស់ (trust) (ជួនកាលហៅថា “‘in-substance defeasance’) មិនធ្វើឲ្យធូរស្រាលដោយខ្លួន ដល់កូនបំណុលមានតព្វកិច្ចចំបងរបស់ខ្លួន

ចំពោះម្ចាស់បំណុលឡើយ នៅក្នុងពេលមិនមានការដកចេញតាមផ្លូវច្បាប់។

១៣.៣.៤ ប្រសិនបើ កូនបំណុលទូទាត់សងទៅភាគីទីបី ដើម្បីទទួលយកកាតព្វកិច្ចនិងធ្វើវិញ្ញត្តិទៅម្ចាស់បំណុលរបស់ខ្លួនថាភាគិទីបីបានទទួលយកកាតព្វកិច្ចបំណុល, កូនបំណុលទទួលស្គាល់កាតព្វបំណុលដរាបណាលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ ១៣.៣.១(ខ) ត្រូវបានឆ្លើយតប។ ប្រសិនបើ កូនបំណុលទូទាត់សង ទៅភាគីទីបីដើម្បីទទួលយកបំណុលនិងទទួលយកនូវការដកចេញ តាមផ្លូវច្បាប់ពីម្ចាស់បំណុលរបស់ខ្លួន,កូនបំណុលបានរំលត់នូវបំណុលនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនប់កូនបំណុលយល់ព្រមធ្វើការទូទាត់បំណូលទៅឱ្យ ភាគីទីបី ឬទូទាត់ដោយផ្ទាល់ទៅឱ្យម្ចាស់បំណុលដើម, កូនបំណុលត្រូវទទួលស្គាល់បំណុលថ្មីចំពោះភាគីទីបី។

១៣.៣.៥ ទោះបីជា មានការដកចេញតាមផ្លូវច្បាប់ក៏ដោយ ទោះជាតាមដោយច្បាប់ក្តី ឬដោយម្ចាស់បំណុលក្តី ក៏បង្ករឱ្យមានការមិនទទួលស្គាល់បំណុល, អង្គភាពអាចទទួលស្គាល់បំណុលថ្មីមួយប្រសិនបើ លក្ខណៈវិនិច្ឆ័យ នៃការមិនទទួលស្គាល់ នៅក្នុងកថាខណ្ឌ ៣.២.១-កថាខណ្ឌ៣.២.២៣ មិនឆ្លើយតប សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរ។ ប្រសិនបើ លក្ខណៈវិនិច្ឆ័យទាំងនោះមិនឆ្លើយតប ទ្រព្យសកម្មបានផ្ទេរមិនត្រូវបាន

ទទួលស្គាល់ឡើយហើយអង្គភាពទទួលស្គាល់បំណុលថ្មីពាក់ព័ន្ធនឹងទ្រព្យសកម្មបានផ្ទេរ។

ខ៣.៣.៦ សម្រាប់គោលបំណងកថាខណ្ឌ ៣.៣.២ លក្ខខណ្ឌនៃការសងនឹងមានភាពខុសគ្នាខ្លាំង ប្រសិនបើតម្លៃបច្ចុប្បន្ននៃលំហូរ សាច់ប្រាក់តាមលក្ខខណ្ឌថ្មី, ដោយរួមមានទាំងថ្លៃឈ្នួល ដែលបានបង់សុទ្ធនៃថ្លៃឈ្នួល ដែលបានទទួល និងកំណត់រកតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់ជាក់ស្តែង ដើមដំបូង ដែលមានយ៉ាងហោចណាស់ ១០% ខុសពីតម្លៃបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ដែលនៅសល់ នៃបំណុលហិរញ្ញវត្ថុដើមដំបូង។ ប្រសិនបើការដោះដូរឧបករណ៍បំណុល ឬការកែប្រែលក្ខខណ្ឌ ត្រូវបានរាប់បញ្ចូលថាជាការរំលត់បំណុល, ការចំណាយ ឬថ្លៃឈ្នួលណាមួយដែលកើតឡើងត្រូវបានទទួលស្គាល់ថាជាផ្នែកមួយ នៃចំណេញ ឬខាតលើការរំលត់បំណុល។ ប្រសិនបើ ការដោះដូរ ឬការកែប្រែណាមួយមិនត្រូវបានរាប់បញ្ចូលថាជា ការរំលត់បំណុលទេ ការចំណាយ ឬថ្លៃឈ្នួលណាមួយដែលកើតឡើងត្រូវកែសម្រួលនូវតម្លៃលើបញ្ជីនៃបំណុល និងត្រូវដករំលស់ តាមរយៈពេលនៅសល់នៃបំណុលដែលបានកែប្រែ។

ខ៣.៣.៧ ក្នុងករណីខ្លះ ម្ចាស់បំណុលដកចេញពីកូនបំណុលនូវកាតព្វកិច្ចបច្ចុប្បន្នសម្រាប់ការទូទាត់សង ប៉ុន្តែកូនបំណុល ត្រូវទទួលយក

តាពកិច្ចធានាសង ប្រសិនបើ ភាគីទទួលយកការទទួលខុសត្រូវចំបង បានបោកប្រាស់។ក្នុងកាលៈទេសៈទាំងនេះ កូនបំណុល÷

(ក) ទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មីផ្អែកលើតម្លៃសមស្រប នៃកាតព្វកិច្ចសម្រាប់ការធានា, និង

(ខ) ទទួលស្គាល់ចំណេញឬខាតផ្អែកលើភាពខុសគ្នារវាង (១) ទឹកប្រាក់ដែលបានបង់ និង (២) តម្លៃលើបញ្ជីនៃបំណុលហិរញ្ញវត្ថុ ដកចេញ តម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុថ្មី។

## ការធ្វើចំណាត់ថ្នាក់ (ជំពូក៤)

### ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ (ផ្នែក ៤.១)

### ម៉ូឌែលអាជីវកម្មរបសអង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ

ខ៤.១.១ កថាខណ្ឌ ៤.១.១(ក) តម្រូវឱ្យអង្គភាព ធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុដោយវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ ឬតាមតម្លៃសមស្របដោយផ្អែកលើមូលដ្ឋានគ្រឹះនៃម៉ូឌែលអាជីវកម្មរបស់អង្គភាពដូចបាកំណត់ដោយអ្នកគ្រប់គ្រងសំខាន់ៗ របស់អង្គភាព (ដូចបានកំណត់ នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ២៤)។

២៤.១.២ ម៉ូឌែលអាជីវកម្មរបស់អង្គភាពមិនអាស្រ័យលើចេតនា របស់អ្នកគ្រប់គ្រងសម្រាប់ឧបករណ៍ហិរញ្ញវត្ថុនិមួយៗឡើយ។ ព្រោះហេតុនោះលក្ខខណ្ឌនេះមិនមែនជាវិធីសាស្ត្រឧបករណ៍ហិរញ្ញវត្ថុដោយឧបករណ៍ហិរញ្ញវត្ថុសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើយ និងត្រូវបានកំណត់ដោយកម្រិត នៃការប្រមូលផ្តុំខ្ពស់ជាង។ទោះជាយ៉ាងណាអង្គភាពមួយអាចមានម៉ូឌែលអាជីវកម្មច្រើនសម្រាប់ការគ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ដូច្នេះ ការធ្វើចំណាត់ថ្នាក់ មិនចាំបាច់ត្រូវតែកំណត់ នៅកម្រិតនៃអង្គភាពរាយការណ៍ឡើយ។ ឧទាហរណ៍ អង្គភាពអាចរក្សាទុកចង្កោមនៃការវិនិយោគដែលខ្លួនគ្រប់គ្រងដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ហើយចង្កោម នៃការវិនិយោគផ្សេងទៀត ដែលអង្គភាពគ្រប់គ្រង ដើម្បីជួញដូរសម្រាប់ចំណេញដោយការប្រែប្រួលនៃតម្លៃសមស្រប។

២៣.១.៣ ទោះបីជាកម្មវត្ថុរបស់ម៉ូឌែលអាជីវកម្មរបស់អង្គភាព អាចត្រូវរក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុ ដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា, អង្គភាពមិនចាំបាច់ ត្រូវរក្សាទុកទាំងអស់នូវឧបករណ៍ហិរញ្ញវត្ថុរហូតដល់ពេលកំណត់សងនោះឡើយ។ ដូច្នេះ ម៉ូឌែលអាជីវកម្មរបស់អង្គភាពអាចត្រូវរក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា តែនៅពេលដែលការលក់ទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។ ឧទាហរណ៍ អង្គភាព អាចលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើៈ

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុលែងឆ្លើយតបទៅនឹងគោលនយោបាយវិនិយោគរបស់អង្គភាព (មានន័យថា កម្រិតឥណទានរបស់ទ្រព្យសកម្មធ្លាក់ចុះក្រោមកម្រិតដែលបានតម្រូវដោយគោលនយោបាយវិនិយោគរបស់អង្គភាព)

(ខ) អ្នកធានា អាចកែសម្រួលចង្កោមវិនិយោគរបស់ខ្លួនដើម្បីឆ្លុះបញ្ចាំង ការប្រែប្រួលរយៈពេលដែលរំពឹងទុក (មានន័យថាពេលវេលារំពឹងទុកសម្រាប់ការបង់សង) ឬ

(គ) អង្គភាពត្រូវការទុន សម្រាប់ការវិនិយោគ ទោះជាយ៉ាងណាប្រសិនបើចំនួន នៃការលក់មិនសូវជាទៀងទាត់ មានចំនួនច្រើនត្រូវបានធ្វើឡើងពីក្នុងចង្កោមនៃការវិនិយោគ, អង្គភាពត្រូវវាយតម្លៃថាការលក់មានសង្គតិភាពជាមួយគោលបំណងនៃការប្រមូលប្រាក់តាមកិច្ចសន្យាឬទេ និងថាតើ ការលក់មានសង្គតិភាពជាមួយគោលបំណងនៃការប្រមូលប្រាក់តាមកិច្ចសន្យាយ៉ាងដូចម្តេច?

ខ៣.១.៤ ខាងក្រោម គឺជាឧទាហរណ៍ នៅពេលដែលគោលបំណងរបស់ម៉ូឌែលអាជីវកម្មរបស់អង្គភាព អាចត្រូវបានរក្សាទុកទ្រព្យសកម្មដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។ បញ្ជីនៃឧទាហរណ៍នេះមិនអស់ត្រឹមនេះទេ។

| ឧទាហរណ៍ | ការវិភាគ |
|---|---|
| **ឧទាហរណ៍ ១**<br>អង្គភាពរក្សាទុកការវិនិយោគ ដើម្បីប្រមូលសាច់ប្រាក់ តាមកិច្ចសន្យា ប៉ុន្តែ នឹងលក់ការវិនិយោគនោះ នៅកាលៈទេសៈណាមួយ។ | ទោះជាយ៉ាងណា អង្គភាព អាចពិចារណានៅក្នុងចំណោមព័ត៌មានផ្សេងៗ អំពីតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឈរលើទស្សនទាននៃសាធនភាព (មានន័យថា បរិមាណ សាច់ប្រាក់ នឹងត្រូវបានទទួលស្គាល់ ប្រសិនបើ អង្គភាព ត្រូវលក់ទ្រព្យសកម្ម) គោលបំណងរបស់អង្គភាព គឺត្រូវរក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុ និងប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។ ការលក់ខ្លះនឹងមិនជំទាស់ទៅនឹងកម្មវត្ថុនោះឡើយ។ |

**ឧទាហរណ៍ ២**

ម៉ូឌែលអាជីវកម្មរបស់អង្គភាពគឺត្រូវទិញចង្កោម នៃទ្រព្យសកម្មហិរញ្ញវត្ថុដូចជាប្រាក់កម្ចី។ចង្កោមទ្រព្យសកម្ម ទាំងនោះអាច ឬមិនអាចរាប់បញ្ចូលទ្រព្យសកម្មដែលមានមកជាមួយ នូវការខាតបង់ខាងឥណទាន បានកើតឡើង។ ប្រសិនបើ ការទូទាត់សងប្រាក់កម្ចីនោះ មិនផ្អែកតាមពេលវេលា, អង្គភាពព្យាយាម ទាញយកសាច់ប្រាក់ តាមកិច្ចសន្យា តាមរយៈមធ្យោបាយជាច្រើនជាឧទាហរណ៍ ដោយការទាក់ទង ជាមួយកូនបំណុល តាមរយៈសំបុត្រ ទូរសព្ទ ឬ មធ្យោបាយផ្សេងៗទៀត។ក្នុងករណីខ្លះ អង្គភាព ធ្វើកិច្ចព្រមព្រៀង ដោះដូរអត្រា ការប្រាក់ ដើម្បី ដោះដូរអត្រា ការប្រាក់ ដោយផ្អែកលើទ្រព្យសកម្មហិរញ្ញ-

គោលបំណងរបស់ម៉ូឌែលអាជីវកម្ម គឺរក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុ និងប្រមូលនូវសាច់ប្រាក់ តាមកិច្ចសន្យា។ អង្គភាព មិនទិញចង្កោមទ្រព្យសកម្មដើម្បីលក់យកចំណេញនោះទេ។

ការវិភាគដូចគ្នានឹងត្រូវអនុវត្ត បើទោះបីជា អង្គភាព មិនរំពឹងថានឹងទទួលបាន រាល់សាច់ប្រាក់ទាំងអស់ តាមកិច្ចសន្យាក៏ដោយ (មានន័យថា ទ្រព្យសកម្មហិរញ្ញវត្ថុ ខ្លះមានការខាតបង់ខាងឥណទាន)។

ម៉្យាងវិញទៀត ការពិតដែលអង្គភាពបានធ្វើកិច្ចព្រមព្រៀងនិស្សន្ទដើម្បីកែប្រែ លំហូរសាច់ប្រាក់ របស់ចង្កោមទ្រព្យសកម្មមិនធ្វើឲ្យមានការផ្លាស់ប្ដូរដល់ ម៉ូឌែលអាជីវកម្ម របស់អង្គភាពឡើយ។ ប្រសិនបើ ចង្កោមនៃទ្រព្យសកម្មមិនត្រូវបានគ្រប់គ្រង ដោយមូលដ្ឋានតម្លៃសមស្រប,គោលបំណង

| | |
|---|---|
| វត្ថុជាក់លាក់នៅក្នុងចង្កោមទ្រព្យសកម្មហិរញ្ញវត្ថុដោយចាប់ពីអត្រាការប្រាក់ប្រែប្រួល ទៅអត្រាការប្រាក់ថេរ។ | របស់ម៉ូឌែល អាជីវកម្ម អាចនឹងត្រូវរក្សាទុកទ្រព្យសកម្មដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។ |
| **ឧទាហរណ៍៣**<br>អង្គភាព មានម៉ូឌែលអាជីវកម្មដែលមានគោលបំណងផ្ដល់ប្រាក់កម្ចីទៅឲ្យអតិថិជន ហើយបន្ទាប់មក លក់ប្រាក់កម្ចីទាំងនោះឲ្យទៅក្រុមហ៊ុនមូលបត្រ។ ក្រុមហ៊ុនមូលបត្រប្រកាស លក់ឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកវិនិយោគ។<br>អង្គភាពបង្កើតដំបូងគ្រប់គ្រងលើក្រុមហ៊ុនលក់មូលបត្រ និងហេតុដូច្នេះ រួមបញ្ចូលជាមួយគ្នា។<br>ក្រុមហ៊ុនមូលបត្រប្រមូលសាច់ប្រាក់តាមកិច្ចសន្យាពីប្រាក់កម្ចី ហើយផ្ទេរវាទៅឲ្យអ្នកវិនិយោគ។<br>គេសន្មតថា សម្រាប់គោល | ក្រុមហ៊ុនរួមដែលបានផ្ដល់ប្រាក់កម្ចី ដោយមានគោលបំណងរក្សាទុកដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។<br>ទោះជាយ៉ាងណាក្ដី អង្គភាពដើមមានគោលបំណងទទួលស្គាល់សាច់ប្រាក់លើចង្កោម នៃប្រាក់កម្ចី ដោយការលក់ប្រាក់កម្ចី ទៅឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ, ដូច្នេះសម្រាប់គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក គេមិនគិតថានឹងគ្រប់គ្រងចង្កោមវិនិយោគនេះ ដើម្បីប្រមូលប្រាក់ តាមកិច្ចសន្យា នោះឡើយ។ |

| | |
|---|---|
| បំណងនៃឧទាហរណ៍នេះ ប្រាក់កម្ចីត្រូវបន្តទទួលស្គាល់ក្នុងរបាយការណ៍រួមស្តីពីស្ថានភាពហិរញ្ញវត្ថុ ដោយ សារតែពួកវាមិនត្រូវបានមិនទទួលស្គាល់ ដោយក្រុមហ៊ុនលក់មូលបត្រ។ | |

ខ៣.១.៥ ម៉ូឌែលអាជីវកម្មមួយដែលមានគោលបំណងមិនរក្សាទុក ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីប្រមូលសាច់ប្រាក់ តាមកិច្ចសន្យា គឺជាអង្គភាពគ្រប់គ្រងលទ្ធផលនៃចង្កោមវិនិយោគទ្រព្យសកម្មហិរញ្ញវត្ថុ ជាមួយនឹងកម្មវត្ថុនៃការទទួលស្គាល់លំហូរសាច់ប្រាក់ តាមរយៈនៃការលក់ទ្រព្យសកម្ម។ ឧទារហណ៍ ប្រសិនបើ អង្គភាពគ្រប់គ្រងយ៉ាងសកម្មចង្កោម នៃការវិនិយោគទ្រព្យសកម្ម ដើម្បីទទួលស្គាល់បម្រែបម្រួលតម្លៃសមស្រប ដែលកើតចេញពីបម្រែបម្រួលនៃគំលាតឥណទាននិងអត្រាចំណេញ, ម៉ូឌែលអាជីវកម្មរបស់អង្គភាព គឺមិនមែនរក្សាទុក ទ្រព្យសកម្មទាំងនោះ ដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យានោះឡើយ។ គោលបំណងរបស់អង្គភាពគឺការទិញនិងការលក់យ៉ាងសកម្ម ហើយអង្គភាពកំពុង

គ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុដើម្បីទទួលស្គាល់ចំណេញ ពីតម្លៃសមស្របជាជាងការប្រមូលប្រាក់តាមកិច្ចសន្យា។

ខ៤.១.៦ ចង្កោមទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានគ្រប់គ្រង ហើយដែលលទ្ធផលរបស់វាត្រូវបានវាយតម្លៃ តាមមូលដ្ឋានតម្លៃសមស្រប (ដូច បរិយាយក្នុងកថាខណ្ឌ៤.២.២(ខ)) គឺមិនមែនរក្សាទុកសម្រាប់ ប្រមូលសាច់ប្រាក់តាមកិច្ចសន្យាឡើយ។ ជាមួយគ្នានេះ ចង្កោមទ្រព្យសកម្មហិរញ្ញវត្ថុដែលឆ្លើយតបទៅនឹងនិយមន័យនៃការរក្សាទុកសម្រាប់ការជួញដូរគឺមិនមែនរក្សាទុកសម្រាប់ប្រមូលសាច់ប្រាក់ តាមកិច្ចសន្យាឡើយ។ ចង្កោមនៃឧបករណ៍ហិរញ្ញវត្ថុបែបនេះត្រូវតែវាស់វែង តាមតម្លៃសមស្រប និងទទួលស្គាល់ជាចំណេញ ឬខាតនៅចុងការិយបរិច្ឆេទ។

## សាច់ប្រាក់តាមកិច្ចសន្យាដែលត្រូវបង់សងទាំងប្រាក់ដើមនិងការប្រាក់តែម្តងគត់ដោយផ្អែកលើប្រាក់ដើមនៅសល់

ខ៤.១.៧ កថាខណ្ឌ ៤.១.១ តម្រូវឱ្យអង្គភាព (លើកលែងតែកថាខណ្ឌ ៤.១.៥ អនុវត្តន៍) ធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុដោយត្រូវវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ឬតាមតម្លៃសមស្របដោយផ្អែកលើចរិតលក្ខណៈសំហូរសាច់ប្រាក់ តាមកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលគ្រប់គ្រងសម្រាប់ការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

១៤.១.៨ អង្គភាពត្រូវវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់តែមួយគត់នៃប្រាក់ដើម និងការប្រាក់ដោយផ្អែកលើបរិមានប្រាក់ដើមនៅជាប់ជំពាក់សម្រាប់រូបិយវត្ថុ ដែលប្រើលើទ្រព្យសកម្មហិរញ្ញវត្ថុនោះ (មើល កថាខណ្ឌ ខ៥.៧.២)។

១៤.១.៩ អានុភាព គឺជាចរិតលក្ខណៈលំហូរសាច់ប្រាក់ តាមកិច្ចសន្យាសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួន។ អានុភាពធ្វើឲ្យកើនភាពងាយប្រែប្រួលនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាជាមួយនឹងលទ្ធផលដែលពួកវាមិនមានចរិតលក្ខណៈសេដ្ឋកិច្ចនៃ ភាគកម្ម។ សិទ្ធិជម្រើសតែឯកឯង, កិច្ចសន្យាដោះដូរ និងអនាគត គឺជាឧទាហរណ៍អំពីទ្រព្យសកម្មហិរញ្ញវត្ថុដែលរួមបញ្ចូលនូវអានុភាព។ កិច្ចសន្យាបែបនេះ មិនឆ្លើយតបទៅនឹង លក្ខខណ្ឌ នៅក្នុងកថាខណ្ឌ៤.១.២(ខ)ឡើយ ហើយដែលក្រោយមកមិនអាចវាស់វែងតាមតម្លៃដករំលស់ឡើយ។

១៤.១.១០ មាត្រានានា នៃកិច្ចសន្យា ដែលអនុញ្ញាតិឲ្យអ្នកបោះផ្សាយ (មានន័យថា កូនបំណុល) ត្រូវបង់មុននូវឧបករណ៍បំណុល (គឺ ប្រាក់កម្ចីឬសញ្ញាប័ណ្ណ) ឬអនុញ្ញាតិឲ្យអ្នកកាន់កាប់ (គឺ ម្ចាស់បំណុល) ដាក់ឧបករណ៍បំណុលទៅឲ្យអ្នកបោះផ្សាយវិញមុនពេលដល់កាលបរិច្ឆេទកំណត់សង នឹងធ្វើឲ្យលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជាការទូទាត់តែម្តងគត់នៃប្រាក់ដើម និងការប្រាក់ដោយផ្អែកលើបរិមាណប្រាក់ដើមនៅជាប់ជំពាក់ តែក្នុងករណីដែលៈ

(ក) មាត្រានៅក្នុងកិច្ចសន្យា មិនជាយថាហេតុ សម្រាប់ព្រឹត្តិ-ការណ៍នាពេលអនាគត,ជាជាងដើម្បីការពារៈ

(១)អ្នកកាន់កាប់ពីការខូចខាតឥណទានរបស់អ្នកបោះផ្សាយ (ការមិនសង, ការធ្លាក់ចុះចំណាត់ថ្នាក់ឥណទាន, ការរំលោភកិច្ចព្រមព្រៀងប្រាក់កម្ចី), ឬ

(២)អ្នកកាន់កាប់ ឬអ្នកបោះផ្សាយទៅនឹង កាផ្លាស់ប្តូរខាងពន្ធដារឬច្បាប់ និង

(ខ)បរិមាណទឹកប្រាក់ នៃការទូទាត់មុន ជាចំនួនដ៏ច្រើន នៃបរិមាណមិនទាន់បានបង់នៃប្រាក់ដើមនិងការប្រាក់ ដែលនៅជាប់ជំពាក់ ដែលអាចរួមបញ្ចូលនូវការតបសងបន្ថែមសមហេតុផល សម្រាប់ការបញ្ចប់កិច្ចសន្យា មុនពេលកំណត់។

ខ៤.១.១១ មាត្រានៃកិច្ចសន្យា ដែលអនុញ្ញាតិឲ្យអ្នកកាន់កាប់ ឬអ្នកបោះផ្សាយ ពន្យារយៈពេលនៃឧបករណ៍បំណុល (គឺជម្រើសនៃការពន្យាដែលនឹងធ្វើឲ្យមានលំរុះសាច់ប្រាក់តាមមកិច្ចសន្យាដែលជាការទូទាត់តែម្តងគត់នៃប្រាក់ដើមនិងការប្រាក់ដោយ ផ្អែកលើប្រាក់ដើមនៅជាប់ជំពាក់ តែក្នុងករណីដែលៈ

(ក) មាត្រានៅក្នុងកិច្ចសន្យាមិនជាយថាហេតុសម្រាប់ព្រឹត្តិការណ៍នាពេលអនាគត, ជាជាងដើម្បីការពារៈ

(១)អ្នកកាន់កាប់ពីការខូចខាតឥណទានរបស់អ្នកបោះផ្សាយ (ការមិនសង, ការធ្លាក់ចុះចំណាត់ថ្នាក់ ឥណទាន, ការរំលោភ កិច្ចព្រមព្រៀងប្រាក់កម្ចី), ឬ

(២)អ្នកកាន់កាប់ឬអ្នកបោះផ្សាយ ទៅនឹងកាផ្លាស់ប្តូរខាងពន្ធដារឬច្បាប់, និង

(ខ) ពេលវេលានៃជម្រើស សម្រាប់ការពន្យាបាននាំឱ្យ លំហូរសាច់ប្រាក់តាមកិច្ចសន្យា ក្នុងអំឡុងរយៈពេល នៃការពន្យាដែលការទូទាត់តែម្តងគត់នៃប្រាក់ដើមនិងការប្រាក់ ដោយផ្អែកលើបរិមាណប្រាក់ដើមនៅជាប់ជំពាក់។

ខ៤.១.១២លក្ខខណ្ឌ នៃកិច្ចសន្យា ដែលធ្វើឱ្យផ្លាស់ប្តូរពេលវេលា និងបរិមាណ នៃការទូទាត់ប្រាក់ដើមឬការប្រាក់មិនបណ្តាលឱ្យលំហូរសាច់ប្រាក់តាមកច្ចសន្យាដែលជាការទូទាត់តែម្តងគត់ នៃប្រាក់ដើមនិងការប្រាក់ ដោយផ្អែកលើបរិមាណប្រាក់ដើម នៅជាប់ជំពាក់ ដរាបណា វាៈ

(ក) ជាអត្រាការប្រាក់ប្រែប្រួល ដែលជាការតបសង សម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់និងហានិភ័យឥណទាន (អាចត្រូវបានកំណត់នៅពេលនៃការទទួលស្គាល់លើកដំបូង

ប៉ុណ្ណោះ, និងហេតុដូច្នេះវានឹងជាអត្រាថេរ) ដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់, និង

(ខ) ប្រសិនបើ លក្ខខណ្ឌនៃកិច្ចសន្យាគឺជាជម្រើសនៃការទូទាត់មុន ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ ខ៤.១.១០ ឬ

(គ) ប្រសិនបើ លក្ខខណ្ឌនៃកិច្ចសន្យា គឺជាជម្រើសនៃការពន្យាពេល ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ ខ៤.១.១១។

ខ៤.១.១៣ ឧទាហណ៍ខាងក្រោមពន្យល់ពីលំហូរសាច់ប្រាក់ តាមកិច្ចសន្យាដែលជាការទូទាត់តែមួងគត់នៃប្រាក់ដើមនិងការប្រាក់ ដោយផ្អែកលើបរិមាណប្រាក់ដើមនៅជាប់ជំពាក់។

ឧទាហរណ៍ទាំងនេះមិនកំណត់ត្រឹមនេះឡើយ។

| ឧបករណ៍ហិរញ្ញវត្ថុ | ការវិភាគ |
|---|---|
| **ឧបករណ៍ហិរញ្ញវត្ថុ A**<br>ឧបរកណ៍ហិរញ្ញវត្ថុ A គឺជាសញ្ញាប័ណ្ណដែលមានចែងអំពីកាលបរិច្ឆេទដល់កំណត់សង។ ការទូទាត់ប្រាក់ដើម និងការប្រាក់ ដោយផ្អែកលើបរិមាណប្រាក់ដើម នៅជាប់ជំពាក់ត្រូវបានភ្ជាប់ទៅនឹងសន្ទស្សអតិផរណារបស់រូបិយវត្ថុ ដែលប្រើក្នុង ឧបករណ៍ហិរញ្ញវត្ថុនោះ។ ការភ្ជាប់ជាមួយ អតិផរណាមិនមានអានុភាពទេ។ ហើយប្រាក់ដើមត្រូវបានការពារ។ | លំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់តែម្តងគត់ នៃប្រាក់ដើមនិងការប្រាក់ដោយផ្អែកលើប្រាក់ដើមនៅជាប់ជំពាក់។ ការទូទាត់នៃប្រាក់ដើមនិងការប្រាក់ដោយផ្អែកលើប្រាក់ដើមនៅជាប់ជំពាក់ ដែលមានការតភ្ជាប់ទៅ នឹងសន្ទស្សអតិផរណាដែលគ្មានអានុភាព បានកំណត់ឡើងវិញអំពីតម្លៃ នៃទឹកប្រាក់ទៅកម្រិតបច្ចុប្បន្នវិញ។ ម៉្យាងទៀត អត្រាការប្រាក់លើឧបករណ៍ហិរញ្ញវត្ថុ ឆ្លុះបញ្ចាំង អំពីការប្រាក់ "ពិត"។ ដូច្នេះ បរិមាណការប្រាក់ គឺជាតម្លៃតបសងសម្រាប់តម្លៃនៃទឹកប្រាក់លើប្រាក់ដើមដែលនៅជាប់ជំពាក់។<br>ក៏ប៉ុន្តែ ប្រសិនបើការទូទាត់ការប្រាក់ត្រូវបានធ្វើជាសន្ទស្សជាមួយអថេរផ្សេងទៀត ដូចជា លទ្ធផលរបស់កូនបំណុល (គឺប្រាក់ចំណេញរបស់កូនបំណុល) ឬសន្ទស្សទ្រព្យម្ចាស់, លំហូរសាច់ប្រាក់ តាមកិច្ច |

| | |
|---|---|
| | សន្យាមិនមែនជាការទូទាត់ប្រាក់ដើម និងការប្រាក់ ដោយផ្អែកលើប្រាក់ដើម នៅជាប់ជំពាក់ឡើយ។នោះគឺដោយសារតែការទូទាត់ការប្រាក់ មិនមែនជាការតបសងទៅនឹងតម្លៃនៃទឹកប្រាក់ ហើយហានិភ័យឥណទានដែលជាប់ពាក់ពន្ធ័នឹងប្រាក់ដើមដែលនៅជាប់ជំពាក់។ មានវិបរិណាមភាពនៅក្នុងការទូទាត់ការប្រាក់ តាមកិច្ចសន្យាដែលមិនមានសង្គតិភាពជាមួយអត្រាការប្រាក់ទីផ្សារ។ |

**ឧបករណ៍ហិរញ្ញវត្ថុ B**

ឧបករណ៍ហិរញ្ញវត្ថុ B គឺជាឧបករណហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ ប្រែប្រួលជាមួយនឹង កាលបរិច្ឆេទដល់កំណត់សង ដែលបានចែងមួយ ដែលអនុញ្ញាតិឲ្យ អ្នកខ្ចីជ្រើសរើស អត្រាការប្រាក់ ដោយផ្អែកលើមូលដ្ឋាន និរន្តរភាព។ ឧទាហរណ៍ នៅតាមអត្រាការប្រាក់និមួយៗ មានការកំណត់ឡើងវិញនូវកាលបរិច្ឆេទ អ្នកខ្ចីអាចជ្រើសរើសបង់អត្រាការប្រាក់ LIBOR សម្រាប់រយៈពេលបីខែ ចំពោះរយៈពេលខ្ចីចំនួនបីខែ ឬ អត្រាការប្រាក់ LIBOR សម្រាប់រយៈពេលមួយខែ ចំពោះរយៈពេលខ្ចី ចំនួនមួយខែ។

លំហូរសាច់ប្រាក់ តាមិច្ចសន្យា គឺជាការទូទាត់តែម្តងគត់នៃប្រាក់ដើមនិងការប្រាក់ដោយផ្អែកលើប្រាក់ដើម ដែលនៅជាប់ជំពាក់ ហូតដល់ការប្រាក់ ដែលបានបង់ទៅតាមអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុឆ្លុះបញ្ចាំងនូវ ការតបសង នៃតម្លៃទឹកប្រាក់ និង សម្រាប់ហានិភ័យឥណទាន ដែល ជាប់ពាក់ពន្ធ័នឹងឧបករណ៍ហិរញ្ញវត្ថុនោះ។ ក្នុងករណីដែល អត្រាការប្រាក់ LIBOR ត្រូវបានកំណត់ឡើងវិញ អំឡុងពេល នៃអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុមិនធ្វើឲ្យ បាត់គុណវិឌ្ឍន៍ ឧបករណ៍ហិរញ្ញវត្ថុនោះឡើយ។

ក៏ប៉ុន្តែ ប្រសិនបើ អ្នកខ្ចីអាចជ្រើសរើសសងតាមអត្រាការប្រាក់ LIBOR មួយខែ សម្រាប់ការជំពាក់រយៈពេលបីខែ ហើយ អត្រាការប្រាក់ LIBOR មួយខែ មិនត្រូវបានកំណត់ឡើងវិញនៅខែនិមួយៗ នោះទេ លំហូរសាច់ប្រាក់តាមកិច្ចសន្យា មិនមែនជាការទូទាត់សងប្រាក់ដើម និងការ

| | |
|---|---|
| | ប្រាក់នោះទេ។<br><br>ការវិភាគដូចគ្នានឹងអនុវត្ត ប្រសិនបើអ្នកខ្ចី អាចជ្រើសរើស "អត្រាការប្រាក់ប្រែប្រួលមួយសម្រាប់រយៈពេលមួយខែ" និង "អត្រាការប្រាក់ ប្រែប្រួលមួយ សម្រាប់រយៈពេល បីខែ" ដែលបានបោះផ្សាយដោយអ្នកឲ្យខ្ចី។<br>ទោះជាយ៉ាងណា ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុ មានអត្រាការប្រាក់ តាមកិច្ចសន្យាដែលផ្អែកលើរយៈពេលដែលលើសពីអាយុកាល នៅសល់របស់ ឧបករណ៍ហិរញ្ញវត្ថុ, លំហូរសាច់ប្រាក់ តាមកិច្ចសន្យារបស់វា មិនមែនជាការទូទាត់ ប្រាក់ដើម និងការប្រាក់ ដោយផ្អែកលើប្រាក់ដើមនៅជាប់ជំពាក់នោះឡើយ។ ឧទាហរ-ណ៍ សញ្ញាបណ្ណដែលមាន អាយុកាលដល់កំណត់សងក្នុងរយៈពេលប្រាំឆ្នាំ ដែលត្រូវបង់អត្រា ការប្រាក់ប្រែប្រួល ត្រូវបានកំណត់ ជាថ្មីឡើងវិញ តាមរយៈពេលកំ |

| | |
|---|---|
| | ណត់ តែជានិច្ចកាលត្រូវឆ្លុះបញ្ចាំង អំពីអាយុ កាលដល់កំណត់សង រយៈពេលប្រាំឆ្នាំ នឹងមិនធ្វើឲ្យលំហូរ សាច់ប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់សងនៃប្រាក់ដើម និងការប្រាក់ ដោយផ្អែកលើប្រាក់ដើម នៅជាប់ជំពាក់ឡើយ។ នូវក៏ដោយសារតែបំណុលការប្រាក់នៅក្នុងគ្រានិមួយៗ មិនជាប់ពាក់ពន្ធ័ នឹងរយៈពេលរបស់ឧបករណ៍បំណុលឡើយ (លើកលែងតែរយៈពេលដើម) |

| | |
|---|---|
| **ឧបករណ៍ហិរញ្ញវត្ថុ C**<br>ឧបករណ៍ហិរញ្ញវត្ថុ C គឺជាសញ្ញាបណ្ណ ដែលមានកាលបរិច្ឆេទ ដល់កំណត់សង និងអត្រាការប្រាក់ប្រែប្រួល របស់ទីផ្សារ។ អត្រាការប្រាក់ ប្រែប្រួលនោះមានកម្រិតខ្ពស់។ | លំហូរសាច់ប្រាក់តាមកិច្ចសន្យា ទាំងពីរៈ<br>(ក)ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ថេរ និង<br>(ខ)ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ប្រែប្រួល គឺជាការទូទាត់សងនៃប្រាក់ដើម និងការប្រាក់ ដោយផ្អែកលើប្រាក់ដើមសល់ ដរាបណា ការប្រាក់ឆ្លុះបញ្ចាំងផលតបសងសម្រាប់ពេលវេលានៃការប្រើប្រាស់លុយ និងសម្រាប់ហានិភ័យដែលពាក់ពន្ធ័នឹងឧបករណ៍ហិរញ្ញវត្ថុក្នុងអំឡុងពេល របស់ឧបករណ៍ហិរញ្ញវត្ថុនោះ។<br>ហេតុដូច្នេះ ឧបករណ៍ហិរញ្ញវត្ថុមួយដែលជាការត្រួបផ្សំ(ក) និង (ខ) (ឧ.សញ្ញាបណ្ណដែលមានកំហិតអត្រាការប្រាក់) អាចមានលំហូរសាច់ប្រាក់ ដែលជាការទូទាត់ តែមួយគត់នៃប្រាក់ដើម និងការប្រាក់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់។លក្ខណៈបែបនេះ អាចបន្ថយភាពប្រែប្រួល នៃសាច់ប្រាក់ដោយការដាក់កម្រិតលើអត្រា |

| | |
|---|---|
| | ការប្រាក់ប្រែប្រួល (កម្រិតខ្ពស់ ឬកម្រិតទាបនៃអត្រាការប្រាក់) ឬបង្កើនភាពប្រែប្រួលនៃសាច់ប្រាក់ ពីព្រោះតែអត្រាការប្រាក់ថេរក្លាយទៅជា អត្រាការប្រាក់ប្រែប្រួលវិញ។ |
| **ឧបករណ៍ហិរញ្ញវត្ថុ D**<br>ឧបករណ៍ហិរញ្ញវត្ថុ D គឺជាប្រាក់កម្ចី មានទ្រព្យដាក់បញ្ចាំពេញលេញ និងត្រូវបានធានាដោយទ្រព្យបញ្ចាំ។ | ជាហេតុការណ៍ពិត ដែលថាប្រាក់កម្ចីមានទ្រព្យបញ្ចាំពេញលេញ គឺត្រូវបានធានាដោយទ្រព្យបញ្ចាំ ដោយខ្លួនវាផ្ទាល់មិនមានផលប៉ះពាល់ដល់ លើការវិភាគថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់តែមួយគត់ នៃប្រាក់ដើម និងការប្រាក់ផ្អែកលើប្រាក់ដើមនៅសល់។ |

៦៤.១.១៤ ឧទាហរណ៍ ខាងក្រោមពន្យល អំពីលំហូរសាច់ប្រាក់ តាមកិច្ចសន្យា ដែលមិនមែនជាការទូទាត់ប្រាក់ដើម និងការប្រាក់ផ្អែកលើបរិមាននៅសល់។បញ្ជីនៃឧទាហរណ៍នេះមិមល្អិតល្អន់ទេ។

| ឧបករណ៍ហិរញ្ញវត្ថុ | ការវិភាគ |
|---|---|
| **ឧបករណ៍ហិរញ្ញវត្ថុ E**<br>ឧបករណ៍ហិរញ្ញវត្ថុ Eគឺជាសញ្ញាបណ្ណ ដែលអាចបំប្លែងឲ្យទៅជាឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់របស់ក្រុមហ៊ុនបោះផ្សាយ។ | អ្នកកាន់កាប់នឹងវិភាគសញ្ញាបណ្ណ អាចបំប្លែងបានទាំងស្រុងរបស់វា។ លំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនមែនជាការទូទាត់ប្រាក់ដើមនិងការប្រាក់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់ឡើយ ពីព្រោះអត្រាការប្រាក់មិនឆ្លុះបញ្ចាំង ផលតបសងនៃតម្លៃពេលវេលារបស់ទឹកប្រាក់និងហានិភ័យឥណទាន។<br>ផលចំណេញ នឹងត្រូវភ្ជាប់ទៅនឹង តម្លៃរបស់មូលធនផ្ទាល់ របស់ក្រុមហ៊ុនបោះផ្សាយ។ |
| **ឧបករណ៍ហិរញ្ញវត្ថុ F**<br>ឧបករណ៍ហិរញ្ញវត្ថុ F គឺជាប្រាក់កម្ចី ដែលបង់អត្រា ការប្រាក់អណ្តែតវិលោម(មានន័យថាអត្រា | លំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនមែនជាការទូទាត់តែមួយគត់នៃប្រាក់ដើមនិងការប្រាក់ ផ្អែកលើបរិមាណប្រាក់ដើមនៅសល់។ |

| | |
|---|---|
| ការប្រាក់មានទំនាក់ទំនងវិលោម ទៅនឹង អត្រាការប្រាក់របស់ទីផ្សារ)។ | បរិមាណអត្រាការប្រាក់ មិនមែនជាផលតបសងនៃតម្លៃពេលវេលារបស់ទឹកប្រាក់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់។ |
| **ឧបករណ៍ហិរញ្ញវត្ថុ G**<br>ឧបករណ៍ហិរញ្ញវត្ថុ G គឺជាឧបករណ៍ហិរញ្ញវត្ថុនិរន្តន៍ ប៉ុន្តែក្រុមហ៊ុនបោះផ្សាយ អាចទិញឧបករណ៍ហិរញ្ញវត្ថុ នោះមកវិញនៅពេលណាមួយ និងសងទៅអ្នកកាន់កាប់ នូវបរិមាណតាមតម្លៃ ឯកតាបូកថែម ការប្រាក់បង្គរត្រូវសង។<br>ឧបករណ៍ហិរញ្ញវត្ថុ G បង់អត្រាការប្រាក់ទីផ្សារ ប៉ុន្តែការទូទាត់ការប្រាក់ មិនអាចធ្វើបានឡើយដរាបណា ក្រុមហ៊ុនហ៊ុន បោះផ្សាយអ្នករក្សាបាននូវសាធនភាពភ្លាមៗ បន្ទាប់ពីនោះការប្រាក់ពន្យាមិនបង្គរជាការប្រាក់បន្ថែមឡើយ។ | លំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនមែនជាការទូទាត់ប្រាក់ដើមនិងការប្រាក់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់។នោះគឺដោយសារតែក្រុមហ៊ុនបោះផ្សាយ អាចត្រូវបានតម្រូវឱ្យពន្យាការទូទាត់សងការប្រាក់ ហើយការប្រាក់បន្ថែមមិនបង្គរលើបរិមាណការប្រាក់ពន្យាទាំងនោះឡើយ។ ប្រសិនបើការប្រាក់បានបង្គរលើបរិមាណពន្យា នោះលំហូរសាច់ប្រាក់ តាមកិច្ចសន្យា អាចជាការទូទាត់ នៃប្រាក់ដើម និងការប្រាក់ ដែលផ្អែកលើ បរិមាណប្រាក់ដើមនៅសល់។ |

| | |
|---|---|
| | ជាការពិត ឧបករណ៍ហិរញ្ញវត្ថុ G គឺជាឧបករណ៍ហិរញ្ញវត្ថុនិរន្តន៍ ដែលមិនមានន័យដោយខ្លួនវាថាជា លំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺមិនមែនជា ការទូទាត់ប្រាក់ដើមនិងការប្រាក់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់។ជាធរមានឧបករណ៍ហិរញ្ញវត្ថុនិរន្តន៍ មានជម្រើសរិបុលកម្មបន្ត(ពហុគុណ)។ ជម្រើសបែបនេះអាចជាផល នៃលំហូរសាច់ប្រាក់ តាមកិច្ចសន្យាដែលជាការទូទាត់នៃប្រាក់ដើមនិងការប្រាក់ ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់ ប្រសិនបើ ការទូទាត់ការប្រាក់គឺ ស្ថិតនៅក្រោមអាណត្តិ និងត្រូវតែបង់ជានិរន្តន៍។ |
| | ជាមួយនេះផងដែរ ជាការពិតដែលថាឧបករណ៍ហិរញ្ញវត្ថុ G អាចត្រូវបានទិញមកវិញ មិនមានន័យថា លំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនមែនជាការទូទាត់ប្រាក់ដើមនិងការប្រាក់ ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់ឡើយដរាប- |

| | |
|---|---|
| | ណា វាអាចត្រូវបានគេទិញមកវិញតាមបរិមាណមួយដែលមិនបានឆ្លុះបញ្ចាំងជាដុំកំភួននូវការទូទាត់ប្រាក់ដើម និងការប្រាក់លើ ប្រាក់ដើមនោះ។ បើទោះជាយ៉ាង បរិមាណអាចទិញមកវិញរួមមាននូវបរិមាណ ដែលតបសងដល់អ្នកកាន់កាប់សម្រាប់ការបញ្ចប់មុន នៃឧបករណ៍ហិរញ្ញវត្ថុលំហូរសាច់ប្រាក់តាមកិច្ចសន្យាអាចជាការទូទាត់ប្រាក់ដើមនិងការប្រាក់ដែលផ្អែកលើ បរិមាណប្រាក់ដើមនៅសល់។ |

ខ៤.១.១៥ នៅក្នុងករណីខ្លះ ទ្រព្យសកម្មហិរញ្ញវត្ថុ អាចមានលំហូរសាច់ប្រាក់តាមកិច្ចសម្យា ដែលត្រូវបានបរិយាយថាជាប្រាក់ដើម និងការប្រាក់ ប៉ុន្តែលំហូរសាច់ប្រាក់ទាំងនោះមិនតំណាងឲ្យ ការទូទាត់ប្រាក់ដើមនិងការប្រាក់ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់ ដូចបានបរិយាយនៅក្នុង កថាខណ្ឌ ៤.១.២(ខ) និង កថាខណ្ឌ ៤.១.៣នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះ។

ខ៤.១.១៦ នេះអាជាករណី ប្រសិនបើ ទ្រព្យសកម្មហិរញ្ញវត្ថុតំណាងឲ្យការវិនិយោគនៅក្នុងទ្រព្យសកម្ម ឬលំហូរសាច់ប្រាក់ណាមួយ ដូច្នេះ

ហើយ លំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺមិនមែនតែជាការទូទាត់ប្រាក់ដើមនិងការប្រាក់លើប្រាក់ដើមដែលនៅសល់ប៉ុណ្ណោះទេ។ ឧទាហរណ៍ លំហូរសាច់ប្រាក់តាមកិច្ចសន្យាអាចរួមមានការទូទាត់សម្រាប់កត្តានានា ដែលមិនមែនជាផលតបសងសម្រាប់ ពេលវេលានៃតម្លៃទឹកប្រាក់និងសម្រាប់ហានិភ័យឥណទានដែលពាក់ពន្ធ័ជាមួយនឹងបរិមាណប្រាក់ដើម នៅសល់ក្នុងអំឡុងពេល នៃការិយបរិច្ឆេទណាមួយ។ជាលទ្ធផល ឧបករណ៍ហិរញ្ញវត្ថុនឹងមិនបំពេញលក្ខខណ្ឌនៅក្នុងកថាខណ្ឌ៤.១.២(ខ)ឡើយ។ នេះអាចជាករណីនៅពេលដែល ការទាមទាររបស់ម្ចាស់បំណុល មានកំណត់ ចំពោះទ្រព្យសកម្មជាក់លាក់ណាមួយរបស់កូនបំណុល ឬចំពោះសច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ឧទាហរណ៍ទ្រព្យសកម្មហិរញ្ញវត្ថុ “គ្មានឧបករណ៍ជួយដោះបន្ទាល់”)។

ខ៤.១.១៧ទោះបីជាយ៉ាងណា ហេតុករណ៍ពិតដែលថាទ្រព្យសកម្មហិរញ្ញវត្ថុគឺជាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលគ្មានឧបករណ៍ជួយដោះបន្ទាល់ដោយខ្លួនវាមិនហាមឃាត់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ ពីការឆ្លើយតបទៅនឹងលក្ខខណ្ឌក្នុងកថាខណ្ឌ៤.១.២(ខ)។ នៅក្នុងស្ថានភាពបែបនេះ ម្ចាស់បំណុលទាមទារវាយតម្លៃ (ពិនិត្យមើល) លើទ្រព្យសកម្ម ឬសាច់ប្រាក់ជាដើមកំណើតណាមួយដើម្បី កំណត់ថាតើលំហូរសាច់ប្រាក់ តាមកិច្ចសន្យារបស់ទ្រព្យសកម្ម ហិរញ្ញវត្ថុកំពុងត្រូវបានចាត់ជាក្រុមនោះ គឺជាការទូទាត់ប្រាក់ដើមនិងការប្រាក់

ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់។ ប្រសិនបើ រយៈពេលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ធ្វើឱ្យកើនឡើង នូវសាច់ប្រាក់ផ្សេងទៀត ឬកំហិតនូវសាច់ប្រាក់តាមរបៀបមួយ ដែលមិនមានសង្គតិភាពជាមួយនឹងការទូទាត់ ដែលតំណាងនូវប្រាក់ដើម និងការប្រាក់, ទ្រព្យសកម្មហិរញ្ញវត្ថុនោះ មិនឆ្លើយតបនឹងលក្ខខណ្ឌក្នុងកថាខណ្ឌ៤.១.២(ខ)។ទោះបីជាទ្រព្យសកម្មជាការបង្ករបង្កើតគឺជាទ្រព្យសកម្មហិរញ្ញវត្ថុឬទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដោយខ្លួនវាមិនមានផលប៉ះពាល់ដល់ការវាយតម្លៃនេះឡើយ។

ខ៤.១.១៨ ប្រសិនបើ ចរិតលក្ខណៈ នៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺមិនពិត វាមិនមានផលប៉ះពាល់ ដល់ការចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើយ។ ចរិតលក្ខណៈនៃលំហូរសាច់ប្រាក់ តាមកិច្ចសន្យាគឺមិនពិត ប្រសិនបើ វាមានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុតែក្នុងករណីដែលព្រឹត្តិការណ៍មួយបានកើតឡើងដោយកម្រ ដោយភាពមិនប្រក្រតីខ្លាំង និងហាក់ដូចជា មិនដែលកើតឡើងទាល់តែសោះតែប៉ុណ្ណោះ។

ខ៤.១.១៩ នៅក្នុងប្រតិបត្តិការឱ្យខ្ចីភាគច្រើនឧបករណ៍ហិរញ្ញវត្ថុរបស់ម្ចាស់បំណុល ត្រូវបានធ្វើចំណាត់ថ្នាក់ធៀបនឹង ឧបករណ៍ហិរញ្ញវត្ថុរបស់ម្ចាស់បំណុលផ្សេងទៀត របស់កូនបំណុល។ ឧបករណ៍ហិរញ្ញវត្ថុមួយដែលពឹងអាស្រ័យនឹង ឧបករណ៍ហិរញ្ញវត្ថុផ្សេង

ទៀតអាចមានលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលការទូទាត់នៃជាការទូទាត់ប្រាក់ដើម និងការប្រាក់ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់ ប្រសិនបើការមិនទូទាត់របស់កូនបំណុលគឺជាការប្រព្រឹត្តិល្មើសនៃកិច្ចសន្យា ហើយអ្នកកាន់កាប់មានសិទ្ធិតតាមកិច្ចសន្យាទៅលើបរិមាណនៃប្រាក់ដើមនិងការប្រាក់មិនទាន់បានបង់ផ្អែកលើបរិមាណប្រាក់ដើមនៅសល់ ទោះបីជានៅក្នុងព្រឹត្តិការណ៍នៃការក្ស័យធន់របស់កូនបំណុល។ ឧទាហរណ៍ គណនីពាណិជ្ជកម្មត្រូវទទួលដែលផ្តល់ចំណាត់ថ្នាក់ម្ចាស់បំណុលថាជាម្ចាស់បំណុលទូទៅនឹងមានគុណវុឌ្ឍិថាមានការទូទាត់ប្រាក់ដើមនិងការប្រាក់ ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់។ នេះជាករណី ដែលកូនបំណុលបោះផ្សាយប្រាក់កម្ចី មានដាក់ទ្រព្យបញ្ចាំ ដែលនៅក្នុងហេតុការណ៍នៃក្ស័យធន ប្រាក់កម្ចីនោះនឹងផ្តល់ឲ្យអាទិភាពឲ្យកាន់កាប់ដើម្បីធ្វើជាចំណែកត្រូវទាមទាររបស់ម្ចាស់បំណុលទូទៅ ដោយយោងទៅតាមទ្រព្យដាក់បញ្ចាំ ប៉ុន្តែ មិនមានផលប៉ះពាល់ដល់សិទ្ធិ តាមកិច្ចសន្យារបស់ម្ចាស់បំណុលទូទៅចំពោះប្រាក់ដើមមិនទាន់បានបង់និងបរិមាណត្រូវសងផ្សេងទៀត។

ខ៤.១.២០ នៅក្នុងប្រភេទប្រតិបត្តិការខ្លះ អង្គភាពអាចបង្កើតអាទិភាព នៃការទូទាត់ទៅឱ្យអ្នកកាន់កាប់ទ្រព្យសកម្ម ដោយប្រើឧបករណ៍ហិរញ្ញវត្ថុដែលភ្ជាប់ដោយបញ្ញត្តិដោយកិច្ចសន្យាពហុគុណដែលបង្កើតបានជាការប្រមូលផ្ដុំនូវហានិភ័យឥណទាន (ចំណែក)។ ចំណែកនិមួយៗមានចំណាត់ថ្នាក់ ដោយការចាត់ទុកក្នុងបង្គាបអាជ្ញាដែលបញ្ជាក់អំពីលំដាប់ដែល លំហូរសាច់ប្រាក់និមួយៗបង្កើតដោយក្រុមហ៊ុនបោះផ្សាយត្រូវវាបានបែងចែកទៅតាមចំណែកនោះ។ នៅក្នុងស្ថានភាពបែបនេះ អ្នកកាន់កាប់ចំណែកនិមួយៗមានសិទ្ធិចំពោះការទូទាត់សងប្រាក់ដើម និងការប្រាក់ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់តែក្នុងករណី ដែលក្រុមហ៊ុនបោះផ្សាយបង្កើតសាច់ប្រាក់គ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងចំណែកដែលមានចំណាត់ថ្នាក់ខ្ពស់។

ខ៤.១.២១ នៅក្នុងប្រតិបត្តិការបែបនេះ ចំណែកនិមួយៗមានចរិតលក្ខណៈលំហូរសាច់ប្រាក់ដែលជាការទូទាត់សងប្រាក់ដើមនិងការប្រាក់ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់ តែក្នុងករណីដែលៈ

(ក) រយៈពេលកិច្ចសន្យារបស់ចំណែកនិមួយៗ ដែលកំពុងត្រូវបានវាយតម្លៃសម្រាប់ការធ្វើចំណាត់ថ្នាក់(ដោយមិនមានការពិនិត្យចំពោះបណ្ដុំឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើត) ធ្វើឱ្យកើន

ឡើងនូវលំហូរសាច់ប្រាក់ ដែលជាការទូទាត់សងប្រាក់ដើមនិងការប្រាក់ ដែលផ្អែកលើបរិមាណប្រាក់ដើម នៅសល់តែប៉ុណ្ណោះ (ឧ.អត្រាការប្រាក់លើចំណែកនិមួយៗមិនភ្ជាប់ទៅនឹងសន្ទស្សន៍កុំម៉ូឌីធី),

(ខ) បណ្តុំឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើត មានចរិតលក្ខណៈលំហូរសាច់ប្រាក់បានកំណត់នៅក្នុងកថាខណ្ឌខ៤.១.២៣និង ខ៤.១.២៤ និង

(គ) ការប្រឈមទៅនឹងហានិភ័យឥណទាន នៅក្នុងចរិតលក្ខណៈលំហូរសាច់ប្រាក់ដែលមានបង្កប់នៅក្នុងចំណែកនោះគឺស្មើនឹងឬទាបជាងការប្រឈមទៅនឹងហានិភ័យឥណទាន របស់បណ្តុំជាការបង្ករបង្កើតរបស់ឧបករណ៍ហិរញ្ញវត្ថុ (ឧ. លក្ខខណ្ឌនេះនឹងឆ្លើយតប ប្រសិនបើ បណ្តុំឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើតនឹងត្រូវខាតបង់ ៥០ភាគរយ ដែលជាលទ្ធផល នៃការខាតបង់ឥណទាននិងក្រោមគ្រប់កាលៈទេសៈទាំងអស់ចំណែកនោះនឹងខាតបង់ ៥០ភាគរយ ឬតិចជាង)។

ខ៤.១.២២ អង្គភាពមួយត្រូវពិនិត្យ ឲ្យបានច្បាស់លាស់រហូតដល់ខ្លួន អាចកំណត់អត្តសញ្ញាណបណ្តុំ ជាការបង្ករបង្កើត របស់ឧបករណ៍ហិរញ្ញវត្ថុដែលកំពុងបង្កើត (ជាជាងរំលងចោល) សាច់ប្រាក់នោះ។ នេះគឺជាបណ្តុំឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើត។

ខ៤.១.២៣ បណ្ដុំឧបករណ៍ហិរញ្ញវត្ថុ ជាការបង្ករបង្កើត ត្រូវមានឧបករណ៍ហិរញ្ញវត្ថុមួយឬច្រើនដែលមានលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជាការទូទាត់សងប្រាក់ដើម និងការប្រាក់ ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់។

ខ៤.១.២៤ បណ្ដុំឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើតអាចរួមមានឧបករណ៍ហិរញ្ញវត្ថុដែល:

(ក)កាត់បន្ថយភាពងាយប្រែប្រួលនៃឧបករណ៍ហិរញ្ញវត្ថុនៅក្នុងកថាខណ្ឌខ៤.១.២៣ និងនៅពេលគួផ្សំជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុនៅក្នុងកថាខណ្ឌខ៤.១.២៣ បានធ្វើឱ្យសាច់ប្រាក់ដែលជាការទូទាត់សងប្រាក់ដើម និងការប្រាក់ដែលផ្អែកលើបរិមាណប្រាក់ដើមនៅសល់(ឧ.កម្រិតខ្ពស់ឬកម្រិតទាបនៃអត្រាការប្រាក់ ឬកិច្ចសន្យាដែលនឹងកាត់បន្ថយហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុមួយចំនួនឬ ទាំងអស់នៅក្នុងកថាខណ្ឌខ៤.១.២៣) ឬ

(ខ) ដាក់បញ្ចូលលំហូរសាច់ប្រាក់របស់ចំណែកនិមួយៗជាមួយនឹងលំហូរសាច់ប្រាក់របស់បណ្ដុំនៃឧបករណ៍ហិរញ្ញវត្ថុជាការបង្ករបង្កើតនៅក្នុងកថាខណ្ឌ ខ៤.១.២៣ ដើម្បីបញ្ជាក់ភាពខុសគ្នានៅក្នុងនិងតែនៅក្នុង:

(១) ថាតើអត្រាការប្រាក់ថេរឬអត្រាការប្រាក់អណ្តែត

(២) រូបិយវត្ថុនៃលំហូរសាច់ប្រាក់ រួមមានទាំងអតិផរណានៅក្នុងរូបិយវត្ថុនោះផងដែរ ឬ

(៣) ពេលវេលារបស់លំហូរសាច់ប្រាក់។

ខ៤.១.២៥ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុនៅក្នុងបណ្តុំនោះមិន ឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុង កថាខណ្ឌខ៤.១.២៣ ឬ កថាខណ្ឌ ខ៤.១.២៤ នោះលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ខ៤.១.២១(ខ) ក៏មិនឆ្លើយតបដែរ។

ខ៤.១.២៦ ប្រសិនបើអ្នកកាន់កាប់ មិនអាចវាយតម្លៃពីលក្ខខណ្ឌ នៅក្នុងកថាខណ្ឌខ ៤.១.២១ នៅដំណាក់កាល នៃការទទួលស្គាល់ដំបូងចំណែកនោះត្រូវតែវាស់វែងតាមតម្លៃសមស្រប។ប្រសិនបើ បណ្តុំឧបករណ៍ហិរញ្ញវត្ថុជាការបង្កបង្កើត អាចផ្លាស់ប្តូរបន្ទាប់ពីដំណាក់កាលដំបូង នៃការទទួលស្គាល់ តាមរបៀបមួយដែលបណ្តុំនោះមិនអាចឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ខ៤.១.២៣ ឬកថាខណ្ឌ ខ៤.១.២៤ ចំណែកនោះមិនឆ្លើយតបទៅនឹងលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ ខ៤.១.២១ និងត្រូវវាស់វែងតាមតម្លៃសមស្រប។

**ជម្រើសដើម្បីកំណត់ថាទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុត្រូវវាស់វែងតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ (ផ្នែក ៤.១ និង ៤.២)**

ខ៤.១.២៧ ដោយស្ថិតនៅក្រោមលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ៤.១.៥ និង កថាខណ្ឌ៤.២.២ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ អនុញ្ញាតិឲ្យអង្គភាព កំណត់អត្តសញ្ញាណរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬក្រុមនៃឧបករណ៍ហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬទាំងពីរ) តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ ដោយបានថា ការធ្វើដូច្នោះនឹងធ្វើឲ្យព័ត៌មានកាន់តែពាក់ពន្ធ័ឡើង។

ខ៤.១.២៨ សេចក្តីសម្រេចចិត្តរបស់អង្គភាព ក្នុងការកំណត់អត្តសញ្ញាណទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្របនាចុងការិយបរិច្ឆេទគឺស្រដៀងគ្នានឹងជម្រើសគោលនយោបាយគណនេយ្យ (ទោះបីជាយ៉ាងណា មិនដូចជាជម្រើសនៃគោលនយោបាយគណនេយ្យ វាមិនតម្រូវឲ្យអនវត្តយ៉ាងសង្គិតភាពចំពោះ គ្រប់ប្រតិបត្តិការស្រដៀងគ្នាទាំងអស់) នៅពេលដែលអង្គភាពមានជម្រើសបែបនេះ កថាខណ្ឌ ១៤(ខ) នៃស្តង់ដាគណនេយ្យអន្តរជាតិ ៨ តម្រូវឲ្យគោលនយោបាយបានជ្រើសរើស ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មាន

កាន់តែមានពាក់ព័ន្ធ នឹងកាន់តែអាចជឿទុកចិត្តបាន អំពីផលប៉ះពាល់របស់ប្រតិបត្តិការរបស់ព្រឹត្តិការណ៍ផ្សេងៗនិងលក្ខខណ្ឌនានាលើស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ ឬលំហូរសាច់ប្រាក់របស់អង្គភាព។ ឧទាហរណ៍ នៅក្នុងករណីនៃការកំណត់អត្តសញ្ញាណ បំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ កថាខណ្ឌ ៤.២.២ កំណត់បាននូវកាលៈទេសៈពីរ នៅពេលការតម្រូវសម្រាប់ព័ត៌មាន ដែលពាក់ព័ន្ធនឹងត្រូវបានបំពេញ។ យោងតាមនោះ ដើម្បីជ្រើសរើសការកំណត់អត្តសញ្ញាណនោះ ដោយអនុលោមតាម កថាខណ្ឌ ៤.២.២ អង្គភាពត្រូវបង្ហាញថាវាស្ថិតនៅក្នុងកាលៈទេសៈណាមួយ (ឬទាំងពីរ) នៃកាលៈទេសៈទាំងពីរនេះ។

## ការកំណត់អត្តសញ្ញាណលុបបំបាត់ចោលឬបន្ថយជាដុំកំភួននូវភាពមិនស៊ីគ្នាផ្នែកគណនេយ្យ

ខ៤.១.២៩ ការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ និងការធ្វើចំណាត់ នៃការផ្លាស់ប្តូរតម្លៃរបស់ ដែលបានទទួលស្គាល់ត្រូវបានកំណត់ ដោយការធ្វើចំណាត់ថ្នាក់របស់ធាតុនោះ និងថាតើធាតុនោះ គឺជាផ្នែកមួយនៃទំនាក់ទំនង សម្រាប់ទប់ស្កាត់ហានិភ័យដែលបានកំណត់ ឬយ៉ាងណា។ ការតម្រូវទាំងនោះអាចបង្កើតអសង្គតភាពនៃការវាស់វែង ឬការទទួលស្គាល់ (ជួន

កាល សំដៅដល់ភាពមិនស៊ីគ្នាផ្នែកគណនេយ្យ) នៅពេលដែល ឧទាហរណ៍ អវត្តមាននៃការកំណត់អត្តសញ្ញាណ នៅចុងការិយបរិច្ឆេទ, ទ្រព្យសកម្មហិរញ្ញវត្ថុ នឹងត្រូវបានចាត់ថ្នាក់ថាបានវាស់វែងតាមតម្លៃសមស្របនៅ ពេលបន្ទាប់មកទៀត ហើយបំណុលដែលអង្គភាពគិតថាមានការពាក់ពន្ធ័នឹងត្រូវបានវាស់វែង តាមតម្លៃដករំលស់នៅពេលក្រោយមកទៀត (ជាមួយនឹងការផ្លាស់ប្តូរតម្លៃសមស្របដែលមិនទទួលស្គាល់)។ នៅក្នុងកាលៈទេសៈបែបនេះ អង្គភាពអាចសន្និដ្ឋានថា របាយការន៍ហិរញ្ញវត្ថុរបស់ខ្លួននឹងផ្តល់នូវព័ត៌មានពាក់ពន្ធ័ ប្រសិនបើ ទាំងទ្រព្យសកម្ម និងទាំងបំណុលត្រូវបានវាស់វែង តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ។

ខ៤.១.៣០ ឧទាហរណ៍ខាងក្រោមបង្ហាញថាពេលណាដែលលក្ខខណ្ឌ ត្រូវបានបំពេញ។ នៅក្នុងគ្រប់ករណីអង្គភាពមួយអាចប្រើលក្ខខណ្ឌនេះដើម្បីកំណត់អត្តសញ្ញាណទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ តែនៅក្នុងករណីដែល វាបានបំពេញគោលការណ៍ នៅក្នុងកថាខណ្ឌ ៤.១.៥ ឬ ៤.២.២(ក)។

(ក) អង្គភាព មានបំណុលក្រោមកិច្ចសន្យាធានារ៉ាប់រង ដែលការវាស់វែងរបស់វារួមបញ្ចូលនូវព័ត៌មានថ្មីៗ (ដូចបានអនុញ្ញាតដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៤

កថាខណ្ឌ២៤), និងទ្រព្យសកម្មហិរញ្ញវត្ថុដែលខ្លួនគិតថាមានភាពទាក់ទងនឹងត្រូវបានវាស់វែងតាមតម្លៃដករំលស់។

(ខ) អង្គភាពមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬទាំងពីរ ដែលមានហានិភ័យរួមគ្នា ដែលនឹងធ្វើឱ្យកើននូវការផ្លាស់ប្តូរផ្ទុយនៅក្នុងតម្លៃសមស្របដែលមាននិន្នាការកាត់កងគ្នាទៅវិញទៅមក។ទោះជាយ៉ាងណាមានតែ ឧបករណ៍ហិរញ្ញវត្ថុមួយចំនួនប៉ុណ្ណោះនឹងត្រូវបានវាស់វែង តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ (នោះគឺ និស្សន្ទ ឬត្រូវបានចាត់ទុកសម្រាប់ការជួញដូរ)។វាអាចជាករណីដែលឧបករណ៍ហិរញ្ញវត្ថុសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យមិនត្រូវបានបំពេញ ឧទាហរណ៍ដោយសារតែការតម្រូវសម្រាប់ការចូលជាធរមាននៅក្នុងកថាខណ្ឌ ៨៨ នៃស្តង់ដា គណនេយ្យអន្តរជាតិ ៣៩ មិនត្រូវបានបំពេញ។

(គ) អង្គភាពមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឬទាំងពីរ ដែលមានហានិភ័យរួមគ្នា ដូចជាហានិភ័យអត្រាការប្រាក់ ដែលនឹងធ្វើឱ្យកើន នូវការផ្លាស់ប្តូរផ្ទុយនៅក្នុងតម្លៃសមស្របដែលមាននិន្នាការកាត់កងគ្នាទៅវិញទៅមក ហើយមូលធនមិនមានគុណវុឌ្ឍ សម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យ ពីព្រោះគ្មានឧបករណ៍ហិរញ្ញវត្ថុណាមួយគឺជានិស្សន្ទ។ ជាងនេះទៀត នៅក្នុងករណីមិនមានគណនេយ្យទប់ស្កាត់ហានិភ័យ

មានអសង្គិតភាពយ៉ាសំបើម នៅក្នុងការទទួលស្គាល់ចំណេញ ឬខាត។ ឧទាហរណ៍ អង្គភាព ត្រូវបានផ្តល់ហិរញ្ញប្បទាន ចំពោះក្រុមនៃប្រាក់កម្ចីជាក់លាក់មួយ ដោយបានបោះផ្សាយ សញ្ញាបណ្ណពាណិជ្ជកម្ម ដែលមានការផ្លាស់ប្តូរតម្លៃសមស្រប របស់វាមាននិន្នាការកាត់កងគ្នាទៅវិញទៅមក។បន្ថែមលើនេះ ប្រសិនបើអង្គភាពទិញឬលក់សញ្ញាបណ្ណ័ជាទៀងទាត់ប៉ុន្តែកម្រ ទិញឬលក់ប្រាក់កម្ចីប្រសិនបើមាន នោះការរាយការណ៍ទាំង ប្រាក់កម្ចី និងសញ្ញាបណ្ណ័ តាមតម្លៃសមស្របនៅចុងការិយ បរិច្ឆេទ នឹងលុបបំបាត់ចោលនូវអសង្គតិភាព នៃការកំណត់ ពេលវេលានៃការទទួលស្គាល់ចំណេញ ឬខាតមូលធន ដែល នឹងកើតឡើងពីការវាស់វែងពួកវាទាំងតាមតម្លៃដករំលស់ និង ការទទួលស្គាល់ចំណេញ ឬខាតមូលធននៅរាល់ពេល ដែល សញ្ញាបណ្ណ័ត្រូវបានទិញមកវិញ។

១៤.១.៣១ នៅក្នុងករណីដូចដែលបានបរិយាយនៅក្នុងកថាខណ្ឌមុនៗ នៅ ដំណាក់កាលដំបូងនៃការទទួលស្គាល់ដើម្បីកំណត់អត្តសញ្ញាណ ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុមិនបានវាស់វែងតាម តម្លៃសមស្រប នៅចុងការិយបរិច្ឆេទអាចលុបបំបាត់ចោល ឬ បន្ថយជាដុំកំភួន នូវអសង្គតិភាពនៃការវាស់វែង ឬការទទួល ស្គាល់និងបង្កើតបានព័ត៌មានពាក់ពន្ធ័ច្រើនថែមទៀត។ សម្រាប់ គោលបំណង នៃការអនុវត្តន៍អង្គភាព មិនចាំបាច់ដាក់បញ្ចូល

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុទាំងអស់ ដើម្បីធ្វើឱ្យមានការកើនឡើងនូវអសង្គតិភាព នៃការវាស់វែង ឬការទទួលស្គាល់នៅក្នុងពេលវេលាតែមួយជាមួយគ្នានោះទេ។ ការពន្យារសមហេតុផលមួយ ត្រូវបានអនុញ្ញាតិ ដោយថាប្រតិបត្តិការនិមួយៗ ត្រូវបានកំណត់អត្តសញ្ញាណ តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនីដំណាក់កាលដំបូងនៃការទទួលស្គាល់ និងនៅពេលនោះ ប្រតិបត្តិការនៅសេសសល់ត្រូវបានរំពឹងថានឹងកើតឡើង។

ខ៤.១.៣២ វានឹងមិនអាចទទួលយកបានទេក្នុងការកំណត់អត្តសញ្ញាណ តែទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុមួយចំនួនដែលនឹងធ្វើឱ្យមានការកើនឡើងនូវអសង្គតិភាពនៃតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍ប្រសិនបើធ្វើ ដូច្នោះ វានឹងមិនលុបបំបាត់ចោល ឬបន្ថយជាដុំកំភួននូវអសង្គតិភាព និងហេតុដូច្នេះវានឹងមិនមានពតិមានពាក់ពន្ធ័កាន់តែច្រើន។ ទោះជាយ៉ាងណាវានឹងអាចទទួលយកបាន ក្នុងការកំណត់អត្តសញ្ញាណ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ស្រដៀងគ្នាមួយចំនួនប្រសិនបើ ការធ្វើដូច្នោះនឹងសម្រេចបានការធ្លាក់ចុះជាដុំកំភួន (និងប្រហែលជាអាច ការធ្លាក់ចុះយ៉ាងខ្លាំងមួយ ដែលមិនមែនជាការកំណត់អត្តសញ្ញាណដែលអាចអនុញ្ញាតិ)នៃអសង្គតិភាព។ ឧទាហរណ៍ សន្មតថាអង្គភាពមានបំណុលហិរញ្ញវត្ថុស្រដៀងគ្នា

មួយចំនួនដែលមានតម្លៃសរុប ១០០ ឯកតារូបិយវត្ថុ និងមានទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នាមួយចំនួនដែលមានតម្លៃសរុប ៥០ ឯកតារូបិយវត្ថុ ប៉ុន្តែត្រូវបានវាស់វែងឈរលើមូលដ្ឋានផ្សេងៗគ្នា។ អង្គភាពអាចកាតើបន្ថយជាដុំកំភួន នូវអសង្គតិភាពនៃការវាស់វែងដោយកំណត់នៅដំណាក់កាលដំបូងនៃការទទួលស្គាល់ នូវទ្រព្យសកម្មទាំងអស់ ប៉ុន្តែទទួលស្គាល់បំណុលមួយចំនួនប៉ុណ្ណោះ (ឧទាហរណ៍ បំណុលនិមួយៗ ដែលបានរួមបញ្ចូលគ្នាមានតម្លៃសរុប ៤៥ ឯកតារូបិយវត្ថុ) តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ។ ទោះជាយ៉ាងណាក៏ដោយសារតែការកំណត់តម្លៃសមស្របនៅចុងការិយបរិច្ឆេទ អាចត្រូវបានអនុវត្ត តែចំពោះឧបករណ៍ហិរញ្ញវត្ថុមួយទាំងមូល អង្គភាពនៅក្នុងឧទាហរណ៍នេះ ត្រូវតែកំណត់អត្តសញ្ញាណបំណុលមួយឬច្រើនដែលមានទាំងអស់របស់ខ្លួន។ អង្គភាពមិនអាចកំណត់សមាសធាតុមួយរបស់បំណុល (ឧ. ការផ្លាស់ប្តូរ នៅក្នុងតម្លៃដែលជាប់ទាក់ទងនឹងហានិភ័យមួយ ដូចជាការផ្លាស់ប្តូរអត្រាការប្រាក់ស្តង់ដា) ឬចំណែកមួយ (ភាគរយ) នៃបំណុល។

**ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង ហើយលទ្ធផលរបស់វាត្រូវបានវាយតម្លៃផ្អែកលើតម្លៃសមស្រប**

ខ៤.១.៣៣ អង្គភាព អាចគ្រប់គ្រងនិងវាយតម្លៃលទ្ធផល នៃក្រុមបំណុលហិរញ្ញវត្ថុ ឬទ្រព្យសកម្មហិរញ្ញវត្ថុ ហើយបំណុលហិរញ្ញវត្ថុគឺជាវិធីនៃការវាស់វែងក្រុមនោះតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ ដែលនាមឲ្យមានព័ត៌មានពាក់ពន្ធ័កាន់តែច្រើនឡើង។ ការផ្តោតនៅក្នុងឧទាហរណ៍នេះគឺអំពីរបៀបដែលអង្គភាពគ្រប់គ្រង និងវាយតម្លៃលទ្ធផល ជាជាងផ្អែកលើចរិតលក្ខណៈរបស់ឧបករណ៍ហិរញ្ញវត្ថុ។

ខ៤.១.៣៤ ឧទាហរណ៍ អង្គភាពមួយអាចប្រើលក្ខខណ្ឌនេះ ដើម្បីកំណត់អត្តសញ្ញាណ បំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ ប្រសិនបើវាឆ្លើយតបទៅនឹងគោលការណ៍នៅក្នុងកថាខណ្ឌ ៤.២.២(ខ) ហើយអង្គភាពមានទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលទទួលបានចំណែកហានិភ័យជាមួយគ្នាហើយហានិភ័យទាំងនោះ ត្រូវបានគ្រប់គ្រង និងវាយតម្លៃឈរលើមូលដ្ឋានតម្លៃសមស្រប ដោយអនុលោម តាមគោលនយោបាយនៃការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល។ ឧទាហរណ៍ អង្គភាពដែលបានបោះផ្សាយ “ឧបករណ៍ហិរញ្ញវត្ថុមានរចនាសម្ពន្ធ័” ដែលរួមមាននិស្សន្ទបង្កប់ពហុ ដែលបង្ករឲ្យមាន

ហានិភ័យលើមូលដ្ឋានតម្លៃសមស្រប ដោយប្រើភាពចំរុះគ្នានៃឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទនិងឧបករណ៍ហិរញ្ញវត្ថុអនិស្សន្ទ។

ខ៤.១.៣៥ ដូចបានកត់សំគាល់ខាងលើលក្ខខណ្ឌនេះអាស្រ័យលើវិធីដែលអង្គភាពគ្រប់គ្រងនិងវាយតម្លៃលទ្ធផលរបស់ក្រុម នៃឧបករណ៍ហិរញ្ញវត្ថុ ដែលស្ថិតក្រោមការពិចារណា។ ដោយយោងតាមនោះ (កម្មបទ នៃការតម្រូវ នៃការកំណត់អត្តសញ្ញាណនៅដំណាក់កាលនៃការទទួលស្គាល់ដំបូង) អង្គភាព ដែលកំណត់អត្តសញ្ញាណបំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ ដោយឈរលើមូលដ្ឋាន នៃលក្ខខណ្ឌនេះត្រូវកំណត់អត្តសញ្ញាណរបស់បំណុលហិរញ្ញវត្ថុ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានគ្រប់គ្រងនិងវាយតម្លៃរួមគ្នា។

ខ៤.១៣៦ ការចងក្រងឯកសារយុទ្ធសាស្ត្ររបស់អង្គភាព មិនចាំបាច់ទូលំទូលាយឡើយ ប៉ុន្តែត្រូវតែគ្រប់គ្រាន់ ដើម្បីបង្ហាញ ពីភាពអនុលោម តាមកថាខណ្ឌ ៤.២.២(ខ)។ ឯកសារនេះ មិនតម្រូវសម្រាប់ធាតុនិមួយៗឡើយ ប៉ុន្តែអាចផ្អែកលើមូលដ្ឋានជាក្រុម។ ឧទាហរណ៍ ប្រសិនបើប្រពន្ធ័នៃការគ្រប់គ្រងលទ្ធផលសម្រាប់នាយកដ្ឋានមួយ ដែលបានយល់ព្រម ដោយអ្នកគ្រប់គ្រងសំខាន់ៗ របស់អង្គភាព បង្ហាញយ៉ាច្បាស់ថា លទ្ធផលរបស់នាយកដ្ឋាននោះ ត្រូវបានវាយតម្លៃផ្អែកលើផលចំណេញសរុប

នោះនឹងមិនមានឯកសារផ្សេងទៀត ត្រូវបានទាមទារ ដើម្បីបង្ហាញនូវភាពអនុលោមតាមកថាខណ្ឌ ៤.២.២(ខ)។

**និស្សន្ទបង្កប់(ផ្នែក៤.៣)**

ខ៤.៣.១ នៅពេលអង្គភាពក្លាយជាភាគីមួយ នៃកិច្ចសន្យាមានលក្ខណៈទ្វេរដែលបាហនិក) មិនមែនជាទ្រព្យសកម្ម ដែលស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ១៣ នេះ កថាខណ្ឌ៤.៣.៣ តម្រូវឱ្យអង្គភាពកំណត់អត្តសញ្ញាណនិស្សន្ទបង្កប់, តម្រូវឱ្យប៉ាន់ប្រមាណថាតើ វាទាមទារត្រូវញែកកិច្ចសន្យាបាហនិកចេញពីកិច្ចសន្យានានា ដែលត្រូវបានតម្រូវឱ្យញែកចេញពីគ្នា, តម្រូវឱ្យវាស់វែងនិស្សន្ទតាមតម្លៃសមស្របនៅដំណាក់កាល នៃការទទួលស្គាល់ដំបូង និងដំណាក់កាលចាបន្តបន្ទាប់ទៀត។

ខ.៤.៣.២ ប្រសិនបើកិច្ចសន្យាបាហនិកមិនមានចែងអំពី ឬមិនបានកំណត់ទុកជាមុន នូវកាលបរិច្ឆេទដល់ កំណត់សង និងតំណាងឱ្យភាគកម្ម នៅសល់នៅក្នុងទ្រព្យសកម្មសុទ្ធរបស់អង្គភាព ដូច្នេះចរិតលក្ខណៈសេដ្ឋកិច្ច និងហានិភ័យ គឺជាចរិតលក្ខណៈ និងហានិភ័យរបស់ឧបករណ៍ហិរញ្ញវត្ថុមូលធន, ហើយនិស្សន្ទបង្កប់ចាំបាច់ ត្រូវតែមានចរិតលក្ខណៈមូលធន ទាក់ទងនឹងអង្គភាព ដូចគ្នាដើម្បីចាត់ទុកថាវាមានកាទាក់ទងជិតស្និទ្ធ។

ប្រសិនបើ កិច្ចសន្យាបាហនិក មិនមែនជាឧបករណ៍ហិរញ្ញវត្ថុមូលធនហើយឆ្លើយតបទៅនឹងនិយមន័យនៃឧបករណ៍ហិរញ្ញវត្ថុដូច្នេះចរិតលក្ខណៈសេដ្ឋកិច្ច និងហានិភ័យ គឺជាចរិតលក្ខណៈ និងហានិភ័យរបស់ឧបករណ៍ហិរញ្ញវត្ថុបំណុល។

១៤.៣.៣ និស្សន្ទបង្កប់មិនមែនជាជម្រើស (ដូចជា forward or swap បង្កប់) ត្រូវតែញែកចេញពីកិច្ចសន្យានាហនិក ដោយឈរលើមូលដ្ឋាននៃលក្ខខណ្ឌច្បាស់លាស់ដែលបានកំណត់ ឬបានចែង ដោយហេតុដូច្នេះ វាមានតម្លៃសមស្របស្មើសូន្យនៅដំណាក់កាលដំបូងនៃការទទួលស្គាល់។និស្សន្ទបង្កប់មិនមែនជាជម្រើស (ដូចជា put, call, cap, floor or swaption បង្កប់) ត្រូវតែញែកចេញពីកិច្ចសន្យាបាហនិក ដោយឈរលើមូលដ្ឋាន នៃលក្ខខណ្ឌបានចែង នៃលក្ខណៈរបស់ជម្រើស។ បរិមាណលើបញ្ជីដំបូងរបស់ ឧបករណ៍ហិរញ្ញវត្ថុបាហនិក គឺជាបរិមាណសំណល់បន្ទាប់ពីការញែកនិស្សន្ទបង្កប់)។

១៤.៣.៤ ជាទូទៅ និស្សន្ទបង្កប់ពហុនៅក្នុងកិច្ចសន្យាមានលក្ខណៈទ្វេរត្រូវបានជួញដូរដូចជានិស្សន្ទបង្កប់ផ្ទួបទោល។ទោះជាយ៉ាងណានិស្សន្ទបង្កប់ ដែលត្រូវបានចាត់ថ្នាក់ថាជា មូលធន (មើលស្តង់ដាគណនេយ្យអន្តរជាតិ ៣២) ត្រូវបានគិតដាច់ដោយឡែកពីនិស្សន្ទទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ថាជាទ្រព្យសកម្ម ឬបំណុល។ ជាការបន្ថែម ប្រសិនបើ កិច្ចសន្យាមាន

លក្ខណៈទ្វេរមាននិស្សន្ទបង្កប់ច្រើនជាងមួយ ហើយនិស្សន្ទទាំងនោះទាក់ទងនឹងការប្រឈមហានិភ័យផ្សេងៗគ្នា និងត្រូវបានញែកចេញដាច់ពីគ្នា និងមិនចំណុះគ្នាទៅវិញទៅមក និស្សន្ទទាំងនោះត្រូវបានយកមកគិតដាច់ដោយឡែកពីគ្នា។

ខ៤.៣.៥ ចរិតលក្ខណសេដ្ឋកិច្ច និងហានិផ័យរបស់និស្សន្ទបង្កប់មិនមានការទាក់ទងជិតស្និទ្ធជាមួយនឹងកិច្ចសន្យាបាហនិក (កថាខណ្ឌ ៤.៣.៣(ខ)) នៅក្នុងឧទាហរណ៍ខាងក្រោម។ ក្នុងឧទាហរណ៍ទាំងនេះ សន្មតថា លក្ខខណ្ឌនៅក្នុងកថាខណ្ឌ ៤.៣.៣(ខ) និង(គ) ត្រូវបាបឆ្លើយតប អង្គភាពយកមកគិតនូវនិស្សន្ទបង្កប់ដាច់ដោយឡែកពីកិច្ចសន្យាបាហនិក។

(ក) ជម្រើសនៃការលក់ (put option) បានបង្កប់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុ ដែលអាចឱ្យអ្នកកាន់កាប់ទាមទារឱ្យអ្នកបោះផ្សាយទទួលយកវិញនូវឧបករណ៍ហិរញ្ញវត្ថុនៅក្នុងតម្លៃជាសាច់ប្រាក់មួយ ឬក្នុងតម្លៃជាទ្រព្យសកម្មដែលប្រែប្រួលឈរលើមូលដ្ឋាននៃការប្រែប្រួលមូលធនឬថ្លៃនៃកុំម៉ូឌីធីឬសន្ទស្សន៍មិនទាក់តងដោយផ្ទាល់ទៅនឹងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក។

(ខ) ជម្រើសឬមាត្រានៅក្នុងកិច្ចសន្យាស្វ័យប្រវត្តិ ដើម្បីពន្យាររយៈពេលនៅសល់ រហូតដល់ កាលបរិច្ឆេទដល់កំណត់ របស់ឧបករណ៍ហិរញ្ញវត្ថុ បំណុល មិនទាក់ទងជិតស្និទ្ធ ទៅនឹងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក ដរាបណា មានការកែ

សម្រួលឯកប្បហារ ជាមួយនឹងអត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន សមស្របនៅពេលនៃការពន្យាពេលនោះ។ ប្រសិនបើអង្គភាព បោះផ្សាយឧបករណ៍ហិរញ្ញវត្ថុបំណុល ហើយអ្នកកាន់កាប់ ឧបករណ៍ហិរញ្ញវត្ថុបំណុលនោះចែងអំពីជម្រើស នៃការទិញ យកវិញលើឧបករណ៍ហិរញ្ញវត្ថុបំណុលទៅកាន់ ភាគីទីបី អ្នក បោះផ្សាយចាត់ទុកជម្រើសទិញវិញនោះ គឺជាការពន្យាពេល រហូតដល់កាលបរិច្ឆេទ ដល់កំណត់របស់ ឧបករណ៍បំណុល នោះ ដោយបានផ្តល់ថាអ្នកបោះផ្សាយ អាចត្រូវបានទាមទារ ឲ្យចូលរួមនៅក្នុង ឬសម្របសម្រួលនូវសកម្មភាព ម៉ាឃីតទីង ម្តងទៀតសម្រាប់ឧបករណ៍ហិរញ្ញវត្ថុបំណុល ដោយសារតែ ជម្រើសទិញមកវិញត្រូវបានអនុវត្ត។

(គ) ការទូទាត់ប្រាក់ដើមនិងការប្រាក់ដែលមានសន្ទស្សន៍ជាមូលធន បានបង្កប់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក ឬកិច្ចសន្យាធានារ៉ាប់រង ដែលបរិមាណនៃប្រាក់ដើម និងការប្រាក់ ត្រូវបានធ្វើសន្ទស្សន៍ ទៅនឹងថ្លៃរបស់កុំម៉ូឌីធី (ដូចជាមាស) មិនទាក់ទងជិតស្និទ្ធទៅនឹងកិច្ចសន្យាបាហនិក ហើយនិស្សន្ទ បង្កប់មិនស្រដៀងគ្នា។

(ឃ) ការទូទាត់ប្រាក់ដើម និងការប្រាក់ ដែលមានសន្ទស្សន៍ ជាកុំម៉ូឌីធី បានបង្កប់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក ឬកិច្ចសន្យាធានារ៉ាប់រង ដែលបរិមាណនៃប្រាក់ដើម និងការ

ប្រាក់ត្រូវបានធ្វើសន្ទស្សន៍ ទៅនឹងថ្លៃរបស់កុម្ម៉ូឌីធី (ដូចជាមាស) មិនទាក់ទងជិតស្និទ្ធទៅនឹង កិច្ចសន្យាបាហនិកឡើយ ពីព្រោះហានិភ័យដែលមាននៅក្នុងនិស្សន្ទបាហនិកនិងនិស្សន្ទបង្កប់មិនស្រដៀងគ្នា។

(ង) ជម្រើសទិញមកវិញ ជម្រើសលក់ ឬជម្រើសនៃការទូទាត់សងបង្កប់នៅក្នុងកិច្ចសន្យាបំណុលបាហនិក ឬកិច្ចសន្យាធានារ៉ាប់រងបានហនិកមិនទាក់ទងជិតស្និទ្ធទៅនឹង កិច្ចសន្យាបាហនិកដរាបណា៖

(១) ថ្លៃអនុវត្តរបស់ជម្រើសនោះ ប្រហែលជា ស្មើគ្នានៅកាលបរិច្ឆេទអនុវត្តជម្រើសនិមួយៗ ធៀបទៅនឹងថ្លៃដើមដករំលស់របស់ឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក ឬតម្លៃលើបញ្ជីរបស់កិច្ចសន្យាធានារ៉ាប់រងបាហនិក, ឬ

(២) ថ្លៃអនុវត្តរបស់ជម្រើស នៃការទូទាត់សងទៅអ្នកឲ្យខ្ចីនូវបរិមាណស្មើនឹងតម្លៃបច្ចុប្បន្នសមរម្យរបស់ការប្រាក់សម្រាប់រយៈពេលដែលនៅសេសសល់របស់កិច្ចសន្យាបាហនិក។ ការប្រាក់ ដែលបាត់បង់គឺជាលទ្ធផលនៃបរិមាណប្រាក់ដើមបានបង់មុនគុណនឹងភាពខុសគ្នានៃអត្រាការប្រាក់។ ភាពខុសគ្នានៃអត្រាការប្រាក់ គឺជាផលលើស នៃអត្រាការប្រាក់ជាក់ស្តែងរបស់កិច្ចសន្យាបាហនិកធៀបនឹង អត្រាការប្រាក់ជាក់ស្តែង ដែល

អង្គភាព នឹងទទួលបាននៅកាលបរិច្ឆេទ នៃការទូទាត់សង ប្រសិនបើ អង្គភាពបានវិនិយោគបន្តនូវបរិមាណប្រាក់ដើមដែលបានបង់មុននៅក្នុងកិច្ចសន្យាសៀងៀងគ្នា សម្រាប់រយៈពេលនៅសេសសល់ របស់កិច្ចសន្យាបាហនិក។ការប៉ាន់ស្មានថាតើ ជម្រើសទិញយកវិញ ឬជម្រើសលក់ មិនទាក់ទងជិតស្និទ្ធ ទៅនឹងកិច្ចសន្យាបំណុលបាហនិក ត្រូវតែបានធ្វើឡើង មិនពេលញែកបំបែកសមាសធាតុ មូលធនរបស់ ឧបករណ៍ហិរញ្ញវត្ថុបំណុលដែលអាចបំប្លែងបានដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣២។

(ច) និស្សន្ទឥណទានដែលត្រូវបានបង្កប់ នៅក្នុងឧបករណ៍ហិរញ្ញវត្ថុបំណុល និងអនុញ្ញាតិឲ្យភាគីមួយ (អត្ថាគាហក) ដើម្បីផ្ទេរទ្រព្យសកម្មអាទិភាពណាមួយ ដែលមិនមានជាកម្មសិទ្ធិរបស់ខ្លួន ទៅភាគីមួយផ្សេងទៀត (អ្នកធានា) មិនទាក់ទងជិតស្និទ្ធទៅនឹងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក។និស្សន្ទឥណទានបែបនេះអនុញ្ញាតិឲ្យ អ្នកធានាទទួលយកហានិភ័យឥណទានពាក់ពន្ធ័ជាមួយនឹង ទ្រព្យសកម្មអាទិភាព ដោយមិនមានកម្មសិទ្ធិផ្ទាល់ទៅលើវា។

ខ៤.៣.៦ ឧទាហរណ៍មួយ នៃកិច្ចសន្យាមានលក្ខណៈទ្វេរគឺ ឧបករណ៍ហិរញ្ញវត្ថុ ដែលផ្តល់ឲ្យអ្នកកាន់កាប់នូវសិទ្ធិលក់ទៅឲ្យអ្នកបោះ

វិញ ដើម្បីជាការដោះដូរយកបរមាណសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ដែលប្រែប្រួលផ្អែកលើមូលដ្ឋាន នៃការប្រែប្រួលសន្ទស្សន៍មូលធនឬសន្ទស្សន៍កុំម៉ូឌីធី ដែលអាចកើនឡើង ឬថយចុះ (ឧបករណ៍ហិរញ្ញវត្ថុអាចដាក់លក់បាន)។ ដរាបណានៅដំណាក់កាលដំបូងនៃការទទួលស្គាល់អ្នកបោះផ្សាយកំណត់ឧបករណ៍ហិរញ្ញវត្ថុ អាចដាក់លក់បានថាជាបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ វាត្រូវបានគេតម្រូវឲ្យបំបែកឧបករណ៍ហិរញ្ញវត្ថុបង្កប់មួយ(មានន័យថាការទូទាត់ប្រាក់ដើមដែលមានសន្ទស្សន៍) ក្រោមកថាខណ្ឌ ៤.៣.៣ ពីព្រោះកិច្ចសន្យាបាហនិក គឺជាឧបករណ៍ហិរញ្ញវត្ថុបំណុល ក្រោមកថាខណ្ឌ ខ៤.៣.២ ហើយការទូទាត់ប្រាក់ដើម ដែលមានសន្ទស្សន៍មិនទាក់ទងជិតស្និទ្ធទៅនឹងឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិកក្រោមកថាខណ្ឌ ខ៤.៣.៥(ក)។ ពីព្រោះការទូទាត់ប្រាក់ដើមអាចកើនឡើង ឬថយចុះ និស្សន្ទបង្កប់គឺជានិស្សន្ទមិនមែនជម្រើសដែលតម្លៃរបស់វាត្រូវបានធ្វើសន្ទស្សន៍ទៅតាមអថេរដែលពាក់ពន្ធ័។

ខ៤.៣.៧ នៅក្នុងករណីដែលឧបករណ៍ហិរញ្ញវត្ថុអាចដាក់លក់បាន ដែលត្រូវបានដាក់លក់នៅពេលណាមួយដើម្បីបានជាសាច់ប្រាក់ស្មើនឹងចំណែកសមាមាត្រ នៃតម្លៃទ្រព្យសកម្មសុទ្ធរបស់អង្គភាព (បណ្ដាអង្គ នៃមូលនិធិអញ្ញមញ្ញគ្មានកំណត់ ឬផលិតផលវិនិ-

យោគតភ្ជាប់ដោយអង្គនោះ), ផលប៉ះពាល់នៃការញែកនិស្សន្ទ បង្កប់ និងការគណនាសមាសធាតុនិមួយៗ គឺត្រូវវាស់វែងកិច្ចសន្យាមានលក្ខណៈទ្វេរតាមបរិមាណនៃការសងលោះដែលត្រូវសងនៅចុងការិយបរិច្ឆេទរាយការណ៍ ប្រសិនបើ អ្នកកាន់កាប់អនុវត្តសិទ្ធិ ដើម្បីលក់ឧបករណ៍ហិរញ្ញវត្ថុត្រលប់ ទៅអ្នកបោះផ្សាយវិញ។

ខ៤.៣.៨ ចរិតលក្ខណៈសេដ្ឋកិច្ច និងហានិភ័យរបស់និស្សន្ទបង្កប់ មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹង ចរិតលក្ខណៈសេដ្ឋកិច្ច និងហានិភ័យ នៃកិច្ចសន្យាបាហនិក នៅក្នុងឧទាហរណ៍ដូចខាងក្រោម។ នៅក្នុងឧទាហរណ៍ទាំងនេះ អង្គភាពមិនគិតនិស្សន្ទបង្កប់ដាច់ដោយឡែកពីកិច្ចសន្យាបាហនិកឡើយ។

(ក) និស្សន្ទបង្កប់ ដែលនៅក្នុងនោះអត្រាការប្រាក់ ឬសន្ទស្សន៍អត្រាការប្រាក់ ដែលអាចផ្លាស់ប្តូរបរិមាណការប្រាក់ ដែលនឹងត្រូវបង់ ឬត្រូវទទួលពីកិច្ចសន្យាបាហនិក ដែលមានជាប់ការប្រាក់ ឬកិច្ចសន្យាធានារ៉ាប់រងដែលមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងកិច្ចសន្យាបាហនិក ដរាបណា កិច្ចសន្យាមានលក្ខណៈទ្វេរ អាចត្រូវបានដោះស្រាយតាមរបៀបមួយ ដែលអ្នកកាន់កាប់នឹងមិនទទួលបានមកវិញជាដុំកំភួន នូវរាល់ការវិនិយោគដែលបានទទួលស្គាល់ទាំងអស់របស់វាឬយ៉ាងហោចណាស់និស្សន្ទបង្កប់ អាចមានតម្លៃទ្វេរដង នូវអត្រាចំណេញ

ដំបូងលើកិច្ចសន្យា បាហនិក របស់អ្នកកាន់កាប់ និងអាច បណ្តាលឲ្យមានអត្រាចំណេញ ដែលយ៉ាងហោចណាស់មាន ចំនួនទ្វេរដង លើអត្រាចំណេញរបស់ទីផ្សារសម្រាប់កិច្ចសន្យា មួយដែកមានលក្ខខណ្ឌដូចកិច្ចសន្យាបាហនិកដែរ។

(ខ) កម្រិតទាបបំផុតរទាបបំផុតរបស់និស្សន្ទបង្កប់ លើអត្រាការ ប្រាក់របស់បំណុលកិច្ចសន្យា ឬកិច្ចសន្យាធានារ៉ាប់រងមានការ ទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងកិច្ចសន្យាបាហនិក ដោយថា កម្រិតខ្ពស់គឺលើសអត្រាការប្រាក់ទីផ្សារ ហើយកម្រិតទាបគឺ ទាបជាងឬខាងក្រោមអត្រាការប្រាក់ទីផ្សារនៅពេលកិច្ចសន្យា ត្រូវបានធ្វើឡើង, និងកម្រិតទាប ឬកម្រិតខ្ពស់មិនត្រូវបាន លើកកំពស់ ដោយសារតែទំនាក់ទំនងទៅនឹងកិច្ចសន្យា បាហ-និក។ស្រដៀងគ្នានេះ ខមាត្រាទាំងឡាយ ដែលត្រូវបានដាក់ បញ្ចូលទៅក្នុងកិច្ចសន្យាដើម្បីទិញឬលក់ទ្រព្យសកម្ម (ឧ.កុំម៉ូ ឌីធី)ដែលបង្កើតនូវកម្រិតទាបនិងកម្រិតខ្ពស់លើថ្លៃ ដែលត្រូវ បង់ ឬត្រូវទទួលពីទ្រព្យសកម្មមានការទាក់ទងយ៉ាងជិតស្និទ្ធិ ទៅនឹង កិច្ចសន្យាបាហនិក ប្រសិនបើទាំងកម្រិតខ្ពស់ និង កម្រិតទាប មិនមែនជាទឹកប្រាក់នៅដំណាក់កាលដើមដំបូង និងមិនត្រូវបានលើកកំពស់។

(គ) និស្សន្ទបង្កប់ជារូបិយវត្ថុបរទេស នៅក្នុងកិច្ចសន្យា បាហនិក ដែលផ្តល់នូវលំហូរ នៃការទូទាត់សងប្រាក់ដើម ឬការប្រាក់

ដែលមានចែងជារូបិយវត្ថុនិងត្រូវបានបង្កប់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុបាហនិក (ឧ.សញ្ញាប័ណ្ណ ដែលមានរូបិយវត្ថុទ្វេរ) មានការទាក់ទង យ៉ាងជិតស្និទ្ធទៅនឹង ឧបករណ៍ហិរញ្ញវត្ថុបំណុលបាហនិក។ និស្សន្ទបែបនេះមិនត្រូវបានញែកចេញពីឧបករណ៍ហិរញ្ញវត្ថុបាហនិកឡើយពីព្រោះស្តង់ដាគណនេយ្យអន្តរជាតិ ២១ តម្រូវឲ្យចំណេញ ឬខាត ពីរូបិយវត្ថុបរទេសលើធាតុដែលមានតម្លៃជាទឹកប្រាក់ត្រូវតែទទួលស្គាល់នៅក្នុងផ្នែកចំណេញ ឬខាត។

(ឃ) និស្សន្ទបង្កប់ជារូបិយវត្ថុបរទេសនៅក្នុងកិច្ចសន្យា បាហនិកដែលជាកិច្ចសន្យាធានារ៉ាប់រងឬមិនមែនជាឧបករណ៍ហិរញ្ញវត្ថុ (ដូចជា កិច្ចសន្យាទិញ ឬលក់ទំនិញ មិនមែនហិរញ្ញវត្ថុ ដែលថ្លៃត្រូវបានកំណត់ជារូបិយវត្ថុបរទេស) មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងកិច្ចសន្យា បាហនិក បានផ្តល់ឲ្យដែលវាមិនមែនត្រូវបានលើកកំពស់,មិនរួមមាននូវលក្ខណៈពិសេសរបស់ជម្រើស,និងតម្រូវឲ្យការទូទាត់ត្រូវបានកំណត់ជារូបិយវត្ថុណាមួយដូចខាងក្រោមៈ

(i) រូបិយវត្ថុមុខងាររបស់ភាគី ដែលមានទម្ងន់ ចំពោះកិច្ចសន្យានោះ,

(ii) រូបិយវត្ថុដែល នៅក្នុងនោះថ្លៃរបស់ទំនិញ ឬសេវាកម្មពាក់ពន្ធ័ដែលត្រូវបានទទួល ឬត្រូវប្រគល់ ត្រូវបាន

កំណត់ជាទៀងទាត់នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មនៅជុំវិញពិភពលោក (ដូចជាដុល្លាអាមេរិកសម្រាប់ប្រតិ-បត្តិការប្រេងឆៅ) ឬ

(iii) រូបិយវត្ថុដែលត្រូវបានប្រើជាទូទៅនៅក្នុងកិច្ចសន្យាទិញ ឬលក់ទំនិញ មិនមែនហិរញ្ញវត្ថុ នៅក្នុងបរិយាកាសសេដ្ឋកិច្ច ដែលនៅក្នុងនោះប្រតិបត្តិការ បានកើតឡើង (ឧ.រូបិយវត្ថុ ដែលងាយប្តូរជាសាច់ប្រាក់ និងមិនប្រែប្រួល ដែលត្រូវបានប្រើជាទូទៅ នៅក្នុងប្រតិបត្តិការអាជីវកម្មក្នុងស្រុក ឬការជួញដូរក្រៅស្រុក)។

(ង) ជម្រើស នៃការទូទាត់មុន ដែលមាននិស្សន្ទបង្កប់ នៅក្នុងបំណុល ជាការប្រាក់សុទ្ធឬបំណុលជាប្រាក់ដើមសុទ្ធមានការទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងកិច្ចសន្យាបាហនិក ដោយបានផ្តល់ឲ្យកិច្ចសន្យាបាហនិកនោះនូវ

(i) សិទ្ធិដើម្បីទទួល បាននូវលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុដែល, នៅក្នុង ឬដោយខ្លួនវា, មិនរួមមាននិស្សន្ទបង្កប់, និង

(ii) មិនរួមមានលក្ខខណ្ឌណាមួយដែលមិនតំណាង នៅក្នុងកិច្ចសន្យាបាហនិកដើមដំបូង។

(ច) និស្សន្ទបង្កប់នៅក្នុងកិច្ចសន្យាភតិសន្យាបាហនិកមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងកិច្ចសន្យាបាហនិក ប្រសិនបើ និស្សន្ទបង្កប់នោះគឺជា

(i) សន្ទស្សន៍ទាក់ទងនឹងអតិផរណា ដូចជាសន្ទស្សន៍ នៃការទូទាត់សងភតិសន្យាធៀបនឹងសន្ទស្សន៍ថ្លៃប្រើប្រាស់ (ឲ្យតែភតិសន្យានោះមិនត្រូវបានលើកកំពស់ហើយសន្ទស្សន៍នោះទាក់ទងនឹង អតិផរណា នៅបរិយាកាសសេដ្ឋកិច្ចផ្ទាល់ខ្លួនរបស់អង្គភាព)

(ii) ថ្លៃឈ្នួលអនិមិត្តដែលផ្អែកលើចំណូលពីការលក់,

(iii) ថ្លៃឈ្នួលអនិមិត្តដែលផ្អែកលើអត្រាការប្រាក់ប្រែប្រួល។

(ឆ) លក្ខណៈពិសេសដែលមានការតភ្ជាប់ទៅនឹងឯកតាមួយបានបង្កប់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុបាហនិក ឬកិច្ចសន្យាធានារ៉ាប់រងបាហនិកមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងឧបករណ៍ហិរញ្ញវត្ថុបាហនិកឬលក្ខណៈពិសេស ដែលមានការតភ្ជាប់ទៅនឹងបាហនិក គឺជាលក្ខខណ្ឌតាមកិច្ចសន្យា ដែលតម្រូវឲ្យការទូទាត់ត្រូវបានកំណត់ជាឯកតា នៃមូលនិធិវិនយោគខាងក្នុងឬពីខាងក្រៅ។

(ជ) និស្សន្ទដែលបង្កប់ នៅក្នុងកិច្ចសន្យាធានារ៉ាប់រង មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹង កិច្ចសន្យាធានារ៉ាប់រងបាហនិក ប្រសិនបើ និស្សន្ទបង្កប់ និងកិច្ចសន្យាធានារ៉ាប់រង បាហនិក

ជាកិច្ចសន្យា ដែលពឹងអាស្រ័យលើគ្នាទៅវិញទៅមក ដែលអង្គភាពមួយមិនអាចវាស់វែង និស្សន្ទបង្កប់ដាច់ដោយឡែកពីគ្នាបាន(មានន័យថាដោយមិនពិចារណាកិច្ចសន្យាបាហនិក)។

## ឧបករណ៍ហិរញ្ញវត្ថុដែលរួមមាននានិស្សន្ទបង្កប់

១៤.៣.៩ ដូចបានកត់សម្គាល់នៅក្នុងកថាខណ្ឌ ១៤.៣.១ នៅពេលដែលអង្គភាពក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យាមានលក្ខណៈទ្វេរជាមួយនឹងបាហនិកមួយដែលមិនមែនជាទ្រព្យសកម្មដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ និងមាននិស្សន្ទបង្កប់មួយ ឬច្រើន កថាខណ្ឌ ៤.៣.៣តម្រូវឲ្យអង្គភាពកំណត់អត្តសញ្ញាណនិស្សន្ទបង្កប់នោះ វាយតម្លៃថាតើវាត្រូវបានតម្រូវឲ្យញែកចេញដាច់ពី កិច្ចសន្យាបាហនិក, និស្សន្ទទាំងឡាយណាដែលត្រូវញែកចេញពីគ្នា, ត្រូវវាស់វែងនិស្សន្ទនោះតាមតម្លៃសមស្របនៅដំណាក់កាលនៃការទទួលស្គាល់ដំបូងនិងដំណាក់កាលបន្តបន្ទាប់ទៀត។ ការតម្រូវទាំងនេះអាចកាន់តែស្មុគស្មាញ ឬធ្វើឲ្យការវាស់វែងកាន់តែមិនអាចជឿជាក់បានជាងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុទាំងមូលតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ។ សម្រាប់ហេតុផលនោះ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ

អនុញ្ញាតិឲ្យកិច្ចសន្យាមានលក្ខណៈទ្វេរទាំងមូលត្រូវបានកំណត់តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ។

ខ៤.៣.១០ ការកំណត់ អត្តសញ្ញាណបែបនេះ អាចត្រូវគេបានប្រើថាតើកថាខណ្ឌ៤.៣.៣ តម្រូវឲ្យនិស្សន្ទបង្កប់ ត្រូវតែញែកចេញពីកិច្ចសន្យាបាហនិក ឬត្រូវហាមឃាត់ការញែកចេញពីគ្នានោះ។ ទោះជាយ៉ាងណា កថាខណ្ឌ ៤.៣.៥ នឹងមិនវិនិច្ឆ័យ នូវការកំណត់អត្តសញ្ញាណកិច្ចសន្យាបាហនិក តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៅក្នុងករណីនានា ដែលបានកំណត់នៅក្នុងកថាខណ្ឌ៤.៣.៥(ក) និង (ខ) ពីព្រោះការធ្វើដូច្នោះនឹងមិនកាត់បន្ថយភាពស្មុគស្មាញ ឬបង្កើនភាព អាចជឿជាក់បានឡើយ។

## ការវាយតម្លៃនិស្សន្ទបង្កប់

ខ៤.៣.១១ ដោយអនុលោមតាមកថាខណ្ឌ ៤.៣.៣ អង្គភាព ត្រូវវាយតម្លៃថាតើនិស្សន្ទបង្កប់ត្រូវបានតម្រូវឲ្យញែកចេញពីកិច្ចសន្យាបាហនិកនិងត្រូវចាត់ទុកថាជានិស្សន្ទ នៅពេលដែលអង្គភាពក្លាយជាភាគីមួយក្នុងកិច្ចសន្យាជាលើកដំបូង។ ការវាយតម្លៃជាបន្តទៀត ត្រូវបានហាមឃាត់ ដរាបណា មានការផ្លាស់ប្តូរលក្ខខណ្ឌ នៃកិច្ចសន្យាដែលនឹងកែប្រែ ជាដុំកំភួននូវលំហូរសាច់ប្រាក់ ដែលបើមិនដូច្នោះទេ គេនឹងត្រូវបានតម្រូវតាម

កិច្ចសន្យា ដែលនៅក្នុងនោះ ការវាយតម្លៃនឹងត្រូវបានតម្រូវ។ អង្គភាព កំណត់ថាតើ ការកែប្រែចំពោះលំហូរសាច់ប្រាក់នឹងមានភាពដុំកំភួន ដោយពិចារណា អំពីវិសាលភាពលំហូរសាច់ប្រាក់អនាគតដែលពាក់ពន្ធ័នឹងនិស្សន្ទ, កិច្ចសន្យាបាហនិក ឬទាំងពីរបានផ្លាស់ប្តូរ និងថាតើ ការផ្លាស់ប្តូរមានភាពដុំកំភួនចំពោះលំហូរសាច់ប្រាក់រំពឹងទុកពីមុនៗរបស់កិច្ចសន្យា ឬយ៉ាងណា។

ខ៤.៣.១២ កថាខណ្ឌខ ៤.៣.១១ មិនអនុវត្តចំពោះនិស្សន្ទបង្កប់ នៅក្នុងកិច្ចសន្យាដែលទទួលបាននៅក្នុងៈ

(ក) ការរួមបញ្ចូលអាជីវកម្ម (ដូចបានកំណត់ នៅក្នុងស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៣ *ការរួមបញ្ចូលអាជីវកម្ម*),

(ខ) ការរួមបញ្ចូលអង្គភាព ឬអាជីវកម្ម ក្រោមការគ្រប់គ្រងរួមគ្នា ដូចបានបរិយាយ នៅក្នុងកថាខណ្ឌ ខ១-ខ៤ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៣, ឬ

(គ) ការបង្កើតក្រុមហ៊ុនរួមទុន ដូចបានកំណត់អត្ថន័យ នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុន*

*រួមទុន* ឬការវាស់វែង ដែលអាចមានរបស់ពួកគេ នៅកាលបរិច្ឆេទ នៃការទិញ[2]។

## ការចាត់ថ្នាក់ឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ(ផ្នែក៤.៤)

ខ៤.៤.១ កថាខណ្ឌ៤.៤.១តម្រូវឲ្យអង្គភាពចាត់ថ្នាក់ឡើងវិញទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើកម្មវត្ថុរបស់ម៉ូឌែលអាជីវកម្មរបស់ អង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មទាំងនោះផ្លាស់ប្តូរ។ ការផ្លាសើប្តូរបែបនេះនឹងត្រូវបានរំពឹងថា មិនសូវជាញឹកញាប់ឡើយ។ ការផ្លាស់ប្តូរទាំងបែបនេះត្រូវតែបានកំណត់ដោយអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អង្គភាព ដែលកើតចេញពី ការផ្លាស់ប្តូរបរិយាកាសខាងក្នុងនិងបរិយាយកាសខាងក្រៅ និងត្រូវតែមានភាពដុំកំភួនចំពោះកិច្ចប្រតិបត្តិការរបស់អង្គភាព និងអាចពន្យល់ បង្ហាញបានទៅអ្នកខាងក្រៅ។ ឧទាហរណ៍នៃការផ្លាស់ប្តូរ ម៉ូឌែលអាជីវកម្មរួមមានដូចខាងក្រោមៈ

(ក) អង្គភាពមានផលបត្រប្រាក់កម្ចីពាណិជ្ជកម្មដែលខ្លួនកាន់កាប់ដើម្បីលក់នៅក្នុងរយៈពេលខ្លី។អង្គភាពតម្រូវឲ្យក្រុមហ៊ុនមួយដែលគ្រប់គ្រងប្រាក់កម្ចីពាណិជ្ជកម្មនិងមានម៉ូឌែលអាជីវកម្មដែលកាន់កាប់កម្ចីនោះដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។

[2] ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ១៣សង្កត់ធ្ងន់លើការទិញកិច្ចសន្យាដែលមាននិស្សន្ទបង្កប់នៅក្នុងការរួមបញ្ចូលអាជីវកម្ម។

ផលបត្រប្រាក់កម្ចីពាណិជ្ជកម្មមិនសម្រាប់លក់ទៀតទេ, ហើយ ផលបត្រនោះ ត្រូវបានគ្រប់គ្រងរួមគ្នាជាមួយនឹងប្រាក់កម្ចីពាណិជ្ជកម្មបានទទួល ហើយផលបត្រទាំងអស់នោះត្រូវបានកាន់កាប់ដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។

(ខ) ក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុសម្រេចចិត្ត បិទចោលអាជីវកម្មទ្រព្យដាក់បញ្ចាំលក់រាយរបស់ខ្លួន។ អាជីវកម្មនោះលែងទទួលយកប្រតិបត្តិការអាជីវកម្មថ្មីហើយក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុធ្វើសកម្មភាពម៉ាឃីតទីងយ៉ាងសកម្ម ដើម្បីលក់ចេញផលបត្រប្រាក់កម្ចីមានទ្រព្យដាក់បញ្ចាំរបស់ខ្លួន។

ខ៤.៤.២ ការផ្លាស់ប្តូរនៅក្នុងកម្មវត្ថុនៃម៉ូឌែលអាជីវកម្មរបស់អង្គភាព ត្រូវតែមានផលប៉ះពាល់នៅមុនកាលបរិច្ឆេទនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុសម្រេចចិត្តថា នៅថ្ងៃទី១៥ ខែកុម្ភៈ ត្រូវបិទចោលអាជីវកម្មទ្រព្យដាក់បញ្ចាំលក់រាយរបស់ខ្លួន និងហេតុដូច្នេះ ត្រូវតែចាត់ថ្នាក់ឡើងវិញរាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានផលប៉ះពាល់នៅថ្ងៃទី១ ខែមេសា (មានន័យថា ថ្ងៃដំបូងនៃការិយបរិច្ឆេទរាយការណ៍របស់អង្គភាព), អង្គភាព មិនត្រូវទទួលយកប្រតិបត្តិការអាជីវកម្មដាក់បញ្ចាំថ្មី ឬបើមិនដូច្នេះទេ វាពាក់ពន្ធ័ទៅនឹងសកម្មភាព ដែលមានសង្គតិភាពជាមួយនឹងអតីត ម៉ូឌែលអាជីវកម្ម នបន្ទាប់ពីថ្ងៃទី១៥ ខែកុម្ភៈ។

២៤.៤.៣ ខាងក្រោមនេះមិនមែនជាការផ្លាស់ប្ដូរម៉ូឌែលអាជីវកម្មឡើយ:

(ក) ការផ្លាស់ប្ដូរបំណងទាក់ទងនឹងទ្រព្យសកម្មជាក់លាក់ណាមួយ (បើទោះបីជា នៅក្នុងកាលៈទេសៈ នៃការផ្លាស់ប្ដូរជាដុំកំភួន នៅក្នុងលក្ខខណ្ឌរបស់ទីផ្សារ)

(ខ) ការលិចបាត់ជាបណ្ដោះអាសន្ន នៃទីផ្សារណាមួយរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(គ) ការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ រវាងផ្នែកនានា របស់អង្គភាពដែលមានម៉ូឌែលអាជីវកម្មផ្សេងគ្នា។

## ការវាស់វែង(ជំពូក៥)

### ការវាស់វែងលើកដំបូង(ផ្នែក ៥.១)

២៥.១.១ តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុនៅដំណាក់កាល នៃការទទួលស្គាល់ដំបូង ជាធម្មតា គឺជាថ្លៃប្រតិបត្តិការ (មានន័យថា តម្លៃសមស្របនៃផលតបសងបានផ្ដល់ឱ្យឬបានទទួល, មើលកថាខណ្ឌ ២៥.៤.៨)។ ទោះជាយ៉ាងណា ប្រសិនបើផ្នែកមួយនៃផលតបសងបានផ្ដល់ឱ្យ ឬបានទទួលគឺសម្រាប់អ្វីមួយ ដែលមិនមែនជាឧបករណ៍ហិរញ្ញវត្ថុ, តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មាន ដោយប្រើបច្ចេកទេស វាយតម្លៃ (មើលកថាខណ្ឌ ២៥.៤.៦ - ២៥.៤.១២)។ ឧទាហរណ៍ តម្លៃសមស្របរបស់ប្រាក់កម្ចីរយៈពេលវែង ឬបរិមាណត្រូវទទួល

រយៈពេលវែង ដែលមិនមានការប្រាក់ អាចត្រូវបានប៉ាន់ស្មានតាមតម្លៃបច្ចុប្បន្ននៃលំហូរចូលសាច់ប្រាក់នាពេលអនាគតទាំងអស់ ដែលបានបែងចែក ដោយប្រើអត្រាការប្រាក់ឧត្តមភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលស្រដៀងគ្នា (ស្រដៀងគ្នាក្នុងរូបិយវត្ថុ, រយៈពេល, ប្រភេទអត្រាការប្រាក់និងកត្តាផ្សេងៗទៀត) ជាមួយនឹងចំណាត់ថ្នាក់ឥណទានស្រដៀងគ្នា។ បរិមាណបន្ថែមណាមួយដែលបានឲ្យខ្ចី គឺជាចំណាយ ឬការថយចុះ នៃប្រាក់ចំណូលដរាបណាវាមានគុណវុឌ្ឍិសម្រាប់ការទទួលស្គាល់ដូចជាប្រភេទផ្សេងទៀតនៃទ្រព្យសកម្ម។

១៥.១.២ ប្រសិនបើ អង្គភាពចាប់ផ្តើមនូវប្រាក់កម្ចីមួយ ដែលមានអត្រាការប្រាក់មិនមែនទីផ្សារ (ឧ.៥ភាគរយ នៅពេលដែលអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីស្រដៀងគ្នាគឺ ៨ភាគរយ) និងទទួលបាននូវថ្លៃឈ្នួលផ្ទាល់ថាជាកម្រៃតបសង, អង្គភាពទទួលស្គាល់ប្រាក់កម្ចីតាមតម្លៃសមស្រប មានន័យថា ថ្លៃឈ្នួលសុទ្ធដែលខ្លួនត្រូវទទួល។

## ការវាស់វែងគ្រាប់បន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ(ផ្នែក៥.២)

១៥.២.១ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុមួយ ដែលត្រូវបានទទួលស្គាល់ពីមុនថាជាទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមតម្លៃសម

ស្រប ហើយតម្លៃសមស្របរបស់វាថយចុះក្រោមសូន្យ, វាគឺជាបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែង ដោយអនុលោមតាមកថាខណ្ឌ ៤.២.១។ ទោះជាយ៉ាងណា កិច្ចសន្យាមានលក្ខណៈទ្វេរដែលមានបាហនិកជាទ្រព្យសកម្មស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះជានិច្ចជាកាលត្រូវវាស់វែងដោយអនុលោមតាមកថាខណ្ឌ ៤.៣.២។

១៥.២.២ ឧទាហរណ៍ខាងក្រោមពន្យល់បង្ហាញពីគណនេយ្យ សម្រាប់ថ្លៃដើមប្រតិបត្តិការនៅដំណាក់កាលនៃការវាស់វែងដំបូងនិងការវាស់វែងជាបន្តបន្ទាប់ទៀត នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃសមស្របជាមួយនឹងការផ្លាស់ប្តូរ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ ដោយអនុលោមតាមកថាខណ្ឌ ៥.៧.៥។ អង្គភាពទទួលបានទ្រព្យសកម្មមួយមានតម្លៃ ១០០ ឯកតារូបិយវត្ថុ បូកថែមប្រាក់ កម្រៃជើងសារ ២ ឯកតារូបិយវត្ថុ។ជាដំបូង អង្គភាពទទួលស្គាល់ទ្រព្យសកម្ម មានតម្លៃ ១០២ ឯកតារូបិយវត្ថុ។ នៅចុងការិយបរិច្ឆេទរាយការណ៍មួយថ្ងៃក្រោយមក ថ្លៃទីផ្សារសម្រង់របស់ទ្រព្យសកម្មគឺ ១០០ ឯកតារូបិយវត្ថុ។ ប្រសិនបើ ទ្រព្យសកម្មត្រូវបានលក់ ប្រាក់កម្រៃជើងសារចំនួន ៣ ឯកតារូបិយវត្ថុ នឹងត្រូវបានបង់ឲ្យ។ នៅកាលបរិច្ឆេទនោះ អង្គភាពវាស់វែងទ្រព្យសកម្មតាមតម្លៃ ១០០ ឯកតារូបិយវត្ថុ (ដោយមិនគិតកម្រៃជើងសារនៅកាលបរិច្ឆេទ

នោះឡើយ។ និងទទួលស្គាល់ការខាតបង់២ឯកតារូបិយវត្ថុ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ។

**ការវាស់វែងតម្លៃសមស្រប (ផ្នែក៥.៤)**

១៥.៤.១ នៅក្រោមនិយមន័យ នៃតម្លៃសមស្រប គឺជាការឧបមារថាអង្គភាពនឹងដំណើរការអាជីវកម្មជានិរន្តន៍ដោយមិនមានបំណងណាមួយភាពចាំបាច់ណាមួយដើម្បីធ្វើការជម្រះបញ្ជី, កាត់បន្ថយជាសារវ័ន្តនូវទំហំនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ឬធ្វើប្រតិបត្តិការនៅក្នុងលក្ខខណ្ឌដ៏អាក្រក់។ ហេតុដូច្នេះ តម្លៃសមស្រប មិនមែនជាបរិមាណដែលអង្គភាពនឹងត្រូវទទួល ឬត្រូវបង់នៅក្នុងប្រតិតបត្តិការចាប់បង្ខំ, ការជម្រះបញ្ជីដោយមិនស្ម័គ្រចិត្ត, ឬការលក់ចេញដោយបង្ខំ។ ទោះជាយ៉ាងណាតម្លៃសមស្របឆ្លុះបញ្ចាំងគុណភាពឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុ។

១៥.៤.២ ស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុនេះ ប្រើពាក្យ "ថ្លៃលក់" និង "ថ្លៃទិញ" (ជួនកាលសំដៅដល់ "ថ្លៃលក់បច្ចុប្បន្ន") នៅក្នុងបរិបទនៃថ្លៃទីផ្សារបានធ្វើសម្រង់, និងពាក្យ "គំលាតថ្លៃទិញ -ថ្លៃលក់" ដើម្បីរួមបញ្ចូលថ្លៃដើមប្រតិបត្តិការ។ ការកែសម្រួលផ្សេងៗ ដើម្បីបានឈានដល់ តម្លៃសមស្រប (ឧ.ហានិភ័យឥណទានសហភាគី) មិនត្រូវបានបញ្ចូលនៅក្នុងពាក្យ "គំលាតថ្លៃទិញ -ថ្លៃលក់"។

## មានទីផ្សារសកម្ម:ថ្លៃសម្រង់

១៥.៤.៣ ឧបករណ៍ហិរញ្ញវត្ថុមួយ ត្រូវបានចាត់ទុកថាបានធ្វើសម្រង់ថ្លៃនៅក្នុងទីផ្សារសកម្ម ប្រសិនបើ ថ្លៃសម្រង់អាចរកបានជាទៀងទាត់និងមានរួចជាស្រេចពីទីផ្សារប្តូរប្រាក់ឈ្មួញកណ្តាល, ឈ្មួញកម្រៃជើងសារ, ក្រុមអាជីវកម្ម, សេវាកម្ម ឬភ្នាក់ងារគ្រប់គ្រងថ្លៃ, ហើយថ្លៃទាំងនោះតំណាងឲ្យប្រតិបត្តិការទីផ្សារដែលកំពុងកើតឡើងជាទៀងទាត់និងជាក់ស្តែងលើមូលដ្ឋាននៃការជួញដូរស្មើភាពគ្នា។ តម្លៃសមស្របត្រូវបានកំណត់ថាជាថ្លៃដែលបានព្រមព្រៀងរវាងអ្នកលក់ និងអ្នកទិញ ដែលមានឆន្ទៈនៅក្នុងប្រតិបត្តិការនៃការជួញដូរស្មើភាពគ្នា។ គោលបំណង នៃការកំណត់តម្លៃសមស្របសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានជួញដូរនៅក្នុងទីផ្សារសកម្ម គឺដើម្បីទទួលបានថ្លៃមួយ ដែលប្រតិបត្តិការមួយនឹងកើតឡើងនៅចុងការិយបរិច្ឆេទរាយការណ៍នៅក្នុងឧបករណ៍ហិរញ្ញវត្ថុនោះ (មានន័យថា ដោយមិនមានការកែប្រែ ឬវេចខ្ចប់ឡើងវិញនូវឧបករណ៍ហិរញ្ញវត្ថុនោះឡើយ) នៅក្នុងទីផ្សារសកម្ម ដែលមានអាទិភាពបំផុតដែលអង្គភាពនឹងអាចទទួលបានឆាប់ៗ។ ទោះជាយ៉ាងណា អង្គភាពកែសម្រួលថ្លៃនៅក្នុងទីផ្សារដែលមានអាទិភាពបំផុត ដើម្បីឆ្លុះបញ្ចាំងនូវភាពខុសគ្នានៅក្នុងហានិភ័យឥណទានសមាភា គឺរវាងឧបករណ៍

ហិរញ្ញវត្ថុដែលជួញដូរនៅក្នុងទីផ្សារនោះនិងឧបករណ៍ហិរញ្ញវត្ថុដែលកំពុងវាយតម្លៃ។អត្ថិភាពនៃការធ្វើសម្រាប់ថ្លៃជាសាធារណៈនៅក្នុងទីផ្សារសកម្ម គឺជាភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្រប និងនៅពេលដែលពួកវា ត្រូវបានប្រើ ដើម្បីវាស់វែងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

១៥.៤.៤ ថ្លៃទីផ្សារសម្រង់ដែលសមរម្យសម្រាប់ទ្រព្យសកម្មមួយ ដែលបានកាន់កាប់ ឬបំណុលដែលត្រូវបបោះផ្សាយ ជាធម្មតាគឺជាថ្លៃលក់បច្ចុប្បន្ន, ហើយសម្រាប់ទ្រព្យសកម្មមួយដែលកំពុង ត្រូវបានទិញឬបំណុលដែលបានកាន់កាប់ គឺជាថ្លៃលក់។ នៅពេលដែលអង្គភាពមាទ្រព្យសកម្ម និងបំណុល ដែលកាត់កងជាមួយនឹងហានិភ័យទីផ្សារ, អង្គភាពអាចប្រើថ្លៃទីផ្សារពាក់កណ្តាលដើម្បីធ្វើជាមូលដ្ឋាន សម្រាប់ការកសាងតម្លៃសមស្របសម្រាប់ជាការកាត់កងស្ថានភាពហានិភ័យ ហើយអនុវត្តថ្លៃទិញ ឬថ្លៃលក់ទៅលើស្ថានភាពដើមគ្រាសុទ្ធនៅពេលដែលសមស្រប។ នៅពេលដែលថ្លៃទិញ និងថ្លៃលក់បច្ចុប្បន្ន មិនអាចរកបានថ្លៃនៃប្រតិបត្តិការថ្មីៗបំផុតនឹងផ្តល់ជាភស្តុតាង នៃតម្លៃសមស្របបច្ចុប្បន្នរហូតដល់វាមិនមានការផ្លាស់ប្តូរជាដុំកំភួន នៅក្នុងកាលៈទេសៈសេដ្ឋកិច្ចចាប់តាំងពីពេលនៃការកើតប្រតិបត្តិការ។ ប្រសិនបើ លក្ខខណ្ឌបានផ្លាស់ប្តូរតាំងពីពេលនៃប្រតិតបត្តិការ (ឧ. ការផ្លាសប្តូរអត្រាការប្រាក់និរភ័យ បន្ទាប់ពីមានសម្រង់ថ្លៃ

ថ្មីៗបំផុត សម្រាប់សញ្ញាប័ណ្ណក្រុមហ៊ុនមួយ), តម្លៃសមស្របផ្ទុះបញ្ចាំង ការផ្លាស់ប្តូរលក្ខខណ្ឌ ដោយយោងតាមថ្លៃ ឬអត្រាបច្ចុប្បន្នសម្រាប់ឧបករណ៍ហិរញ្ញវត្ថុស្រដៀងគ្នានៅពេល ដែលសមស្រប។ ស្រដៀងគ្នានេះ ប្រសិនបើអង្គភាពអាចបង្ហាញថាថ្លៃប្រតិបត្តិការចុងក្រោយមិនមែនជាតម្លៃសមស្រប (ឧ.ដោយសារតែ វាបានឆ្លុះបញ្ចាំងបរិមាណដែលអង្គភាពមួយត្រូវទទួលបានឬត្រូវបង់នៅក្នុងប្រតិបត្តិការចាប់បង្ខំ,ការជម្រះបញ្ជី ដោយមិនស្ម័គ្រចិត្តឬការលក់ចោលដោយចាប់បង្ខំ) ថ្លៃនោះត្រូវតែកែសម្រួល។ តម្លៃសមស្របរបស់ផលបត្រនៃឧបករណ៍ហិរញ្ញវត្ថុគឺជាផលិតផល នៃឯកតាឧបករណ៍ហិរញ្ញវត្ថុជាច្រើន និងថ្លៃទីផ្សារសម្រង់របស់វា។ ប្រសិនបើការធ្វើសម្រង់ថ្លៃជាសាធារណៈនៅក្នុងទីផ្សារសកម្មមួយមិនកើតឡើង សម្រាប់ឧបករណ៍ហិរញ្ញវត្ថុទាំងមូលរបស់ខ្លួន ប៉ុន្តែទីផ្សារសកម្មកើតឡើងសម្រាប់ផ្នែកនានា នៃសមាសធាតុរបស់ខ្លួន, តម្លៃសមស្រប ត្រូវបានកំណត់ដោយឈរលើមូលដ្ឋានថ្លៃទីផ្សារពាក់ពន្ធ័សម្រាប់ផ្នែកនៃសមាសធាតុនោះ។

១៥.៤.៥ ប្រសិនបើអត្រា (មិនមែនថ្លៃ) ត្រូវបានធ្វើសម្រង់នៅក្នុងទីផ្សារសកម្ម អង្គភាពប្រើអត្រាសម្រង់តាមទីផ្សារនោះដើម្បីធ្វើជាធាតុចូលនៅក្នុងបច្ចេកទេសវាយតម្លៃ ដើម្បីកំណត់តម្លៃសមស្រប។ ប្រសិនបើ អត្រាសម្រង់ តាមទីផ្សារមិនរាប់បញ្ចូលហានិភ័យ

ឥណទាន ឬកត្តាផ្សេងទៀត ដែលអ្នកចូលរួមទីផ្សារនឹងរាប់បញ្ចូល ទៅក្នុងការវាយតម្លៃឧបករណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវកែសម្រួលសម្រាប់កត្តាទាំងនោះ។

## មិនមានទីផ្សារសកម្ម: បច្ចេកទេសវាយតម្លៃ

ខ៥.៤.៦ ប្រសិនបើ ទីផ្សារសម្រាប់ឧបករណ៍ហិរញ្ញវត្ថុមួយ មិនមែនជាទីផ្សារសកម្ម អង្គភាព បង្កើតតម្លៃសមស្រប ដោយការប្រើបច្ចេកទេសវាយតម្លៃ។បច្ចេកទេសវាយតម្លៃរួមមានប្រតិបត្តិការទីផ្សារធម្មតាថ្មីៗរវាងភាគីដែលមានឆន្ទៈ ប្រសិនបើមាន ដោយសំអាងដល់តម្លៃសមស្របបច្ចុប្បន្នរបស់ឧបករណ៍ហិរញ្ញវត្ថុមួយផ្សេងដែលមានភាពដូចគ្នាយ៉ាងខ្លាំង, ការវិភាគសាច់ប្រាក់ដែលបានធ្វើអប្បហារ និងម៉ូលខែលកំណត់ថ្លៃ ជម្រើសពិសេស។ ប្រសិនបើមានបច្ចេកទេសវាយតម្លៃ ដែលត្រូវបានប្រើជាទូទៅដោយអ្នកចូលរួមទីផ្សារ ដើម្បីកំណត់ថ្លៃ ឧបករណ៍ហិរញ្ញវត្ថុ ហើយបច្ចេកទេសនោះត្រូវបានគេបង្ហាញដើម្បីផ្តល់ នូវការប៉ាន់ស្មាន ដែលអាចជឿជាក់បាននៃថ្លៃដែលបានទទួលបាននៅក្នុងប្រតិបត្តិការទីផ្សារជាក់ស្តែង, អង្គភាពប្រើបច្ចេកទេសនោះ។

ខ៥.៤.៧ គោលបំណងនៃការប្រើវិធីសាស្ត្រនៃការវាយតម្លៃ គឺត្រូវបង្កើតនូវថ្លៃប្រតិបត្តិការដែលនឹងមាននៅលើកាលបរិច្ឆេទនៃការវាស់

វែងនៅក្នុងការដោះដូរស្មើភាពគ្នាដែលបានជម្រុញដោយផល បាន ពីអាជីវកម្មធម្មតា។ តម្លៃសមស្រប ត្រូវបានប៉ាន់ស្មាន ដោយឈរលើមូលដ្ឋាន នៃលទ្ធផល នៃបច្ចេកទេសវាយតម្លៃ ដែលបានមកពី ការប៉ាន់ស្មានជាក់ស្តែង នៃតម្លៃសមស្រប ប្រសិនបើ (ក) វាឆ្លុះបញ្ចាំងដោយសមហេតុផលអំពីរបៀប ដែលទីផ្សារអាចនឹងត្រូវបានគេរំពឹង ដើម្បីកំណត់ថ្លៃឧបករណ៍ ហិរញ្ញវត្ថុ និង (ខ) ធាតុចូលនៃបច្ចេកទេសវាយតម្លៃ ដែល តំណាងដោយសមសហេតុផលនូវការរំពឹងរបស់ទីផ្សារ និងការ វាស់វែងកត្តាហានិភ័យផលចំណេះដែលបង្កប់នៅក្នុងឧបករណ៍ ហិរញ្ញវត្ថុនោះ។

១៥.៤.៨ ដូច្នេះហើយ បច្ចេកទេសវាយតម្លៃ (ក) រួមបញ្ចូលនូវរាល់កត្តា នានា ដែលអ្នកចូលរួមទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ និង (ខ) បច្ចេកទេសវាយតម្លៃមានសង្គតិភាព ជាមួយនឹងវិធី សាស្ត្រសេដ្ឋកិច្ច ដែលបានទទួលយកសម្រាប់ការថ្លៃឧបករណ៍ ហិរញ្ញវត្ថុ។ ជាទៀតទាត់ អង្គភាព ក្រិតនូវបច្ចេកទេសវាយតម្លៃ និងធ្វើតេស្ត ដើម្បីរកសុពលភាពរបស់វាដោយប្រើថ្លៃ ដែល បាន មកពីប្រតិបត្តិការទីផ្សារថ្មីៗ ដែលអាចអង្កេតបាននៅក្នុង ឧបករណ៍ហិរញ្ញវត្ថុដូចគ្នា (មានន័យថាមិនមានការកែប្រែ ឬ រៀបចំឡោះងវិញឡើយ) ឬផ្អែកលើទិន្នន័យទីផ្សារ ដែលអាច អង្កេតបាដែលមានស្រាប់។ អង្គភាព ទទួលបានទិន្នន័យទីផ្សារ

ដែលមានសង្គតិភាពជាមួយនឹងទីផ្សារដូចគ្នា ដែលឧបករណ៍ហិរញ្ញវត្ថុនោះមានការបង្ករបង្កើត ឬត្រូវបានទិញ។ ភស្តុតាងល្អបំផុតនៃតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ នៅដំណាក់កាលនៃការទទួលស្គាល់ដំបូងគឺជាថ្លៃប្រតិបត្តិការ (មានន័យថាតម្លៃសមស្រប នៃផលតបសងបានផ្តល់ឲ្យ ឬបានទទួល) ដរាបណា តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុនោះ ត្រូវបានបង្ហាញភស្តុតាង ដោយការប្រៀបធៀបជាមួយនឹងប្រតិបត្តិការទីផ្សារថ្មីៗ ដែលអាចអង្កេតបានផ្សេងទៀត នៅក្នុងឧបករណ៍ហិរញ្ញវត្ថុដូចគ្នា (មានន័យថា មិនមានការកែប្រែឬការរៀបចំឡើងវិញឡើយ) ឬបានផ្អែកលើបច្ចេកទេសវាយតម្លៃ ដែលអថេររបស់វាដាក់បញ្ចូល តែនៅក្នុងទិន្នន័យដែលបានពីទីផ្សារអាចអង្កេតបាន។

ខ៥.៤.៩ ការវាស់វែងជាបន្តបន្ទាប់ទៀត នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ និងការទទួលស្គាល់ជាបន្តបន្ទាប់នៃចំណេញ ឬខាត ត្រូវតែមានសង្គតិភាព ជាមួយការតម្រូវ នៃស្តង់ដារបាយការណ៍ទាកើទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ។ការអនុវត្តន៍កថាខណ្ឌ ខ៥.៤.៨ អាចបណ្តាឲ្យមិនមានចំណេញ ឬខាតបង់ដែលនឹងត្រូវទទួលស្គាល់ បន្ទាប់ពីការទទួលស្គាល់ឡើកដំបូង តែនៅក្នុងកម្រិតដែលវាកើតឡើងពីការផ្លាស់ប្តូរនៅក្នុងកត្តាមួយ

(រួមមានទាំងពេលវេលា) ដែលអ្នកចូលរួមទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ។

ខ៥.៤.១០ ការទិញដំបូងឬការបង្កបង្កើតដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬការកកើតឡើងនៃបំណុលហិរញ្ញវត្ថុគឺជាប្រតិបត្តិការទីផ្សារដែលផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការប៉ាន់ស្មានតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ។ជាពិសេស ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុនោះគឺជាឧបករណ៍បំណុល (ដូចជា ប្រាក់កម្ចី), តម្លៃសមស្របរបស់វាអាចត្រូវបានប៉ាន់ស្មានដោយសំអាងលើលក្ខខណ្ឌទីផ្សារដែលកើតឡើង នៅកាលបរិច្ឆេទនៃការទិញ ឬការបង្កបង្កើតរបស់វា ហើយលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ឬអត្រាការប្រាក់ ដែលបច្ចុប្បន្នបានកំណត់ដោយអង្គភាពនោះ ឬដោយអង្គភាពផ្សេងទៀត សម្រាប់ឧបករណ៍ហិរញ្ញវត្ថុបំណុលស្រដៀងគ្នា (មានន័យថាកាលវេលាដល់កំណត់សង,លំហូរសាច់ប្រាក់, រូបិយវត្ថុ, ហានិភ័យឥណទាន, ទ្រព្យដាក់បញ្ចាំ,និង មូលដ្ឋានការប្រាក់ស្រដៀងគ្នា)។ ម៉្យាងវិញទៀត ដោយមិនមានការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់កូនបំណុល និងគំលាតឥណទានអាចអនុវត្តបាន បន្ទាប់ពីការបង្កបង្កើតឧបករណ៍ហិរញ្ញវត្ថុបំណុល, ការប៉ាន់ស្មាននៃអត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន អាចទទួលបានដោយការប្រើអត្រាការប្រាក់ស្តង់ដាសម្រាប់ប្រៀបធៀបដែលឆ្លុះបញ្ចាំងពីគុណភាពឥណទានដែលល្អប្រសើរជាង

ឧបករណ៍ហិរញ្ញវត្ថុបំណុល ដែលមានស្រាប់, ដោយកាន់កាប់ដោយមាំទាំនូវគំលាតឥណទាន, និងកែសម្រួល សម្រាប់ការផ្លាស់ប្ដូរ នៅក្នុងអត្រាការប្រាក់ស្តង់ដា សម្រាប់ប្រៀបធៀបពីកាលបរិច្ឆេទនៃការបង្កបង្កើត។ ប្រសិនបើ លក្ខខណ្ឌបានផ្លាស់ប្ដូរតាំងពីប្រតិបត្តិការទីផ្សារថ្មីៗបំផុត, ការផ្លាស់ប្ដូរនៅក្នុងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុកំពុងត្រូវបានវាយតម្លៃដោយសំអាងលើថ្លៃឬអត្រាបច្ចុប្បន្ន សម្រាប់ឧបករណ៍ហិរញ្ញវត្ថុស្រដៀងគ្នា, ដោយបានកែសម្រួលយ៉ាងសមរម្យ សម្រាប់ភាពខុសគ្នានានាដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ ដែលកំពុងត្រូវបានវាយតម្លៃ។

១៥.៤.១១ ព័ត៌មានដូចគ្នាអាចរកមិនបាននាកាលបរិច្ឆេទ នៃការវាស់វែងនិមួយៗ។ ឧទាហរណ៍ នៅកាលបរិច្ឆេទដែលអង្គភាពធ្វើប្រាក់កម្ចី ឬទិញឧបករណ៍ហិរញ្ញវត្ថុបំណុលដែលមិនត្រូវបានជួញដូរយ៉ាងសកម្ម, អង្គភាពមានថ្លៃប្រតិបត្តិការដែលជាថ្លៃទីផ្សារផងដែរ។ ទោះជាយ៉ាងណា មិនមានព័ត៌មានអំពីប្រតិបត្តិការថ្មី អាចរកបាននៅកាលបរិច្ឆេទនៃការវាស់វែងបន្ទាប់ និង, ទោះបីជាអង្គភាព អាចកំណត់បាននូវកម្រិតទូទៅរបស់ អត្រាការប្រាក់ទីផ្សារ, អង្គភាពអាចមិនដឹងអំពីកម្រិតឥណទាន ឬហានិភ័យផ្សេងៗ ដែលអ្នកចូលរួមទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃឧបករណ៍ហិរញ្ញវត្ថុនាកាលបរិច្ឆេទនោះ។ អង្គភាពមួយអាច

មិនមានព័ត៌មានពីប្រតិបត្តិការថ្មីៗដើម្បីកំណត់គំលាតឥណទាន សមរម្យមួយទៅលើអត្រាការប្រាក់មូលដ្ឋាន ដើម្បីប្រើនៅក្នុងការកំណត់អត្រាអប្បហារ សម្រាប់ការគណនាតម្លៃបច្ចុប្បន្ន។ វាសមហេតុសមផល ដើម្បីសន្មតថា, ពេលមិនមានភស្តុតាងដែលផ្ទុយពីនេះ, គ្មានការផ្លាស់ប្តូរបានកើតឡើងនៅក្នុងគំលាតដែលបានកើតឡើងនៅកាលបរិច្ឆេទដែលប្រាក់កម្ចីត្រូវបានខ្ចី។ ទោះបីជាយ៉ាងណា អង្គភាពត្រូវបានគេរំពឹងថា នឹងធ្វើខិតខំដោយសមហេតុផលដើម្បីកំណត់ថាតើមានភស្តុតាង ដែលបានធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងកត្តាទាំងនោះ ឬយ៉ាងណា។ នៅពេលដែលភស្តុតាងនៃការផ្លាស់ប្តូរបានកើតឡើង អង្គភាពនឹងពិចារណា អំពីផលប៉ះពាល់ នៃការផ្លាស់ប្តូរនោះ នៅក្នុងការកំណត់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុនោះ។

១៥.៤.១២ នៅក្នុងការអនុវត្តន៍ការវិភាគលំហូរសាច់ប្រាក់បានធ្វើអប្បហារ អង្គភាព ប្រើអត្រាអប្បហារមួយ ឬច្រើន ដែលស្មើនឹងអត្រាចំណេញធម្មតាសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខខណ្ឌ និងចរិតលក្ខណៈដូចគ្នាយ៉ាងខ្លាំង ដោយរួមមានទាំងគុណភាពឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុ, រយៈពេលនៅសល់ ដែលអត្រាការប្រាក់តាមកិច្ចសន្យាត្រូវបានគេកំណត់, រយៈពេលនៅសល់នៃការសងត្រវិញប្រាក់ដើម និងរូបិយវត្ថុដែលប្រើនៅក្នុងការទូទាត់។ បរិមាណត្រូវទទួលរយៈពេលខ្លី និងបរិមាណត្រូវ

សងរយៈពេលខ្លីដែលមិនមានចែងអំពីអត្រាការប្រាក់អាចត្រូវបានវាស់វែងតាមបរិមាណលើវិក័យបត្រ ប្រសិនបើ ផលប៉ះពាល់នៃការធ្វើអប្បហារមិនសូវមានភាពជុំកំភួន។

## ធាតុចូលនៅក្នុងបច្ចេកទេសវាយតម្លៃ

ខ៥.៤.១៣ បច្ចេកទេសសមរម្យមួយសម្រាប់ការប៉ានស្មាន តម្លៃសមស្រប របស់ឧបករណ៍ហិរញ្ញវត្ថុណាមួយ នឹងត្រូវរួមបញ្ចូល ទៅក្នុង ទិន្នន័យទីផ្សារដែលអាចអង្កេតបាន អំពីលក្ខខណ្ឌទីផ្សារ និង កត្តាផ្សេងៗ ដែលហាក់ដូចជាមានផលប៉ះពាល់ដល់តម្លៃសម ស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ។ តម្លៃសមស្របរបស់ឧបករណ៍ ហិរញ្ញវត្ថុ នឹងត្រូវផ្អែកលើកត្តាមួយ ឬច្រើន ដូចខាងក្រោម (និងប្រហែលជាកត្តាផ្សេងទៀត)។

(ក) *តម្លៃពេលវេលានៃទឹកប្រាក់ (មានន័យថា ការប្រាក់តាមអត្រាការប្រាក់មូលដ្ឋានឬអត្រាការប្រាក់និរភ័យ)*។ អត្រាការប្រាក់មូលដ្ឋាន ជាធម្មតា អាចទទួលបានពីថ្លៃសញ្ញាប័ណ្ណរដ្ឋ ដែលអាចអង្កេតបាន និងតែងតែបានធ្វើសម្រង់ចេញពីការផ្សាយជាសាធារណៈ។ តាមធម្មតា អត្រាទាំងនេះប្រែប្រួលជាមួយនឹងកាលបរិច្ឆេទអនាគតនៃលំហូរសាច់ប្រាក់ព្យាករណ៍ ស្របតាមខ្សែកោងទិន្នផលរបស់អត្រាការប្រាក់ដែលមានរយៈពេលខុសៗគ្នា។ សម្រាប់ហេតុផលជាក់ស្តែង អង្គភាព អាចប្រើ

អត្រាការប្រាក់ទូទៅដែលអាចអង្កេតបាននិងត្រូវបានគេទទួលស្គាល់បំផុត ដូចជា LIBOR ឬ SWAP rate, ដើម្បីធ្វើជាអត្រាស្តង់ដាប្រៀបធៀបធៀប។ (ពីព្រោះ អត្រាការប្រាក់ដូចជា LIBOR មិនមែនជា អត្រាការប្រាក់និរភ័យ, ការកែសម្រួលហានិភ័យ ឥណទានដ៏សមរម្យមួយចំពោះឧបករណ៍ហិរញ្ញវត្ថុមួយត្រូវបានកំណត់ដោយឈរលើហានិភ័យឥណទាន ដែលទាក់ទងនឹង ហានិភ័យឥណទាន នៅក្នុងអត្រាការប្រាក់ជាស្តង់ដាប្រៀបធៀបនេះ)។ នៅក្នុងប្រទេសខ្លះ សញ្ញាប័ណ្ណ រដ្ឋអាចមានហានិភ័យឥណទានខ្លាំង និងមិនអាច ផ្តល់ជាសំអាងចំពោះអត្រាការប្រាក់ សម្រាប់សញ្ញាប័ណ្ណក្រុមហ៊ុនដែលមានចំណាត់ថ្នាក់ខ្ពស់ ដែលបានចេញផ្សាយជារូបិយវត្ថុរបស់ប្រទេសនោះ។

(ខ) *ហានិភ័យឥណទាន*។ ផលប៉ះពាល់ លើតម្លៃសមស្រប នៃហានិភ័យឥណទាន (មានន័យថា អត្រាលើសលើអត្រាការប្រាក់មូលដ្ឋានសម្រាប់ហានិភ័យឥណទាន) អាចទទួលបានពីថ្លៃទីផ្សារ ដែលអាចអង្កេតបាន សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលបានជួញដូរ ដែលមានគុណភាពឥណទានខុសគ្នា ឬពីអត្រាការប្រាក់អាចអង្កេតបាន ដែលបានកំណត់យកដោយអ្នកឲ្យខ្ចីសម្រាប់ប្រាក់កម្ចី ដែលមានចំណាត់ឥណទានផ្សេងៗគ្នា។

(គ) *ថ្លៃនៃអត្រាប្តូរប្រាក់បរទេស*។ ទីផ្សារអត្រាប្តូរប្រាក់ បរទេស សកម្មកើតមានចំពោះរូបិយវត្ថុចំបងៗជាច្រើន, ហើយថ្លៃត្រូវបានធ្វើសម្រង់រាល់ថ្ងៃនៅក្នុងការបោះផ្សាយជាសាធារណៈ។

(ឃ) *ថ្លៃកុំម៉ូឌីធី*។ មានថ្លៃទីផ្សារដែលអាចអង្កេតបានជាច្រើនសម្រាប់កុំម៉ូឌីធីជាច្រើន។

(ង) *ថ្លៃមូលធន*។ ថ្លៃ (និងសន្ទស្សន៍ថ្លៃ) របស់ឧបករណ៍ហិរញ្ញវត្ថុដែលបានជួញដូរអាចអង្កេតបាន ដោយងាយនៅក្នុងទីផ្សារមួយចំនួន។ តម្លៃបច្ចុប្បន្ន ដែលផ្អែកលើបច្ចេកទេសវាយតម្លៃអាចត្រូវបានប្រើដើម្បីប៉ាន់ស្មានថ្លៃទីផ្សារបច្ចុប្បន្ននៃឧបករណ៍ហិរញ្ញវត្ថុមូលធនដែលមិនមានថ្លៃអាចអង្កេតបាន។

(ច) *ភាពងាយប្រែប្រួល (ទំហំនៃការផ្លាស់ប្តូរពេលអនាគត នៃថ្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬឧបករណ៍ផ្សេងៗ)*។ ការវាស់វែងភាពងាយប្រែប្រួលនៃឧបករណ៍ដែលបានជួញដូរយ៉ាងសកម្មជាធម្មតា អាចត្រូវបានប៉ាន់ស្មានដោយសមហេតុសមទ្ធិផលដោយផ្អែកលើទិន្នន័យទីផ្សារចាស់ៗឬដោយការប្រើភាពងាយប្រែប្រួលនៅក្នុងថ្លៃទីផ្សារបច្ចុប្បន្ន។

(ឆ) *ហានិភ័យ នៃការបង់ប្រាក់មុន និងហានិភ័យ នៃការសងបំណុល*។ តម្រូវនៃការបង់ប្រាក់មុននាពេលអនាគត សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងគម្រូទូទាត់សង នាពេលអនាគត

សម្រាប់ បំណុលហិរញ្ញវត្ថុអាចត្រូវបានប៉ាន់ស្មាន ដោយផ្អែកលើទិន្នន័យចាស់ៗ។ (តម្លៃសមស្រប នៃបំណុលហិរញ្ញវត្ថុដែលអាចត្រូវបានទូទាត់សងដោយសហជីវិនមិនអាចតិចជាងតម្លៃបច្ចុប្បន្នរបស់បរិមានត្រូវសង មើលកថាខណ្ឌ ៥.៤.៣)

(ជ) *ចំណាយលើការផ្តល់សេវាកម្ម សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ*។ ចំណាយ នៃការផ្តល់សេវាកម្មអាចត្រូវបានប៉ាន់ស្មាន ដោយប្រើការប្រៀនធៀបជាមួយនឹងថ្លៃឈ្នួលបច្ចុប្បន្នដែលបានកំនត់ដោយអ្នកចូលរួមទីផ្សារ។ ប្រសិនបើចំណាយ នៃការផ្តល់សេវាកម្មរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ មានភាពដុំកំភួន ហើយអ្នកចូលរួមទីផ្សារផ្សេងទៀតនឹងប្រឈមនឹង ការចំណាយប្រហាក់ប្រហែលគ្នាអ្នកបោះផ្សាយ ត្រូវតែពិចារណានៅក្នុងការកំណត់តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ វាហាក់ដូចជាថា តម្លៃសមស្របនៅពេលដំបូងនៃសិទ្ធិតាមកិច្ចសន្យាធៀបនឹងថ្លៃឈ្នួលអនាគតស្មើនឹង ចំណាយដើមដំបូង ដែលបានបង់សម្រាប់ពួកគេ, ដរាបណា ថ្លៃឈ្នួលអនាគត និងចំណាយពាក់ពន្ធ័មិនស្របតាមចំណាយទីផ្សារដែលអាចអង្កេតបាន។

### ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់គ្មានថ្លៃសម្រង់ (និងកិច្ចសន្យានៅលើការវិនិយោគទាំងនោះត្រូវតែទូទាត់ដោយការប្រគល់ឲ្យឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់ដែលគ្មានសម្រង់ថ្លៃ)

ខ៥.៤.១៤ គ្រប់ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់ និងកិច្ចសន្យាលើការវិនិយោគទាំងនោះត្រូវតែវាស់វែង តាមតម្លៃសមស្រប។ ទោះជាយ៉ាងណានៅក្នុងកាលៈទេសៈដ៏មានកំណត់ ចំណាយ អាចជាការប៉ាន់ស្មានសមរម្យមួយ នៃតម្លៃសមស្រប។ នោះអាចជាករណី ប្រសិនបើ ព័ត៌មានថ្មីៗបំផុត មិនគ្រប់គ្រាន់អាចរកបានដើម្បីកំណត់តម្លៃសមស្រប, ឬប្រសិនបើមានកម្រិតយ៉ាទូលាយ នៃការវាស់វែងតម្លៃសមស្រប ដែលអាចកើតមាន ហើយចំណាយតំណាង នូវការប៉ាន់ស្មានល្អបំផុត នៃតម្លៃសមស្របស្ថិតនៅក្នុងកម្រិតនោះ

ខ៥.៤.១៥ សូចនករ ដែលការចំណាយ អាចមិនតំណាងឲ្យតម្លៃសមស្របរួមមានៈ

(ក) ការផ្លាស់ប្តូរជាដុំកំភួន នៅក្នុងលទ្ធផលសម្រេចបានរបស់ក្រុមហ៊ុនរងការវិនិយោគដោយប្រៀបធៀបនឹងថវិកា ផែនការ ឬសរសរស្តម្ភ។

(ខ) ការផ្លាស់ប្តូរនៅក្នុង ការរំពឹងទុករបស់សរសរស្តម្ភផលិតផលបច្ចេកទេសរបស់ក្រុមហ៊ុនរងការវិនិយោគនឹងត្រូវបានសម្រេច។

(គ) ការផ្លាស់ប្តូរជាដុំកំភ្ជួន នៅក្នុងទីផ្សារ សម្រាប់មូលធនផ្ទាល់របស់ក្រុមហ៊ុនរងការវិនិយោគឬផលិតផលរបស់វាឬផលិតផលសក្តានុពល។

(ឃ) ការផ្លាស់ប្តូរជាដុំកំភ្ជួននៅក្នុងសេដ្ឋកិច្ច ឬបរិយាកាសសេដ្ឋ-កិច្ចពិភពលោករបស់ក្រុមហ៊ុនរងការវិនិយោគ។

(ង) ការផ្លាស់ប្តូរនៅក្នុងលទ្ធផលសម្រេចបានរបស់អង្គភាព អាចប្រៀបធៀបបាន, ឬនៅក្នុងការវាយតម្លៃដែលបានអនុវត្តនៅក្នុងទីផ្សារទាំងមូល។

(ច) បញ្ហាផ្ទៃក្នុងរបស់ក្រុមហ៊ុនរងការវិនិយោគ ដូចជា ការគៃបន្លំ, ជំលោះពាណិជ្ជកម្ម, បណ្តឹងវិវាទ, ការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រង ឬការផ្លាស់ប្តូរយុទ្ធសាស្រ្ត។

(ឆ) ភស្តុតាងពីប្រតិបត្តិការខាងក្រៅ ក្នុងមូលធនផ្ទាល់របស់ក្រុមហ៊ុនរងការវិនិយោគ ដោយក្រុមហ៊ុនរងការវិនិយោគ (ដូចជាការបោះផ្សាយថ្មីៗនូវមូលធនផ្ទាល់), ឬដោយការផ្ទេរឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់រវាងភាគីទីបី។

ខ៥.៤.១៦ បញ្ជីនៅក្នុងកថាខណ្ឌខ ៥.៤.១៥ មិនល្អិតល្អន់ទេ។ អង្គភាពមួយ ត្រូវប្រើរាល់ព័ត៌មានអំពីលទ្ធផលសម្រេចបាន និងកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនរងការវិនិយោគ ដែលអាចរកបានបន្ទាប់ពីការទទួលស្គាល់លើកដំបូង។ ទៅតាមទំហំនៃកត្តាពាក់

ពន្ធ ដែលកើតមាន ពួកគេអាចបង្ហាញថាចំណាយ នោះមិនតំណាងឱ្យ តម្លៃសមស្របឡើយ។ នៅក្នុងករណី បែបនេះ អង្គភាពត្រូវធ្វើការប៉ាន់ស្មានតម្លៃសមស្រប។

១៥.៤.១៧ ចំណាយ មិនមែនជាការប៉ាន់ស្មានតម្លៃសមស្រប សម្រាប់ការវិនិយោគ នៅក្នុងឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់ ដែលមានសម្រង់ថ្លៃ (ឬកិច្ចសន្យានៅក្នុងឧបករណ៍មូលធនផ្ទាល់ ដែលមានសម្រង់ថ្លៃ) ឡើយ។

**ចំណេញឬខាតមូលធន(ផ្នែក៥.៧)**

១៥.៧.១ កថាខណ្ឌ ៥.៧.៥ អនុញ្ញាតិឱ្យអង្គភាពធ្វើការជ្រើសរើស ដែលពុំអាចផ្លាស់ប្តូរបានដើម្បីបង្ហាញ នៅក្នុងការផ្លាស់ប្តូរ នៃចំណូលបន្ទាប់បន្សំនៅក្នុងតម្លៃសមស្របរបស់ការវិនិយោគមួយនៅក្នុងឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់ ដែលមិនកាន់កាប់ សម្រាប់ការលក់។ ការជ្រើសរើសនេះ ត្រូវបានធ្វើឡើង ទៅតាមឧបករណ៍ហិរញ្ញវត្ថុ ដោយឧបករណ៍ហិរញ្ញវត្ថុ (មានន័យថាសន្លឹក ហ៊ុនតាមប្រភេទសន្លឹកហ៊ុន)។ បរិមាណដែលបង្ហាញនៅក្នុង ផ្នែកចំណូលបន្ទាប់បន្សំនឹង មិនត្រូវបានផ្ទេរទៅផ្នែកចំណេញ ឬខាត នៅពេលក្រោយមកទៀតឡើយ។ ទោះជាយ៉ាងណា អង្គភាពអាចផ្ទេរចំណេញ ឬខាតមូលធនដោយការបង្គរនៅក្នុងអង្គភាពបាន។ ភាគលាភលើការវិនិយោគបែបនេះត្រូវ

បានទទួលស្គាល់នៅក្នុងផ្នែកចំណេញ ឬខាត ដោយអនុលោមតាម ស្តង់ដាគណនេយ្យអន្តរជាតិ ១៨ ដរាបណាភាគលាភបង្ហាញយ៉ាច្បាស់នូវការទទួលបានមកវិញផ្នែក នៃការចំណាយវិនិយោគ។

១៥.៧.២ អង្គភាពអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ ២១ *ផលប៉ះពាល់នៃការផ្លាស់ប្តូរនៅក្នុងអត្រាប្តូរប្រាក់បរទេស* ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដែលជាធាតុមានតម្លៃជាទឹកប្រាក់ ដោយអនុលោមតាម ស្តង់ដាគណនេយ្យអន្តរជាតិ ២១ និងបានកំណត់ជារូបិយវត្ថុបរទេស។ ស្តង់ដាគណនេយ្យអន្តរជាតិ ២១ តម្រូវឲ្យចំណេ ញឬខាត ពីអត្រាប្តូរប្រាក់បរទេស នៅលើទ្រព្យសកម្មដែលមានតម្លៃជាទឹកប្រាក់ និងបំណុល ដែលមានតម្លៃជាទឹកប្រាក់ត្រូវតែទទួលស្គាល់ នៅក្នុងផ្នែកចំណេញ ឬខាត។ ការលើកលែងមួយ គឺធាតុដែលមានតម្លៃជា ទឹកប្រាក់ដែលត្រូវបានកំណត់ថាជាឧបករណ៍ទប់ស្កាត់ ហានិភ័យនៅក្នុងការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់ (មើល កថាខណ្ឌ៩៥-១០១ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩) ឬការទប់ស្កាត់ហានិភ័យ នៃការវិនិយោគសុទ្ធ (មើលកថាខណ្ឌ ១០២ នៃស្តង់ដាគណនេយ្យអន្តរជាតិ៣៩)។

១៥.៧.៣ កថាខណ្ឌ៥.៧.៥

អនុញ្ញាតិឲ្យអង្គភាពធ្វើការជ្រើសរើសដែលពុំអាចផ្លាស់ប្តូរបាន

ដើម្បីបង្ហាញនូវការផ្លាស់ប្តូរនៅក្នុងចំណូលបន្ទាប់បន្សំ នៃតម្លៃសមស្រប របស់ការវិនិយោគមួយ នៅក្នុងឧបករណ៍ហិរញ្ញវត្ថុមូលធនផ្ទាល់ដែលមិនកាន់កាប់សម្រាប់ការលក់។ ការវិនិយោគបែបនេះ មិនមែនជាធាតុ ដែលមានតម្លៃជាទឹកប្រាក់នោះទេ។ ដោយយោងតាមនោះចំណេញ ឬខាត ដែលបានបង្ហាញ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំ ដោយអនុលោមតាម កថាខណ្ឌ ៥.៧.៥ រួមមាននូវសមាសធាតុ នៃការប្តូរប្រាក់បរទេស ដែលទាក់ទង។

ខ៥.៧.៤ ប្រសិនបើ មានទំនាក់ទំនងទប់ស្កាត់ ហានិភ័យរវាងទ្រព្យសកម្មដែលគ្មាននិស្សន្ទ និងបំណុលដែលគ្មាននិស្សន្ទ ការផ្លាស់ប្តូរនៅក្នុងសមាសធាតុ នៃរូបិយវត្ថុបរទេស នៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះត្រូវបានបង្ហាញនៅក្នុងផ្នែកចំណេញ ឬខាត។

## បំណុលដែលបានកំណត់តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ

ខ៥.៧.៥ នៅពេលអង្គភាពមួយកំណត់បំណុលហិរញ្ញវត្ថុមួយ តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ អង្គភាពត្រូវតែកំណត់ថាតើដាក់បង្ហាញវានៅក្នុងផ្នែកចំណូលបន្ទាប់បន្សំនូវផលប៉ះពាល់នៃការផ្លាស់ប្តូរ នៅក្នុងហានិភ័យឥណទានរបស់បំណុលនោះ នឹងបង្កើតឡើងឬធ្វើឲ្យរីកធំនូវភាពមិនស៊ីចង្វាក់គ្នាខាងគណនេយ្យ

នៅក្នុងផ្នែកចំណេញ ឬខាត ឬយ៉ាងណា។ ភាពមិនស៊ីគ្នាខាងគណនេយ្យនឹងត្រូវបានបង្កើតឡើង ឬបានធ្វើឱ្យរីកធំ ប្រសិនបើដាក់បង្ហាញ នូវផលប៉ះពាល់នៃការផ្លាស់ប្តូរនៅក្នុង ហានិភ័យឥណទាននៅក្នុងផ្នែកចំណេញឬខាតបន្ទាប់បន្សំនឹងធ្វើឱ្យមានភាពមិនស៊ីគ្នាកាន់តែធំឡើង នៅក្នុងផ្នែកចំណេញ ឬខាត ប្រសិនបើ បរិមាណទាំងនោះត្រូវបានបង្ហាញ នៅក្នុងផ្នែកចំណេញឬខាត។

ខ៥.៧.៦ ដើម្បីធ្វោះការកំណត់នោះ អង្គភាពមួយត្រូវវាយតម្លៃ ថាតើខ្លួនរំពឹងថាផលប៉ះពាល់នៃការផ្លាស់ប្តូរ នៅក្នុងហានិភ័យឥណទានរបស់បំណុលនឹងកាត់កងនៅក្នុងផ្នែកចំណេញ ឬខាត ដោយការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលបានវាស់វែង តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ។ ការរំពឹងបែបនេះត្រូវតែផ្អែកលើទំនាក់ទំនងសេដ្ឋកិច្ចរវាងចរិតលក្ខណៈរបស់បំណុល និងចរិតលក្ខណៈរបស់ឧបករណ៍ ហិរញ្ញវត្ថុផ្សេងទៀត។

ខ៥.៧.៧ ការកំណត់នោះ ត្រូវតែបានធ្វើនៅគពេល នៃការទទួលស្គាល់ដំបូង និងមិនចាំបាច់ត្រូវវាយតម្លៃឡើងវិញឡើយ។ សម្រាប់គោលបំណងជាក់ស្តែង អង្គភាពមិនចាំបាច់បញ្ចូលទ្រព្យសកម្មទាំងងអស់ឡើយ ហើយបំណុលនឹងធ្វើឱ្យកើនឡើងនូវភាពមិន

ស៊ីគ្នាខាងគណនេយ្យនៅពេលវេលាដូចគ្នា ដោយពិតប្រាកដ។ ការពន្យាសមហេតុផលមួយត្រូវបានអនុញ្ញាតិ ដោយហេតុថា ប្រតិបត្តិការ នៅសេសសល់ ត្រូវបានរំពឹងថានឹងកើតឡើង។ អង្គភាពត្រូវអនុវត្តដោយសង្គតិភាពវិធីសាស្ត្ររបស់ខ្លួន នៅក្នុងការកំណត់ថាតើ ការដាក់បង្ហាញ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំនូវផលប៉ះពាល់ នៃការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់បំណុលនឹងបង្កើត ឬធ្វើឲ្យរីកធំភាពមិនស៊ីគ្នាខាងគណនេយ្យនៅក្នុងផ្នែកចំណេញ ឬខាត ឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី អង្គភាពអាចប្រើវិធីសាស្ត្រផ្សេងៗគ្នា នៅពេលមានទំនាក់ទំនងសេដ្ឋកិច្ចផ្សេងៗគ្នារវាងចរិតលក្ខណៈរបស់បំណុលដែលបានកំណត់តាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ និងចរិតលក្ខណៈរបស់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ តម្រូវឲ្យអង្គភាពមួយផ្តល់ នូវការលាតត្រដាងបែបគុណវិស័យ នៅក្នុងកំណត់សម្គាល់ របស់របាយការណ៍ហិរញ្ញវត្ថុ អំពីវិធីសាស្ត្ររបស់ខ្លួនសម្រាប់ធ្វើការកំណត់នោះ។

ខ៥.៧.៨ ប្រសិនបើភាពមិនស៊ីគ្នាទបែបនោះត្រូវបានបង្កើតឬធ្វើឲ្យរីកធំ អង្គភាព ត្រូវបានតម្រូវឲ្យបង្ហាញរាល់ការផ្លាស់ប្តូរទាំងអស់នៅក្នុងតម្លៃសមស្រប (រួមទាំង ផលប៉ះពាល់នៃការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់បំណុលផងដែរ) នៅក្នុងផ្នែកចំណេញ

ឬខាត។ ប្រសិនបើ ភាពមិនស៊ីគ្នាទបែបនោះមិនត្រូវបានបង្កើត ឬធ្វើឱ្យរីកធំ អង្គភាពត្រូវបានតម្រូវឱ្យបង្ហាញរាល់ការផ្លាស់ប្ដូរទាំងអស់នៅក្នុងហានិភ័យឥណទាន នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំ។

១៥.៧.៩ បរិមាណបានបង្ហាញ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំ មិនត្រូវបានផ្ទេរទៅក្នុងផ្នែកចំណេញ ឬខាត នៅពេលក្រោយឡើយ។ ទោះជាយ៉ាងណា អង្គភាព អាចផ្ទេរចំណេញ ឬខាតមូលធនដែលបានបង្គរនៅក្នុងក្របខណ្ឌអង្គភាព។

១៥.៧.១០ ឧទាហរណ៍ខាងក្រោមបរិយាយស្ថានភាពមួយ ដែលនៅក្នុងនោះភាពមិនស៊ីគ្នាខាងគណនេយ្យ នឹងត្រូវបាននបង្កើតឡើងនៅក្នុងផ្នែកចំណេញ ឬខាត ប្រសិនបើផលប៉ះពាល់នៃការផ្លាស់ប្ដូរនៅក្នុងហានិភ័យឥណទានរបស់បំណុលត្រូវបានបង្ហាញនៅក្នុងផ្នែកចំណូលបន្ទាប់បន្សំ។ ធនាគារដាក់បញ្ចាំមួយផ្ដល់ប្រាក់កម្ចីទៅអតិថិជន និងផ្ដល់មូលនិធិប្រាក់កម្ចីទាំងនោះ ដោយការលក់សញ្ញាប័ណ្ណជាមួយនឹងចរិតលក្ខណៈដែលស៊ីគ្នា( ឧ. បរិមាណជំពាក់, ប្រវត្តិនៃការសងបំណុល, លក្ខខណ្ឌ និងរូបិយវត្ថុ) នៅក្នុងទីផ្សារ។ លក្ខខណ្ឌតាមកិច្ចសន្យារបស់ប្រាក់កម្ចីអនុញ្ញាតិឱ្យអតិថិជន សងប្រាក់កម្ចីរបស់ខ្លួនវិញ (មានន័យថា បំពេញកាតព្វកិច្ចបំណុល ចំពោះធនាគារ) ដោយការទិញសញ្ញាប័ណ្ណ

ដែលត្រូវគ្នាតាមតម្លៃសមស្របនៅក្នុងទីផ្សារ និងការប្រគល់ឱ្យសញ្ញាប័ណ្ណនោះទៅធនាគារដាក់បញ្ចាំ។ជាលទ្ធផល នៃសិទ្ធិនៃការទូទាត់សងតាមកិច្ចសន្យា, ប្រសិនបើ គុណភាពឥណទានរបស់សញ្ញាប័ណ្ណកាន់តែអាក្រក់ (និងហេតុដូច្នេះ តម្លៃសមស្របរបស់បំណុលរបស់ធនាគារ ដាក់បញ្ចាំនឹងថយចុះ) តម្លៃសមស្របរបស់ទ្រព្យសកម្ម ជាប្រាក់កម្ចីរបស់ធនាគារនោះនឹងថយចុះផងដែរ។ កាផ្លាស់ប្ដូរតម្លៃសមស្រប របស់ទ្រព្យសកម្មឆ្លុះបញ្ចាំងពីសិទ្ធិ តាមកិច្ចសន្យារបស់អតិថិជន ដើម្បីសងវិញ នូវប្រាក់កម្ចីដែលមានរបស់បញ្ចាំដោយការទិញយកនូវសញ្ញាប័ណ្ណដែលមានតាមតម្លៃសមស្រប (នៅក្នុងឧទាហរណ៍នេះ, ដែលមានតម្លៃថយចុះ) និងការប្រគល់សញ្ញាប័ណ្ណ ទៅធនាគារ។ ដូច្នេះ ផលប៉ះពាល់នៃការផ្លាស់ប្ដូរនៅក្នុងហានិភ័យឥណទានរបស់បំណុល (សញ្ញាប័ណ្ណ) នឹងកាត់កងនៅក្នុងផ្នែកចំណេញ ឬខាតដោយស៊ីគ្នានឹងការផ្លាស់
ប្ដូរនៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ(ប្រាក់កម្ចី)។ ប្រសិនបើផលប៉ះពាល់នៃការផ្លាស់ប្ដូរនៅក្នុងហានិភ័យឥណទានរបស់បំណុលត្រូវបានបង្ហាញ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំដែលមានភាពមិនស៊ីគ្នាខាងគណនេយ្យ នៅក្នុងផ្នែកចំណេញ ឬខាត។ ដូច្នេះ ធនាគារដាក់ទ្រព្យបញ្ចាំត្រូវបានតម្រូវឱ្យបង្ហាញរាល់ការផ្លាស់ប្ដូរនៅក្នុងតម្លៃសមស្របរបស់បំណុល (រួមមាន

ទាំងផលប៉ះពាល់ នៃការផ្លាស់ប្តូរ នៅក្នុងហានិភ័យឥណទានរបស់បំណុល) នៅក្នុងផ្នែកចំណេញឬខាត។

ខ៥.៧.១១ នៅក្នុងឧទាហរណ៍នៅក្នុងកថាខណ្ឌ ខ៥.៧.១០, មានការតភ្ជាប់ តាមកិច្ចសន្យារវាងផលប៉ះពាល់នៃការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់បំណុល និងការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ (មានន័យថា ជាលទ្ធផលនៃសិទ្ធិតាមកិច្ចសន្យារបស់អតិថិជន ដើម្បីសងវិញនូវប្រាក់កម្ចីដោយការទិញយក នូវសញ្ញាប័ណ្ណតាមតម្លៃសមស្រប និងការប្រគល់សញ្ញាប័ណ្ណនោះទៅធនាគារដាក់ទ្រព្យបញ្ចាំ)។ ទោះជាយ៉ាងណា ភាពមិនស៊ីគ្នាខាងគណនេយ្យអាចកើតឡើងផងដែរ នៅពេលមិនមានវត្តមាននៃការតភ្ជាប់តាមកិច្ចសន្យា។

ខ៥.៧.១២ សម្រាប់គោលបំណងនៃការអនុវត្តន៍ការតម្រូវ នៅក្នុងកថាខណ្ឌ ៥.៧.៧និង៥.៧.៨, ភាពមិនស៊ីគ្នាខាងគណនេយ្យមិនបណ្តាលមកពីវិធីសាស្ត្រនៃការគ្រប់គ្រងតែមួយនោះទេដែលអង្គភាពប្រើ ដើម្បីកំណត់ផលប៉ះពាល់ នៃការផ្លាស់ប្តូរ នៅក្នុងហានិភ័យឥណទានរបស់បំណុល។ ភាពមិនស៊ីគ្នាខាងគណនេយ្យ នៅក្នុងផ្នែកចំណេញ ឬខាត នឹងកើនឡើងតែនៅពេលដែល ផលប៉ះពាល់នៃការផ្លាស់ប្តូរ នៅក្នុងហានិភ័យឥណទានរបស់បំណុល (ដូចបានកំណត់អត្ថន័យ នៅក្នុងស្តង់ដាររបាយការណ៍ទាក់ទង

នឹងហិរញ្ញវត្ថុអន្តរជាតិ ៧) ត្រូវបានគេរំពឹងនឹងកាត់កង ដោយការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។ ផាពមិនស៊ីគ្នាកើតឡើងតែនៅពេលដែល វិធីសាស្ត្រនៃការគ្រប់គ្រង (មានន័យថា ដោយសារតែ អង្គភាពមិនដាក់ដាច់តែឯក នូវការផ្លាស់ប្តូរនៅក្នុង ហានិភ័យឥណទានរបស់បំណុលពីការផ្លាស់ប្តូរផ្សេងទៀតនៃរតម្លៃសមស្រប) មិនមានផលប៉ះពាល់ដល់ការកំណត់ ដែលបានតម្រូវដោយកថាខណ្ឌ ៥.៧.៧និង៥.៧.៨។ ឧទាហរណ៍ អង្គភាព អាចមិនដាក់ដាច់តែឯងនូការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់បំណុលពីការផ្លាស់ប្តូរនៅក្នុងហានិភ័យសន្ទនីយភាព។ ប្រសិនបើអង្គភាពបង្ហាញនូវផលប៉ះពាល់រួម នៃកត្តាទាំងពីរ នៅក្នុងផ្នែកចំណូកបន្ទាប់បន្សំភាពមិនស៊ីគ្នាអាចកើតឡើង ដោយសារតែការផ្លាស់ប្តូរនៅក្នុងហានិភ័យសន្ទនីយភាពអាចត្រូវបានរាប់បញ្ចូល នៅក្នុងការវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ របស់អង្គភាព និងការផ្លាស់ប្តូរតម្លៃសមស្របទាំងមូល របស់ទ្រព្យសកម្មទាំងនោះ ត្រូវបានបង្ហាញនៅក្នុងផ្នែកចំណេញ ឬខាត។ ទោះជាយ៉ាងណា ភាពពមិនស៊ីគ្នាបែបនេះបណ្តាលមកពី ភាពមិនច្បាស់លាស់នៃការវាស់វែង, មិនកាត់កងជាមួយនឹងទំនាក់ទំនងបានបរិយាយនៅក្នុងកថាខណ្ឌ ខ៥.៧.៦ និងហេតុដូច្នេះ

មិនប៉ះពាល់ដល់ការកំណត់ ដែលបានតម្រូវដោយកថាខណ្ឌ ៥.៧.៧និង៥.៧.៨ ឡើយ។

*អត្ថន័យនៃ “ហានិភ័យឥណទាន”*

ខ៥.៧.១៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ កំណត់អត្ថន័យហានិផ័យឥណទានថាជា “ហានិភ័យដែលភាគីមួយនៃឧបករណ៍ហិរញ្ញវត្ថុនឹងបណ្តាលឲ្យមានការខាតបង់សម្រាប់ភាគីមួយផ្សេងទៀតដោយការមិនបំពេញកាតព្វកិច្ច”។ការតម្រូវនៅក្នុងកថាខណ្ឌ ៥.៧.៧(ក) ទាក់ទងនឹងហានិភ័យ ដែលអ្នកបោះផ្សាយនឹងមិនបំពេញកាតព្វកិច្ចបំណុល។វាមិនចាំបាច់ត្រូវទាកទងនឹង ភាពមានកេរ្តិ៍ឈ្មោះ ខាងឥណទានរបស់អ្នកបោះផ្សាយឡើយ។ ឧទាហរណ៍ ប្រសិនបើអង្គភាព មួយចេញផ្សាយបំណុលដែលមានទ្រព្យបញ្ចាំនិងបំណុលដែលគ្មានទ្រព្យបញ្ចាំដែលមានលក្ខណៈដូចគ្នា, ហានិភ័យឥណទាននៃបំណុលទាំងពីរនោះនឹងខុសគ្នា បើទោះបីជា ពួកវាត្រូវបានចេញផ្សាយដោយអង្គភាពតែមួយក៏ដោយ។ ហានិភ័យឥណទានលើបំណុលដែលមានទ្រព្យបញ្ចាំនឹងតិចជាងហានិភ័យឥណទាន លើបំណុលដែលគ្មានទ្រព្យបញ្ចាំ។ ហានិភ័យឥណទានលើបំណុល ដែលមានទ្រព្យបញ្ចាំអាចស្មើសូន្យ។

១៥.៧.៧១៤ សម្រាប់គោលបំណង នៃការអនុវត្តន៍ការតម្រូវ នៅក្នុងកថាខណ្ឌ៥.៧.៧(ក), ហានិភ័យឥណទានខុសគ្នាពីហានិភ័យនៃការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយ។ ហានិភ័យនៃការប្រើប្រាស់ទ្រព្យសកម្ម មិនទាក់ទងនឹងហានិភ័យ ដែលអង្គភាព នឹងមិនបំពេញបានកាតព្វកិច្ចបំណុលណាមួយប៉ុន្តែផ្ទុយទៅវិញវាទាក់ទងនឹងហានិភ័យ ដែលទ្រព្យសកម្មទោលមួយឬក្រុមនៃទ្រព្យសកម្មនឹងប្រើប្រាស់មិនបានល្អ(ឬមិនល្អទាំងស្រុង)។

១៥.៧.១៥ ខាងក្រោមជាឧទាហរណ៍ នៃហានិភ័យ នៃការប្រើប្រាស់ទ្រព្យសកម្ម៖

(ក) បំណុលមានលក្ខណៈ នៃការតភ្ជាប់ទៅនឹងអង្គមួយ ដែលបរិមាណ ត្រូវដល់កំណត់សងទៅអ្នកវិនិយោគ ត្រូវបានកំណត់ តាមកិច្ចសន្យា ដោយឈរលើការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ណាមួយ។ ផលប៉ះពាល់នៃលក្ខណៈនៃការតភ្ជាប់ទៅនឹងអង្គមួយលើតម្លៃសមស្របរបស់បំណុល គឺជាហានិភ័យនៃការប្រើប្រាស់ទ្រព្យសកម្មណាមួយ, មិនមែនជាហានិភ័យឥណទានឡើយ។

(ខ) បំណុល ដែលចេញផ្សាយដោយអង្គភាពមានគោលបំណងពិសេសដែលមានចរិតលក្ខណៈខាងក្រោម។ អង្គភាពមាន

គោលបំណងពិសេសត្រូវបានដាក់ដាច់ដោយឡែក តាមផ្លូវច្បាប់ ដូច្នេះ ទ្រព្យសកម្មនៅក្នុងអង្គភាពមានគោលបំណងពិសេសត្រូវបានការពារ សម្រាប់ជាប្រយោជន៍ របស់អ្នកវិនិយោគរបស់ខ្លួន ទោះបិនៅក្នុងហេតុការនៃការក្ស័យធន។ អង្គភាព មានគោលបំណងពិសេស មិនមានទាក់ទងនឹងប្រតិបត្តិការផ្សេងទៀត ហើយទ្រព្យសកម្មនៅក្នុង អង្គភាពមានគោលបំណងពិសេសមិនអាចត្រូវបានដាក់បញ្ចាំឡើយ។ បរិមាណត្រូវសង ចំពោះអ្នកវិនិយោគរបស់អង្គភាព មានគោលបំណងពិសេស តែក្នុងករណីដែលទ្រព្យសកម្ម បានដាក់ការបារនឲបង្កើតលំហូរសាច់ប្រាក់។ ដូច្នេះ ការផ្លាស់ប្តូរតម្លៃសមស្របរបស់បំណុល ជាចំបងឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្ម។ ផលប៉ះពាល់នៃការប្រើប្រាស់ទ្រព្យសកម្មលើតម្លៃសមស្របរបស់បំណុល គឺជាហានិភ័យទាក់ទងនឹង ការប្រើប្រាស់ទ្រព្យសកម្ម, មិនមែនជាហានិភ័យឥណទានឡើយ។

*ការកំណត់ផលប៉ហពាល់នៃការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទាន*

ខ៥.៧.១៦ សម្រាប់គោលបំណងនៃការអនុវត្តន៍ការតម្រូវនៅក្នុង កថាខណ្ឌ ៥.៧.៧(ក) អង្គភាពត្រូវកំណត់បរិមាណនៃការផ្លាស់ប្តូរនៅក្នុង

តម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលពាក់ពន្ធ័នឹងការផ្លាស់ប្ដូរនៅក្នុងហានិភ័យឥណទានរបស់បំណុលថាជា:

(ក) បរិមាណនៃការផ្លាស់ប្ដូរនៅក្នុងតម្លៃសមស្របដែលមិនទាក់ទងនឹងការផ្លាស់ប្ដូរ លក្ខខណ្ឌទីផ្សារ ដែលធ្វើឱ្យកើនឡើងហានិភ័យទីផ្សារ (មើលក្នុង កថាខណ្ឌ ខ៥.៧.១៧ និង ខ៥.៧.១៨) ឬ

(ខ) ការប្រើវិធីសាស្ត្រផ្សេងដែលអង្គភាពជឿថាតំណាង យ៉ាងត្រឹមត្រូវ ជាងនូវបរិមាណនៃការផ្លាស់ប្ដូរ នៅក្នុងតម្លៃសមស្របរបស់បំណុល ដែលទាក់ទងនឹងការផ្លាស់ប្ដូរ នៅក្នុងហានិភ័យឥណទានរបស់ខ្លួន។

ខ៥.៧.១៧ ការផ្លាស់ប្ដូរលក្ខខណ្ឌទីផ្សារ ដែលនឹងធ្វើឱ្យកើនឡើងហានិភ័យទីផ្សាររួមមានការផ្លាស់ប្ដូរអត្រាការប្រាក់ជាស្ដង់ដាប្រៀបធៀប, ថ្លៃឧបករណ៍ហិរញ្ញវត្ថុ របស់អង្គភាពផ្សេងទៀត, ថ្លៃកុំម៉ូឌីធី, អត្រាប្ដូរប្រាក់បរទេស ឬសន្ទស្សន៍ថ្លៃឬអត្រា។

ខ៥.៧.១៨ ប្រសិនបើការផ្លាស់ប្ដូរពាក់ពន្ធ័ជាដុំកំភួននៅក្នុងលក្ខខណ្ឌទីផ្សារសម្រាប់បំណុលគឺជាការផ្លាស់ប្ដូរនៅក្នុងអត្រាការប្រាក់(ជាស្ដង់ដាប្រៀបធៀប) បានអង្កេតបរិមាណនៅក្នុងកថាខណ្ឌ ខ៥.៧.១៦(ក)

អាចត្រូវបានប៉ាន់ស្មានដូចខាងក្រោមៈ

(ក) ទីមួយ,អង្គភាពគណនាអត្រាចំណេញផ្ទៃក្នុងរបស់បំណុល នៅដើមការិយបរិច្ឆេទដោយប្រើតម្លៃសមស្របរបស់បំណុល និងលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់បំណុល នៅដើមការិយ-បរិច្ឆេទ។ វាដកចេញពីអត្រាចំណេញនៃអត្រាការប្រាក់ (ជាស្តង់ដាប្រៀបធៀប) បានអង្កេតនៅដើមការិយបរិច្ឆេទដើម្បីទទួលបានសមាសធាតុទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុ របស់អត្រាចំណេញផ្ទៃក្នុង។

(ខ) បន្ទាប់មក, អង្គភាព គណនាតម្លៃបច្ចុប្បន្នរបស់លំហូរសាច់ប្រាក់ទាក់ទងនឹងបំណុល ដោយប្រើលំហូរសាច់ប្រាក់ តាមកិច្ចសន្យារបស់បំណុលនោះនៅចុងការិយបរិច្ឆេទ ហើយអត្រាអប្បហារស្មើនឹងផលបូកនៃ (១) អត្រាការប្រាក់(ជាស្តង់ដាប្រៀបធៀប) បានអង្កេតនៅចុងការិយបរិច្ឆេទ និង (២) សមាសធាតុទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុរបស់អត្រាចំណេញផ្ទៃក្នុងដូចបានកំណត់នៅក្នុង(ក)។

(គ) ភាពខុសគ្នារវាងតម្លៃសមស្របរបស់បំណុល នៅចុងការិយ-បរិច្ឆេទនិងបរិមាណបានកំណត់នៅក្នុ (ខ) គឺជាការផ្លាស់ប្តូរនៃតម្លៃសមស្រប ដែលមិនទាក់ទងនឹងការផ្លាស់ប្តូរ នៃអត្រា

ការប្រាក់ (ជាស្តង់ដាប្រៀបធៀប) បានអង្កេត។ នេះគឺជាបរិមាណដែលត្រូវដាក់បង្ហាញនៅក្នុងផ្នែកចំណូលបន្ទាប់បន្សំដោយអនុលោមតាមកថាខណ្ឌ ៥.៧.៧(ក)។

ខ៥.៧.១៩ ឧទាហរណ៍នៅក្នុងកថាខណ្ឌ ខ៥.៧.១៨ សន្មតថាការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របដែលកើតចេញពីកត្តា ដែលមិនមែនជាការផ្លាស់ប្តូរនៅក្នុងហានិភ័យឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬការផ្លាស់ប្តូរនៃអត្រាការប្រាក់ (ជាស្តង់ដាប្រៀបធៀប) បានអង្កេតមិនមានសារៈសំខាន់។ វិធីសាស្ត្រនេះ នឹងមិនសមស្របប្រសិនបើការផ្លាស់ប្តូរតម្លៃសមស្របកើតចេញពីកត្តាផ្សេងទៀតដែលមានសារៈសំខាន់។ នៅក្នុងការណីទាំងនោះ អង្គភាពត្រូវបានតម្រូវឲ្យប្រើវិធីសាស្ត្រផ្សេងដែលវាស់វែង កាន់តែប្រសើរឡើងនូវផលប៉ះពាល់នៃការផ្លាស់ប្តូរហានិភ័យឥណទានរបស់បំណុល (មើល កថាខណ្ឌខ៥.៧.១៦(ក))។ ឧទាហរណ៍ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងឧទាហរណ៍រួមមាននិស្សន្ទបង្កប់, កាផ្លាស់ប្តូរតម្លៃសមស្របរបស់និស្សន្ទបង្កប់ ត្រូវបានដកចេញនៅក្នុងការកំណត់បរិមាណ ដែលត្រូវដាក់បង្ហាញ នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំដោយអនុលោមតាមកថាខណ្ឌខ៥.៧.៧(ក)។

ខ៥.៧.២០ ដូចជាមួយនឹងការប៉ាន់ស្មានទាំងអស់នៃតម្លៃសមស្របវិធីសាស្ត្រនៃការវាស់វែងរបស់អង្គភាព សម្រាប់កំណត់ផ្នែកមួយ នៃការផ្លាស់ប្តូរតម្លៃសមស្របរបស់បំណុល ដែលទាក់ទងនឹងការផ្លាស់

ប្តូរហានិភ័យឥណទានត្រូវតែប្រើឱ្យអស់លទ្ធភាព នូវធាតុចូលរបស់ទីផ្សារ។

## កាលបរិច្ឆេទចូលជាធរមាន(ជំពូក៧)

### អន្តរកាល(ផ្នែក៧.២)

### ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់សម្រាប់ការជួញដូរ

ខ៧.២.១ នៅកាលបរិច្ឆេទនៃការអនុវត្តន៍លើកដំបូង នៃស្តង់ដារបាយ-ការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះ អង្គភាព ត្រូវតែកំណត់ថាតើគោលបំណង នៃម៉ូឌែលអាជីវកម្ម របស់អង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មណាមួយរបស់ខ្លួនឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុងកថាខណ្ឌ៤.១.២(ខ) ឬប្រសិនបើទ្រព្យសកម្មមួយមាន លក្ខណៈសម្បត្តិ សម្រាប់ការជ្រើសរើស នៅក្នុងកថាខណ្ឌ ៥.៧.៥។ សម្រាប់គោលបំណងនោះ អង្គភាព ត្រូវកំណត់ថាតើទ្រព្យសកម្មហិរញ្ញវត្ថុឆ្លើយតបនឹងនិយមន័យ នៃការកាន់កាប់សម្រាប់ការជួញដូរឬទេ ប្រសិនបើ អង្គភាពបានទិញយកទ្រព្យសកម្មនោះនៅកាលបរិច្ឆេទនៃការអនុវត្តន៍។

## និស្សន្ទ

BA1 ឧទាហរណ៍អំពីនិស្សន្ទគឺ**futures and forward, swap and option contracts**។ ជាធម្មតា និស្សន្ទមានបរិមាណនិមត្តដែលជាបរិមាណនៃរូបិយវត្ថុ, ចំនួនសន្លឹកហ៊ុន, ចំនួនឯកតាទម្ងន់ ឬឯកតាផ្សេងៗកំណត់ នៅក្នុងកិច្ចសន្យា។ ទោះជាយ៉ាងណា, ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ មិនទាមទារអ្នកកាន់កាប់ ឬអ្នកបោះផ្សាយ ត្រូវវិនិយោគឬត្រូវទទួលបានបរិមាណនិមិត្តនៅការចាប់ផ្តើមកិច្ចសន្យា។ ម៉្យាងវិញទៀត និស្សន្ទអាចទាមទារការទូទាត់ថេរមួយ ឬការទូទាត់បរិមាណ មួយដែលអាចផ្លាស់ប្តូរ (ប៉ុន្តែមិនសមាមាត្រទៅនឹងការផ្លាស់ប្តូរដែលមានស្រាប់) ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អនាគតដែលមិនទាក់ទងនឹងបរិមាណនិមិត្តនោះ។ ឧទាហរណ៍ កិច្ចសន្យាមួយអាចតម្រូវនូវការទូទាត់ថេរ ១០០០ ឯកតារូបិយវត្ថុ ប្រសិនបើអត្រា LIBOR រយៈពេលប្រាំមួយខែកើនឡើង ១០០ ចំណុច។ កិច្ចសន្យាបែបនេះ គឺជានិស្សន្ទ បើទោះបីជាបរិមាណនិមិត្តមិនបានបញ្ជាក់ក៏ដោយ។

BA.2 និយមន័យ នៃនិសន្ទន្ទ នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ រួមមានកិច្ចសន្យា ដែលត្រូវបានទូទាត់ដុល

ដោយការប្រគល់នូវធាតុ (ឧ.forward contract រហូតដល់លើការទិញឧបករណ៍ហិរញ្ញវត្ថុបំណុលមានអត្រាថេរ)។ អង្គភាព អាចមានកិច្ចសន្យាដើម្បីទិញឬលក់ធាតុមិនហិរញ្ញវត្ថុដែលអាចត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធឬជាឧបករណ៍ហិរញ្ញវត្ថុផ្សេង ឬដោយការដោះដូរឧបករណ៍ហិរញ្ញវត្ថុ (ឧ.កិច្ចសន្យាទិញឬលក់កុំម៉ូឌីធីតាមថ្លៃថេរមួយនាពេលអនាគត)។ កិច្ចសន្យាបែបនេះស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ដរាបណាវាបានបន្តកាន់កាប់សម្រាប់គោលបំណងនៃការប្រគល់ឲ្យធាតុ មិនមែនហិរញ្ញវត្ថុ ដោយអនុលោមតាមការទិញ តាមការរំពឹងទុករបស់អង្គភាព, ការតម្រូវឲ្យលក់ ឬការប្រើប្រាស់ (មើល កថាខណ្ឌ ៥-៧នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)។

BA3 ចរិតលក្ខណៈមួយនៃនិស្សន្ទគឺថា វាមានការវិនិយោគសុទ្ធដំបូងដែលតិចជាងបរិមាណដែលបានតម្រូវ សម្រាប់ប្រភេទផ្សេងទៀត នៃកិច្ចសន្យាដែលនឹងត្រូវរំពឹងថាមានការឆ្លើយតបស្រដៀងគ្នា ចំពោះការផ្លាស់ប្តូរកត្តាទីផ្សារ។ option contract ឆ្លើយតបនឹងនិយមន័យនោះពីព្រោះកម្រៃតបសងតិចជាងការវិនិយោគដែលនឹងត្រូវបានតម្រូវដើម្បីទទួលបានឧបករណ៍ហិរញ្ញវត្ថុដែលជម្រើសពិសេស មានការពាក់ពន្ធ័។ currency swap ដែលតម្រូវនូវការដោះដូរលើកដំបូងនៃរូបិយវត្ថុខុសគ្នាមានតម្លៃស្មើនឹងតម្លៃសមស្រប ឆ្លើយតបនឹងនិយមន័យពីព្រោះវាមានការវិនិយោគដំបូងស្មើសូន្យ។

BA4 ការទិញឬការលក់តាមរបៀបធម្មតា នឹងបង្កើនការតាំងចិត្តនៃថ្លៃថេរ រវាងកាលបរិច្ឆេទជួញដូរនិងកាលបរិច្ឆេទនៃការទូទាត់ដែលឆ្លើយតប នឹងនិយមន័យនៃនិស្សន្ទ។ ទោះជាយ៉ាងណាដោយសារតែរយៈពេលខ្លីនៃការតាំងចិត្ត វាមិនទទួលស្គាល់ថាជាឧបករណ៍ហិរញ្ញវត្ថុ និស្សន្ទឡើយ។ ផ្ទុយទៅវិញ ស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះផ្តល់ នូវកិច្ចការគណនេយ្យពិសេសសម្រាប់កិច្ចសន្យាតាមរបៀបធម្មតា (មើល កថាខណ្ឌ៣.១.២ និង ខ៣.១.៣-ខ៣.១.៦)។

BA5 និមយន័យអំពីនិស្សន្ទសំដៅដល់អថេរមិនមែនហិរញ្ញវត្ថុ ដែលមិនបញ្ជាក់ចំពោះភាគីមួយនៃកិច្ចសន្យា។ ទាំងនេះរួមមាន សន្ទស្សន៍នៃការខាតបង់ដោយការរញ្ជួយដីនៅក្នុងតំបន់ណាមួយនិងសន្ទស្សន៍នៃសីតុណ្ហភាពនៅទីក្រុងណាមួយ។ អថេរមិនមែនហិរញ្ញវត្ថុ បញ្ជាក់ចំពោះភាគីមួយ នៃកិច្ចសន្យារួមមានការកើតឡើង ឬមិនកើតឡើងនៃអគ្គីភ័យ ដែលជាការខូចខាត ឬការបំផ្លេចបំផ្លាញ ទ្រព្យសកម្មរបស់ភាគីមួយនៃកិច្ចសន្យា។ការផ្លាស់ប្តូតម្លៃសមស្របនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ គឺបញ្ជាក់ចំពោះម្ចាស់ ប្រសិនបើតម្លៃសមស្របមិនឆ្លុះបញ្ចាំងតែ ការផ្លាស់ប្តូរថ្លៃទីផ្សារ សម្រាប់ទ្រព្យសកម្មនោះ (អថេរហិរញ្ញវត្ថុ)ប៉ុន្តែក៏ជាលក្ខខណ្ឌនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ ដែលបានកាន់កាប់(អថេរមិនមែនហិរញ្ញវត្ថុ)។ឧទាហរណ៍ ប្រសិនបើការធានាសម្រាប់តម្លៃសំណល់របស់រថយន្តមួយ បានធ្វើឱ្យអ្នកធានា

ត្រូវបានប្រឈមនឹងហានិភ័យ នៃការផ្លាស់ប្តូរលក្ខខណ្ឌរូបវន្ត របស់រថយន្ត, ការផ្លាស់ប្តូរ នៅក្នុងតម្លៃសំណល់ គឺបញ្ជាក់ចំពោះម្ចាស់រថយន្ត។

## ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដែលកាន់កាប់សម្រាប់ការជួញដូរ

BA6 ជាទូទៅ ការជួញដូរឆ្លុះបញ្ចាំងការទិញលក់ញឹកញាប់ និងសកម្ម, ហើយឧបករណ៍ហិរញ្ញវត្ថុដែលកាន់កាប់សម្រាប់ការជួញដូរជាទូទៅត្រូវបានប្រើជាមួយនឹងគោលបំណងនៃការបង្កើតប្រាក់ចំណេញពីការប្រែប្រួលឡើងចុះរយៈពេលខ្លីនៃថ្លៃឬភាគរយចំណេញរបស់ឈ្មួញអន្តរការី។

BA7 បំណុលហិរញ្ញវត្ថុដែលកាន់កាប់សម្រាប់ការជួញដូររួមមាន៖

(ក) បំណុលមាននិស្សន្ទ ដែលមិនត្រូវបានរាប់ថាជា ឧបករណ៍ទប់ស្កាត់ហានិភ័យ

(ខ) កាតព្វកិច្ចប្រគល់ឲ្យ នូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានខ្ចីដោយអ្នកលក់រយៈពេលខ្លី (មានន័យថាអង្គភាពដែលលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលខ្លួនបានខ្ចី និងមិនទាន់ក្លាយជាកម្មសិទ្ធិនៅឡើយ)

(គ) បំណុលហិរញ្ញវត្ថុដែលបានកើតឡើងក្នុងបំណងទិញមកវិញនាពេលអនាគតដ៏ខ្លី (ឧ. ឧបករណ៍ហិរញ្ញវត្ថុបំណុលមានថ្លៃសម្រង់ដែលអ្នកបោះផ្សាយអាចទិញមកវិញនាពេលអនាគតដ៏ខ្លីអាស្រ័យលើការផ្លាស់ប្តូរតម្លៃសមស្របរបស់វា) និង

(ឃ) បំណុលហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃផលបត្រនៃឧបករណ៍ហិរញ្ញវត្ថុដែលស្រដៀងគ្នាដែលត្រូវបានគ្រប់គ្រងរួមគ្នា និងមានភស្តុតាងនៃបែបផែននៃការរកចំណេញរយៈពេលខ្លី។

BA8 ហេតុការណ៍ពិតដែលថាបំណុលត្រូវបានប្រើដើម្បីផ្តល់ទុនសកម្មភាពនៃការជួញដូរ ដោយខ្លួនវា មិនធ្វើឲ្យបំណុលនោះក្លាយជាបំណុលសម្រាប់ការជួញដូរ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ